# អធិប្បាយ
# មង្គលសូត្រសង្ខេប

ព្រះវិន័យធរ អនុគណ

ឯក-ញឹម ធម្មិស្សរោ វត្តធម្មិស្សរារាម

ខេត្តសៀមរាប

*រៀបរៀង*

បោះពុម្ពគ្រាដំបូង

*ព.ស.២៤៩៩*    *គ.ស.១៩៥៦*

# អារម្ភកថា

ហេតុដើមដែលនាំឱ្យកើត សៀវភៅអធិប្បាយមង្គលសូត្រសង្ខេបនេះឡើង មកពីឧបាសក គិម-ស៊ុយ ឧបាសិកា ហ៊ុម ជាម្ចាស់រោងពុម្ពខេមររដ្ឋ នៅភ្នំពេញ, និយាយនឹងខ្ញុំថាៈ មានមនុស្សច្រើនគ្នាត្រូវការចង់ដឹងពីរឿងមង្គល ៣៨ ប្រការ, ក៏អារាធនាខ្ញុំឱ្យរៀបរៀងធម៌នេះឡើង ដើម្បីឱ្យបានជាប្រយោជន៍ដល់ពួកពុទ្ធបរិស័ទទាំងឡាយនោះៗផង ត្រូវនឹងបំណងខ្ញុំចង់រៀបរៀងធម៌នេះធ្វើជាធម្មទានផងដែរ ទើបខ្ញុំខំឆ្លៀតយកឱកាសខ្លះមករៀបរៀងធម៌នេះឡើង ។

កាលដែលខ្ញុំនឹងធ្វើនោះ ខ្ញុំបានយកគម្ពីរមង្គលត្ថទីបនីអដ្ឋកថាមង្គលសូត្រមកតាំងទុកជាគោល ហើយខ្ញុំរៀបរៀងដាក់ឱ្យមានកងធម៌ ព្រមទាំងនិទានរឿងខ្លីៗ ដើម្បីទាញយកបុគ្គលាធិដ្ឋាននេះ មកជាជំនួយធម្មាធិដ្ឋាន, ប៉ុន្តែខ្ញុំមិនបាននិយមយកតាមបែបក្នុងគម្ពីរនោះដោយសព្វគ្រប់ទេ ខ្ញុំស្រង់

យកតែត្រង់ណា ដែលមានសារប្រយោជន៍ច្រើនដល់អ្នកមើល-អ្នកស្តាប់ ហើយត្រូវតាមបំណងរបស់ខ្ញុំអ្នករៀបរៀងនោះផង ។

ដោយហេតុនេះ ខ្ញុំសូមអភ័យទោសអំពីសំណាក់នៃលោកអ្នកជាបណ្ឌិតទាំងឡាយ កុំប្រកាន់ទោសព្រោះខ្ញុំធ្វើកាត់ច្រូតខ្លីៗ ដើម្បីឱ្យតិចចំនួនសន្លឹកក្រដាសក្នុងសៀវភៅនេះផង ។

នៅទីបំផុតនេះ ខ្ញុំសូមផ្ញើសេចក្តីភ្ញាំងភ្ញាត់ខុសឆ្គងលើលោក-អ្នកបណ្ឌិត បើឃើញទាស់ខុសត្រង់ណា សូមមេត្តាជួយកែតម្រូវឱ្យខ្ញុំផង, ធម្មតាការងារទាំងពួង រមែងមានខុសព្រោះធ្វើ បើគ្មានធ្វើការអ្វីទេ ក៏គ្មានទាំងខុស គ្មានទាំងត្រូវផងដែរ ។ ប៉ុន្តែ ខ្ញុំមានសង្ឃឹមថា: ការព្យាយាមរបស់ខ្ញុំនេះ គង់នឹងបានសម្រេចប្រយោជន៍ដល់ជនច្រើនគ្នាជាមិនខាន ដោយបានមើលបានស្តាប់ បានគិត បានសួរ បានកត់គោលទុក ត្រង់កន្លែងណាមួយ ដែលខ្លួនត្រូវការចង់ចេះចង់ចាំធម៌នោះៗ ពុំលែងឡើយ ។

ព្រះវិន័យធរ អនុគណ

ធម្មិស្សរោ ឯក - ញឹម

# មង្គលប្បវត្តិ

*រឿងមង្គលសូត្រនេះ ហេតុដើមកើតមកអំពីអាចារ្យបីនាក់ គឺៈ អាចារ្យទិដ្ឋប្រកាន់ថាៈ ឃើញជាមង្គល ១, អាចារ្យសុតប្រកាន់ថាៈ ឮជាមង្គល ១, អាចារ្យមុតប្រកាន់ថាៈ លិទ្ធភ្លក្សជាមង្គល ១ ។*

*លុះអាចារ្យទាំង ៣ នាក់ជជែកគ្នា ចំណែកអាចារ្យទិដ្ឋថាៈ មង្គលនោះស្រេចនឹងភ្នែកឃើញរូបល្អៗ ទើបជាមង្គលប្រសើរ ។*

*អាចារ្យសុតថាៈ ភ្នែកឃើញរូបល្អខ្លះអាក្រក់ខ្លះ នឹងយកការឃើញនេះជាមង្គលពុំបានឡើយ ។ ចំណែកខ្ញុំថាៈ ការឮសំឡេងពីរោះគាប់ចិត្តខ្លួន ទើបបានជាមង្គលប្រសើរពិតមែន ។*

*អាចារ្យមុតថាៈ ការឮសំឡេងនេះនឹងយកជាមង្គលក៏ពុំបាន ព្រោះត្រចៀកយើងតែងឮសូរសម្លេងអាក្រក់ខ្លះ ល្អខ្លះ បើឮសុទ្ធតែល្អទៅទើបជាមង្គលមែន, ចំណែកខ្ញុំថាៈ ស្រេចនឹងអណ្ដាតលិទ្ធភ្លក្សត្រូវលើម្ហូបចំណីឆ្ងាញ់ពិសាទើបជាមង្គលប្រសើរ ។*

អាចារ្យទិដ្ឋ និងអាចារ្យសុត គេនាំគ្នាតបត្រឡប់មកឱ្យអាចារ្យមុតវិញថា: អ្នកឯងថានេះក៏មិនត្រូវទៀត យើងមិនយល់ព្រមតាមពាក្យអ្នកថានោះទេ ព្រោះការលិទ្ធភ្លក្សនេះ ជួនកាលត្រូវលើម្ហូបចំណីឆ្ងាញ់ពិសា ជួនកាលត្រូវលើម្ហូបចំណីមិនឆ្ងាញ់មានរសខារចត់ជូរល្វីងជាដើម នឹងថាការលិទ្ធភ្លក្សដោយអណ្តាតនេះ ជាមង្គលក៏ពុំបានឡើយ ។ ម៉្លោះហើយពួកមនុស្សអ្នកស្តាប់ ក៏ចាប់ចិត្តចូលចិត្តដោយស្រឡាញ់ផ្សេងៗគ្នា អ្នកខ្លះចូលចិត្តជឿតាមពាក្យអាចារ្យទិដ្ឋ, អ្នកខ្លះចូលចិត្តជឿតាមពាក្យអាចារ្យសុត, អ្នកខ្លះក៏ចូលចិត្តជឿតាមពាក្យអាចារ្យមុត, មនុស្សនោះក៏បែកគ្នាជាបីពួក មិនបែកតែមនុស្សក៏បែកដល់ពួកទេពតាដែលជាមិត្រគ្នានឹងមនុស្សផង ចាប់តាំងពីភុម្មទេវតាជាដើមឡើងទៅដល់ស្ថានព្រហ្មលោក ឈ្មោះអកនិដ្ឋកា កើតជាកោលាហលជជែកគ្នាជ្រួលជ្រើមអស់ ១២ ឆ្នាំ ។ ទុកជាពួកមនុស្សនិងទេពតាទាំងឡាយ ទាំង ១ ម៉ឺនចក្រវាឡនាំគ្នាគិតរកមង្គលអស់កាលយូរអង្វែងដល់ទៅ ១២ ឆ្នាំដូច្នោះហើយ ក៏នៅ

តែរកមង្គលមិនឃើញឡើយ ទើបនាំគ្នាទៅសួររកមង្គលនឹងព្រះឥន្ទ្រាធិរាជៗ ក៏សួរបញ្ជាក់ថា: ការណ៍ឈ្មោះទាស់ទែងខ្វែងគំនិតគ្នា ពីការណ៍រកមង្គលនេះកើតពីស្ថានណាមក ? ទេពតាទាំងឡាយនោះ ក៏ឆ្លើយទូលតបទៅព្រះឥន្ទវិញថា: កើតមកពីស្ថានមនុស្សលោក ។ ទើបព្រះឥន្ទប្រាប់ឧបាយដល់ទេពតាទាំងឡាយនោះថា: បើកើតពីស្ថានមនុស្សលោកមក ព្រះពុទ្ធជាម្ចាស់ព្រះអង្គបានត្រាស់ហើយ សព្វថ្ងៃគង់នៅនឹងវត្តព្រះជេតពន នាស្ថានមនុស្សលោកនោះស្រាប់, អ្នកទាំងឡាយ ចូរនាំគ្នាចុះទៅក្រាបថ្វាយបង្គំទូលសួររកមង្គលនេះ នឹងព្រះពុទ្ធជាម្ចាស់នោះចុះ ព្រះអង្គនឹងសម្ដែងមង្គលនេះ ប្រាប់អ្នកទាំងឡាយ; ទើបទេពតាទាំងឡាយនោះ ក៏នាំគ្នាចុះមកកាន់ស្ថានមនុស្ស ហើយចូលទៅទូលសួរព្រះសាស្ដា, ព្រះបរម-លោកនាថក៏ទ្រង់សំដែងនូវមង្គល ៣៨ ប្រការ ដែលជាគ្រឿងញុំាងបាបធម៌ទាំងពួងឱ្យវិនាសទៅ ដល់នរជនទាំងឡាយទាំងមនុស្សទាំងទេពតា ដ៏ច្រើនក្រៃលែងនឹងរាប់ចំនួនពុំបាន,

ឯពួកទេពតាទាំងឡាយនោះ លុះច្រើនហួសពេក វត្តជេតពន ដែលជាវត្តធំបំផុតក្នុងគ្រា ពុទ្ធសម័យ មានទំហំ ៣ យោជន៍ ៤ ជ្រុង បើប្រមាណនិងគីឡូម៉ែត្រដែលប្រើសម័យនេះ ត្រូវជា ២១ គីឡូម៉ែត្រ ៤ ជ្រុងស្មើ ក៏ចង្អៀត, ទើបទេពតាទាំងឡាយនោះ ក៏និម្មិតខ្លួនតូចៗទំហំប៉ុន គ្រាប់ខ្សាច់ ហើយនៅផ្តុំគ្នាជាពួកៗ ក្នុងមួយពួកៗ ចំនួន ១០ ខ្លះ ២០ ខ្លះ ៣០ ខ្លះ ៤០ ខ្លះ ៥០ ខ្លះ ។ល។ នៅចាំស្តាប់ព្រះពុទ្ធ អង្គសំដែងមង្គលក្នុងគ្រានោះឯង ដូចមានក្នុងរឿងដំណាលរបស់ព្រះអានន្ទ ទុកក្នុងខាងដើម សូត្រ តទៅនេះ ។

# (បញ្ជីមាតិកា)

⊚ ⊚ ⊚


| សារបណ្ណរឿង | | ទំព័រ | សារបណ្ណរឿង | | ទំព័រ |
|---|---|---|---|---|---|
| មង្គលទី ១ | ពាលកថា... | ១១ | មង្គលទី ២១ | អប្បមាទកថា... | ៨២ |
| មង្គលទី ២ | បណ្ឌិតកថា... | ១៦ | មង្គលទី ២២ | គារវកថា... | ៨៦ |
| មង្គលទី ៣ | បូជនីយកថា... | ១៩ | មង្គលទី ២៣ | និវាតកថា... | ៩២ |
| មង្គលទី ៤ | បដិរូបទេសវាសកថា... | ២១ | មង្គលទី ២៤ | សន្តុដ្ឋិកថា... | ៩៦ |
| មង្គលទី ៥ | បុញ្ញកថា... | ២៥ | មង្គលទី ២៥ | កតញ្ញុតាកថា... | ៩៩ |
| មង្គលទី ៦ | អត្តសម្មាបណិធិកថា... | ៣៣ | មង្គលទី ២៦ | ធម្មស្សវនកថា... | ១០៦ |
| មង្គលទី ៧ | ពាហុសច្ចកថា... | ៣៦ | មង្គលទី ២៧ | ខន្តិកថា... | ១១១ |
| មង្គលទី ៨ | សិប្បកថា... | ៣៩ | មង្គលទី ២៨ | សោវចស្សតាកថា... | ១១៦ |
| មង្គលទី ៩ | វិនយកថា... | ៤៣ | មង្គលទី ២៩ | សមណទស្សនកថា... | ១១៩ |
| មង្គលទី ១០ | សុភាសិតកថា... | ៤៦ | មង្គលទី ៣០ | ធម្មសាកច្ឆាកថា... | ១២២ |
| មង្គលទី១១-១២ | មាតាបិតុឧបដ្ឋានកថា... | ៤៩ | មង្គលទី ៣១ | តបកថា... | ១២៦ |
| មង្គលទី ១៣ | បុត្តទារសង្គហកថា... | ៥៤ | មង្គលទី ៣២ | ព្រហ្មចរិយកថា... | ១៣០ |
| មង្គលទី ១៤ | អនាកុលាកម្មន្តកថា... | ៥៨ | មង្គលទី ៣៣ | អរិយសច្ចទស្សនកថា | ១៣៤ |
| មង្គលទី ១៥ | ទានកថា... | ៦២ | មង្គលទី ៣៤ | និព្វានសច្ឆិកិរិយាកថា | ១៤០ |
| មង្គលទី ១៦ | ធម្មចរិយាកថា... | ៦៦ | មង្គលទី ៣៥ | អកម្បិតចិត្តកថា... | ១៤៦ |
| មង្គលទី ១៧ | ញាតកាសង្គហកថា... | ៦៩ | មង្គលទី ៣៦ | អសោកចិត្តកថា... | ១៤៩ |
| មង្គលទី ១៨ | អនវជ្ជកម្មកថា... | ៧៣ | មង្គលទី ៣៧ | វិរជចិត្តកថា... | ១៦០ |
| មង្គលទី ១៩ | បាបវិរតិកថា... | ៧៧ | មង្គលទី ៣៨ | ខេមចិត្តកថា... | ១៦៥ |
| មង្គលទី ២០ | មជ្ជបានសញ្ញមកថា... | ៧៩ | | | |

# មង្គលសូត្រ

**ឯវមេ្ម សុតំ** (សូត្រនេះឈ្មោះមង្គលសូត្រ) គឺខ្ញុំឈ្មោះអានន្ទ បានស្តាប់មកហើយយ៉ាងនេះថាៈ

សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តព្រះជេតពន ជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋី សាងថ្វាយទៀបក្រុងសាវត្ថី គ្រានោះឯងទេពតាទាំងឡាយ ចាត់ឱ្យទេពតាអង្គមួយមាននាមនិងគោត្រពុំប្រាកដ កាលវេលារាត្រីបឋមយាមកន្លងទៅហើយ មានរស្មីដ៏ល្អញ៉ាំងវត្តជេតពនជុំវិញទាំងអស់ឱ្យភ្លឺស្វាងហើយ ព្រះដ៏មានព្រះភាគទ្រង់គង់ក្នុងទីណា ក៏ចូលទៅកាន់ទីនោះ លុះចូលទៅដល់ហើយ ទើបថ្វាយបង្គំចំពោះព្រះដ៏មានព្រះភាគ ហើយឈរក្នុងទីដ៏សមគួរ កាលទេពតានោះឈរក្នុងទីដ៏សមគួរហើយ ទើបក្រាបទូលព្រះដ៏មានព្រះភាគដោយពាក្យជាគាថាយ៉ាងនេះថាៈ

ពហូ ទេវា មនុស្សា ច មង្គលានិ អចិន្តយុំ
អាកង្ខមានា សោត្ថានំ ព្រូហិ មង្គលមុត្តមំ

ទេវតានិងមនុស្សទាំងឡាយជាច្រើន ប្រាថ្នានូវសេចក្តីសួស្តី បានគិតរកនូវមង្គលទាំងឡាយ (ជាយូរអង្វែងអស់១២ ឆ្នាំក៏រកពុំឃើញសោះឡើយ) សូមព្រះអង្គទ្រង់ព្រះមេត្តាប្រោសសំដែងប្រាប់នូវមង្គលដ៏ឧត្តម ។

(ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សំដែងតបពាក្យទេវតានោះដោយពាក្យជាគាថាយ៉ាងនេះថា)

អសេវនា ច ពាលានំ បណ្ឌិតានញ្ច សេវនា
បូជា ច បូជនីយានំ ឯតម្មង្គលមុត្តមំ

កិរិយាមិនសេពគប់នូវបុគ្គលពាលទាំងឡាយ ១ កិរិយាសេពគប់នូវបុគ្គលជាបណ្ឌិតទាំងឡាយ ១ កិរិយាបូជាដល់បុគ្គលដែលគួរបូជាទាំងឡាយ ១ ទាំងបីនេះជាមង្គលដ៏ឧត្តម ។ ក្នុងគាថាទី ១ នេះ មាន ៣ មង្គល ឯពាក្យថាមង្គលនេះប្រែថាសេចក្តីចំរើនដោយសុខសួស្តី ។

# មង្គលទី ១

អធិប្បាយថា: អសេវនា ច ពាលានំ កិរិយាមិនសេពគប់នូវបុគ្គលទាំងឡាយ ជាមង្គលដ៏ឧត្តម ។ គ្រាន់តែមិនសេពគប់នឹងបុគ្គលពាលទុកជាមង្គលទី ១ បាននោះ ព្រោះថាមិនបានខូចចិត្ត មិនបានខូចខ្លួន មិនបានបង់ខាតខូចទ្រព្យសម្បត្តិអ្វីសោះ ទើបឱ្យឈ្មោះថាជាមង្គលទី ១, ឯពាលនោះមានច្រើនប្រការណាស់ មិនងាយនឹងចំណាំរូបពាលបាន; ពាលនេះមិនមែននៅលើគ្រហស្ថ ឬនៅលើរូបបព្វជិតណាមួយៗ ឡើយស្រេចហើយតែបុគ្គលណាកាត់ប្រយោជន៍ ២ ប្រការ គឺប្រយោជន៍ខ្លួន និង ប្រយោជន៍ជនដទៃចោល ហៅថាពាល, បុគ្គលពាលនោះ ឥតស្គាល់គុណទោស ឥតស្គាល់ខុសត្រូវអ្វីទេ មានតែដង្ហើមដកចេញចូល ដូចជាស្នប់ឃ្យូរៗ ឥតចេះដឹងធម៌បណ្ឌិតអ្វីបន្តិចបន្តួចសោះឡើយ ហើយបុគ្គលពាលនោះ រមែងកាត់ប្រយោជន៍ក្នុងជាតិនេះផង កាត់ប្រយោជន៍ក្នុងជាតិខាងមុខផង កាត់ប្រយោជន៍ក្នុងព្រះនិព្វានផង បុគ្គលពាលមានលក្ខណៈឱ្យចំណាំបានដោយសណ្ឋាន ៣ យ៉ាងគឺ: គំនិត

អាក្រក់ ១ ធ្វើអំពើអាក្រក់ដោយកាយ ១ ដោយវាចា ១ ទាំង ៣ នេះជាលក្ខណៈពាល; ឯរូបបុគ្គលពាលនោះ មិនមែនអាក្រក់ស្មើគ្នាប៉ុនគ្នាដូចគ្នាទាំងអស់ទេ មានធ្ងន់ស្រាលលើសខ្វះគ្នាជា ៣ ប្រការគឺៈ ពាលោ បុគ្គលគ្រាន់តែល្ងង់ក៏ហៅថាពាលដែរ, ពាលោខោ បុគ្គលល្ងង់ហើយធ្វើអាក្រក់ ដោយកាយវាចាចិត្តទៀត ហៅថាពាលពិតមានពិសហើយ, អតិពាលោខោ បុគ្គលល្ងង់ផង ធ្វើអំពើអាក្រក់ដោយកាយវាចាចិត្ត ដ៏ក្លៀវក្លាយ៉ាងក្រៃលែងផង ហៅថាមហាពាល ឬហៅថាមហាពាលពិតពេកណាស់; មានពិសក្រៃលែងជាងពស់វែក គួរឱ្យខ្លាចគួឱ្យចៀសវាងចេញឱ្យឆ្ងាយ អ្នកប្រាជ្ញទាំងឡាយមានអកិត្តិតាបសជាដើម លោកផ្តាំកូនថាៈ បើទុកជាមនុស្សនៅក្នុងជម្ពូទ្វីបនេះ មានតែពីរនាក់នឹងជនពាលនោះក៏ដោយ លោកថា កុំឱ្យនៅជាមួយនឹងបុគ្គលពាលនោះសោះឡើយ បានជាខ្លាចជនពាលខ្លាំងម្ល៉េះព្រោះពាលនោះ បើសេពគប់ទៅកាលណាហើយ ពាលនោះវានាំឱ្យធ្វើអំពើពាលផ្សេងៗ មានសម្លាប់ លួចប្លន់យកទ្រព្យសម្បត្តិ និងលួចកូនប្រពន្ធជនដទៃ ភូតកុហកផឹកទឹកស្រវឹង

ជាដើម កុំថាឡើយអ្នកដទៃ សូម្បីតែមាតាបិតាបង្កើតខ្លួន ក៏ជនពាលនោះ វានាំកូនឱ្យសម្លាប់ចោលបានដែរ, ដូចរឿងអជាតសត្តុកុមារ ទៅសេពគប់នឹងភិក្ខុទេវទត្តជាបុគ្គលពាលៗ នោះញុះញង់ឱ្យសម្លាប់ព្រះបាទពិម្ពិសារជាបិតា ដោយដាក់ទ្រុងដែកពុះព្រះបាទា បង្អត់អាហារទាល់តែទិវង្គតទៅ ដើម្បីជ្រែកយករាជសម្បត្តិ សូម្បីព្រះនាងវេទេហិកាទេវីជាព្រះមាតា សូមអង្វរករយ៉ាងណាថាដូចម្ដេចៗក្ដី គ៏ពុំព្រមតាមសោះឡើយ, នេះហើយការសេពគប់នឹងពាលៗ នាំឱ្យធ្វើបិតុឃាត គឺសម្លាប់បិតាហើយខ្លួនត្រូវធ្លាក់ទៅសោយទុក្ខវេទនា នៅក្នុងលោហកុម្ភីនរកដរាបដល់មកសព្វថ្ងៃនេះពុំទាន់រួចឡើយ ។ ការសេពគប់នេះធំបំផុត កុំចាំបាច់និយាយថ្វីដល់ជាតិមនុស្សនិងមនុស្ស សូម្បីតែសត្វតិរច្ឆាននិងមនុស្ស លុះអាស្រ័យគ្នាហើយ ក៏ប្រព្រឹត្តយកតម្រាប់តាមគ្នាទៅបាន ដូចរឿងសេកឈ្មោះសត្តិគុម្ពៈនិងបុប្ផកៈសេកទាំងពីរនេះបងប្អូនបង្កើតនឹងគ្នា នៅវេលាសត្វសេកទាំងពីរនេះដុះស្លាបក្រាស់ហើយ មានខ្យល់កំបុតត្បូងក្ដួចយកសេកទាំងពីរនេះ បើុងឡើងតាមខ្យល់ទៅ សេកមួយធ្លាក់ទៅនៅនឹងជំរំលំពែងចោរៗ រើសយកទៅថែរក្សា សេកនោះឈ្មោះថា

សត្តិគុម្ពៈៗ នេះ ចេះនិយាយភាសាមនុស្សអសប្បុរសតាមចោរ មានកាយវាចាចិត្តជាចោរ ។ ឯសេកមួយទៀត ខ្យល់ក្ចចធ្លាក់ទៅនៅនឹងសួនផ្កាឥសីៗ រើសយកទៅចិញ្ចឹងថែរក្សា សេកនោះឈ្មោះថាបុប្ផកៈៗ នេះ ចេះនិយាយភាសាមនុស្សសប្បុរស តាមឥសី មានកាយវាចាចិត្តជាអ្នកមានសីល មានធម៌អាថ៌តាមឥសីទាំងអស់ នេះព្រោះអាស្រ័យធម៌សេពគប់ មិត្រពាល មិត្របណ្ឌិត សរសេចក្ដីឱ្យឃើញច្បាស់បានថាៈ អសប្បុរិសោ អសប្បុរិសការេ ការសេពគប់ស្មាគម រួបរួមរាប់រកមនុស្សជាអសប្បុរសៗ នោះ នឹងធ្វើខ្លួនឱ្យទៅជាមនុស្សអសប្បុរសផងបាន, សប្បុរិសោ សប្បុរិសការេ ការសេពគប់ស្មាគមរួបរួមរាប់រកមនុស្សជាសប្បុរសៗ នោះនឹងធ្វើខ្លួនឱ្យទៅជាមនុស្សសប្បុរសផងបានដោយពិត ។

ការសេពគប់នេះ កុំថាឡើយដល់រូបមនុស្សនិងសត្វ សូម្បីតែរុក្ខជាតិជានិជ្ជីវវត្ថុគឺរបស់គ្មានជីវិតសោះ គ្រាន់តែចម្រើនឡើងនិងវិនាសទៅវិញដោយធាតុ ៤ ប៉ុណ្ណោះ លោកសម្មតិឱ្យឈ្មោះថារស់ថាងាប់ ដូចជាដើមស្វាយរបស់ស្ដេចទធិវាហនៈនោះ

ពីដើមផ្លែមកមានរសជាតិឆ្ងាញ់ពិសាដូចជាផលាទិព្វ, លុះគ្រាក្រោយត្រូវគេយកដើមស្ដៅដែលមានជាតិល្វីង ទៅដាំអែបឱ្យឫសស្ដៅនិងឫសស្វាយឱបគ្នា គេយកវល្លិបណ្ដូលពេច ដែលមានជាតិល្វីងណាស់នោះ ទៅដាំដាក់បំពាក់ឱ្យព័ទ្ធពាសពេញមែកស្វាយៗ នោះ លុះមានផ្លែចេញមកក៏ល្វីដូចជាបណ្ដូលពេចពិតៗ ផ្លែស្វាយដែលអន្តរាយនេះ ដោយសេចក្ដីព្យាបាទរបស់ស្ដេចដទៃ ព្រោះតែស្ដេចទធិវាហនៈនោះ មិនចែកពូជស្វាយទិព្វដល់ស្ដេចជិតខាងផង; ក្នុងបំណងនេះ នាំរឿងមកបញ្ជាក់ឱ្យឃើញថាៈ ការសេពគប់មិត្រពាលនិងបណ្ឌិត ក្នុងមង្គលទី ១ ចប់ដោយសង្ខេបប៉ុណ្ណេះ ។

---

# មង្គលទី ២

បណ្ឌិតានញ្ច សេវនា កិរិយាសេពគប់នូវបុគ្គលជាបណ្ឌិតទាំងឡាយជាមង្គលដ៏ឧត្តម ។

អធិប្បាយថាៈ បណ្ឌិតទាំងឡាយក្នុងលោក មានព្រះពុទ្ធា-ទិបណ្ឌិតជាដើម ទោះបីកាលលោកនៅមានសន្តានជាបោថុជ្ជននៅឡើយក្តី លោកមានសន្តានដ៏បរិសុទ្ធផុតកិលេសអស់ហើយក្តី លោកមិនដែលកាត់ប្រយោជន៍ខ្លួនលោក និងប្រយោជន៍អ្នកដទៃឡើយ លោកតែងប្រកបដោយហិរិ និងឱត្តប្បៈ ព្រមទាំងប្រកបដោយ សទ្ធា សីលៈ សុតៈ ចាគៈ បញ្ញា លោកតែងប្រព្រឹត្តធ្វើប្រយោជន៍ ៣ ប្រការគឺៈ ប្រយោជន៍ជាតិនេះ និងប្រយោជន៍ជាតិខាងមុខ និងប្រយោជន៍ដ៏ក្រៃលែងគឺព្រះនិព្វានបុគ្គលដែលចូលទៅសេពគប់នឹងបណ្ឌិតទាំងឡាយ មានពុទ្ធាទិ-បណ្ឌិតជាដើមនោះ រមែងបានផលប្រយោជន៍ ដូចរឿងឧបតិស្សៈនិងកោលិតៈ ទាំងពីរនាក់នេះជាមិត្រសម្លាញ់នឹងគ្នាបានចូលទៅសិក្សាក្នុងសំណាក់អាចារ្យសញ្ជ័យ ឃើញលទ្ធិធម៌របស់អាចារ្យសញ្ជ័យថា មិនមានខ្លឹមសារ ក៏លាអាចារ្យដើម

បំបែកគ្នាស្វែងរកសារធម៌ ឬមោក្ខធម៌, ឯឧបតិស្សៈទៅកាន់ក្រុងរាជគ្រឹះ ក៏បានជួបនឹងព្រះអស្សជិតត្ថេរ ដែលជាតួអង្គព្រះសេអាមេត្រី([1]) លោកទើបនឹងបួសថ្មីៗ ផង ហើយសួររកបំណាងធម៌ថាមានទីបំផុតត្រឹមណា និងសួររកព្រះសាស្ដាចារ្យថា វាទៈដូចម្ដេច? គ្រានោះ អស្សជិតត្ថេរ លោកពោលថាៈ

យេ ធម្មា ហេតុប្បភវា តេសំ ហេតុំ តថាគតោ
តេសញ្ច យោ និរោធោ ច ឯវំ វាទី មហាសមណោ

ធម៌ទាំងឡាយឯណា មានហេតុជាដែនកើតឡើង ព្រះតថាគតពោលនូវហេតុនៃធម៌ទាំងឡាយនោះផង និងពោលនូវសេចក្ដីរំលត់ព្រមទាំងឧបាយជាគ្រឿងរំលត់ នូវធម៌ទាំងឡាយនោះផង ព្រះមហាសមណៈ ជាគ្រូអាត្មាព្រះអង្គមានវាទៈយ៉ាងនេះជាប្រក្រតី ។

ឯឧបតិស្សមាណព គ្រាន់តែបានស្ដាប់ប៉ុណ្ណេះ ក៏បានសម្រេចសោតាបត្តិផល ហើយថ្វាយបង្គំលាព្រះអស្សជិតត្ថេរទៅសំដែងធម៌ប្រាប់កោលិតៈជាសំឡាញ់ៗ នោះស្ដាប់ហើយក៏

[1] -ព្រះអរិយមេត្តយ្យៈ (ព្រះសិរីអារ្យមេត្រី) ។

បានសម្រេចសោតាបត្តិផលដូចគ្នា ក៏នាំគ្នាចូលមកបួសជាឯហិបព្វជ្ជាក្នុងព្រះពុទ្ធសាសនា គ្រាក្រោយតមក ក៏បានសម្រេចព្រះអរហត្ត ហើយឧបតិស្សៈ គឺព្រះសារីបុត្តត្ថេរ បានជាបឋម-សាវ័កព្រះពុទ្ធជាម្ចាស់យើង ឯកោលិតៈ គឺព្រះមោគ្គល្លានត្ថេរ ក៏បានទីជាទុតិយសាវ័កព្រះពុទ្ធជាម្ចាស់យើងនេះដែរ, ឯការសេពគប់នឹងបណ្ឌិត ក៏ឃើញថាបាននូវសេចក្ដីចម្រើនដោយពិត ។ មានរឿងចោរ ៥០០ នាក់ដទៃទៀត ភ័យនឹងរាជបុរសលើកទ័ពដេញតាម ក៏រត់ចូលទៅសូមសមាទានសីល ៥ អំពីសំណាក់អរញ្ញិកត្ថេរៗ ក៏ឱ្យសមាទានសីល ៥ ចប់ រាជបុរសមកទាន់ចាប់យកទៅសម្លាប់ស្លាប់ទៅ បានទៅកើតស្ថានសួគ៌ឈ្មោះតាវត្តិង្សសោយសុខក្នុងទិព្វវិមានទាំងអស់ ដោយការសេពគប់នឹងបណ្ឌិតនោះឯង ។

---

# មង្គ័លទី ៣

បូជា ច បូជនិយ្យានំ កិរិយាបូជាដល់បុគ្គលដែលគួរបូជាទាំងឡាយ ជាមង្គលដ៏ឧត្តម ។

អធិប្បាយថា: បុគ្គលដែលគួរបូជានោះ បុគ្គលជាន់ខ្ពស់ គឺព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រមទាំងព្រះធម៌ និងព្រះសង្ឃ, បុគ្គលជាន់កណ្តាល គឺឧបជ្ឈាយ៍ មាតាបិតា បងប្រុស បងស្រី ជីដូនជីតា និងសមណព្រាហ្មណ៍ទាំងឡាយឯណា ដែលមានសីលទាំងអម្បាលនេះជាបុគ្គលគួរបូជា, បុគ្គលជាន់ទាបគឺស្វាមី ក៏ជាបុគ្គលគួរបូជារបស់ភិរយាដែរ, ឯបុគ្គលដែលបានបូជាព្រះពុទ្ធនឹងនាំឱ្យមានតេជះច្រើន, បើបានបូជាព្រះធម៌ នឹងនាំឱ្យមានបញ្ញាច្រើន, បើបានបូជាព្រះសង្ឃ នឹងនាំឱ្យមានភោគសម្ប័ទច្រើន តាមអានុភាពត្រ័យរ័ត្ននោះៗ ការញែកផលានិសង្សបូជានេះ គ្រាន់តែឱ្យឃើញគុណានុភាពព្រះត្រ័យរ័ត្នប៉ុណ្ណោះ, ឯព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃនោះ លោកទុកដូចជាបិតាមាតានិងបុត្រ នៅក្នុងបន្ទុកគ្រួសារនិមួយៗ មិនបានដាច់ឆ្ងាយពីគ្នាពេកទេ, ឯអ្នកធ្វើបូជាព្រះពុទ្ធ នឹងបានប្រយោជន៍ក្នុងជាតិនេះផង

ក្នុងជាតិខាងមុខផង ដូចរឿងនាយមាលាការឈ្មោះសុមនៈ តែងតែបេះផ្កាម្លិះយកពីសួនផ្កាទៅថ្វាយព្រះបាទពិម្ពិសារ រាល់ៗថ្ងៃ ថ្ងៃមួយនោះ បានជួបនឹងព្រះសាស្តាចារ្យកើតចិត្តជ្រះថ្លា ក៏យកផ្កាម្លិះនោះ បាចថ្វាយព្រះសាស្តាចារ្យ នៅពាក់កណ្តាលផ្លូវទៅ, ឯផ្កាម្លិះនោះមិនមានជ្រុះមកដល់ដីឡើយ កើតជាផ្កាកម្រងដ៏ល្អអស្ចារ្យ មានទងខ្ទាស់ជាប់គ្នាបីដូចជាក្រឡាសំណាញ់ចាក់ស្រែះជាប់ជាផ្ទាំងពីរផ្ទាំង គឺផ្ទាំងមួយអណ្តែតពីខាងឆ្វេង ផ្ទាំងមួយទៀតអណ្តែតពីខាងស្តាំ ហើយអណ្តែតតាមព្រះពុទ្ធទៅ, ឯនាយសុមនមាលាការនោះ កាលបើបានឃើញដូច្នោះហើយ ក៏រឹតតែកើតចិត្តជ្រះថ្លាខ្លាំងឡើងណាស់ លុះទៅដល់ផ្ទះហើយ ក៏ប្រាប់ដំណើរនោះដល់ភរិយាៗ នោះជាស្រីពាល ភ័យពេកខ្លាចជាប់ទោសដល់ខ្លួនត្បិតគ្មានផ្កាថ្វាយព្រះបាទពិម្ពិសារ ក៏បន្ទោសស្វាមី និយាយសុំលែងលះគ្នាក្នុងវេលានោះ ហើយចុះចេញពីផ្ទះទៅក្រាបទូលពត៌មាននោះ ដល់ព្រះបាទពិម្ពិសារៗ ជ្រាបហើយក៏ទ្រង់ព្រះបណ្តេញស្រីនោះឱ្យចេញចាករាជធានី ហើយឱ្យហៅនាយមាលាការមកសួរបញ្ជាក់ ទ្រង់ជ្រាបហេតុសព្វគ្រប់ហើយព្រះអង្គជ្រះថ្លានឹងនាយមាលាការ ទើបទ្រង់ព្រះរាជទានរបស់

ឱ្យនាយមាលាការក្នុងមួយមុខៗ ប្រាំបីៗ គឺមាស ប្រាក់ គោ ក្របី ដំរី សេះ ខ្ញុំប្រុស ខ្ញុំស្រី និងស្រុកសួយប្រាំបីស្រុកទៀត ឱ្យជារង្វាន់ដល់នាយមាលាការៗ នេះ មិនមែនមានផលានិសង្ស ត្រឹមតែប៉ុណ្ណោះ នឹងមិនធ្លាក់ទៅនរកអស់មួយសែនកប្បទៀត ហើយលុះជាតិជាទីបំផុត នឹងបានត្រាស់ជាព្រះបច្ចេកពុទ្ធ ១ ព្រះអង្គមាននាមថាសុមនៈ ដោយផលបូជាផ្កាម្លិះនោះឯង ។

---

# មង្គលទី ៤

បដិរូបទេសវាសោ ច កិរិយានៅក្នុងប្រទេសដ៏សមគួរ ទុកជាមង្គលដ៏ឧត្តម ។

អធិប្បាយថាៈ ប្រទេសដ៏សមគួរនោះ សំដៅយកប្រទេស ដែលបរិបូរណ៍ទៅដោយធម៌វិន័យ បើគ្រាពុទ្ធសម័យ សំដៅយក មជ្ឈិមប្រទេស ជាប្រទេសបរិបូណ៌ដោយធម៌វិន័យហើយស្ថិត នៅពាក់កណ្តាលផែនដី ទុកថាជាបដិរូបប្រទេស ព្រោះប្រទេស នោះមានព្រះពុទ្ធ និងព្រះបច្ចេកពុទ្ធ និងព្រះអគ្គសាវកព្រះពុទ្ធ

តែងកើតតែងស្ថិតនៅក្នុងទីនោះ បុគ្គលដែលនៅក្នុងមជ្ឈិម-ប្រទេសនោះ រមែងបានអនុត្តរិយធម៌ គឺធម៌ដ៏ប្រសើរលើសលប់ ៦ ប្រការគឺ ទស្សនានុត្តរិយៈ ឃើញប្រសើរ គឺឃើញព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងអគ្គសាវកព្រះពុទ្ធ ១ សវនានុត្តរិយៈ ស្តាប់ប្រសើរគឺ ស្តាប់ធម៌ព្រះពុទ្ធជាដើម ១ លាភានុត្តរិយៈ បានប្រសើរ គឺបាននូវសទ្ធាចិត្ត ជឿកម្មជឿផល ជឿគុណព្រះរតន-ត្រ័យជាដើម ១ សិក្ខានុត្តរិយៈ សិក្សារៀនសូត្រប្រសើរ គឺសិក្សាធម៌អាថ៌ ឬធម្មវិន័យពុទ្ធសាសនា ១ ចារិចរិយានុត្តរិយៈ បម្រើប្រសើរ គឺបានបម្រើធ្វើជាឧបដ្ឋាកៈ ឬឧបដ្ឋាយិកាព្រះពុទ្ធ ឬក៏ជាវេយ្យាវច្ចករព្រះសង្ឃ ១ អនុស្សតានុត្តរិយៈ រឭកប្រសើរ គឺរឭកដល់គុណ ១០ យ៉ាង មានរឭកពុទ្ធគុណ ធម្ម-គុណ សង្ឃគុណជាដើម ១ (រួមជា ៦ ប្រការ) ហើយបុគ្គលនោះមានសទ្ធា មានសេចក្តីស្នេហាជាប់មិនដាច់ដោយចំណែកមួយ ដូចរឿងព្រាហ្មណ៍ម្នាក់ឈ្មោះវក្កលិ នៅក្នុងក្រុងសាវត្ថី បានឃើញរូបព្រះពុទ្ធជាម្ចាស់ហើយ ក៏មានចិត្តជ្រះថ្លាកើតសេចក្តីស្នេហាជាប់ចិត្តស្អិតក្នុងព្រះពុទ្ធរូបនោះ ចង់តែមើលព្រះរូបមិន

ចេះឆ្អែតឆ្អន់សោះ ទើបដល់ខ្លួនចេញពីផ្ទះទៅបួសក្នុងសំណាក់ព្រះសាស្តា លុះបួសហើយកាលណា គ្មានគិតសិក្សារៀនសូត្រធម៌អាថ៌អ្វីសោះ គិតតែពីតាមមើលព្រះបរមរូបរបស់ព្រះពុទ្ធអង្គនោះ លុះឧបនិស្ស័យដែលអាស្រ័យនឹងសេចក្តីអប់រំក្នុងព្រះសាស្តាចាស់ក្លាហើយ ទើបព្រះអង្គមានព្រះពុទ្ធដីកាថា នែ! វក្កលិ អ្នកឯងកុំមើលរូបតថាគតដោយមំសចក្ខុអ្នកឡើយ អ្នកចូរមើលធម៌ ចូរពិចារណាឱ្យឃើញធម៌តថាគតវិញចុះ អ្នកណាឃើញធម៌ អ្នកនោះឈ្មោះថាឃើញតថាគត អ្នកណាឃើញតថាគតអ្នកនោះឈ្មោះថាឃើញធម៌ ឯអ្នកឯងនេះគិតមើលត្រឹមតែរូបតថាគតប៉ុណ្ណោះ មិនមើលធម៌តថាគតដោយមំសចក្ខុសោះឡើយ ណ្ហើយចុះអ្នកឯងចូលចៀសចេញពីទីនេះទៅ, វក្កលិភិក្ខុនោះ កាលឮព្រះពុទ្ធជាម្ចាស់ទ្រង់បណ្តេញចេញដូច្នោះហើយ ក៏នឹកតូចចិត្តណាស់ស្រែកទ្រហោយំ ហើយដើរឡើងទៅលើភ្នំដរាប់ដល់កំពូល គិតថាអាត្មាអញរស់នៅធ្វើអ្វីទៀតឡើយបើខានឃើញព្រះសាស្តាហើយ ស្លាប់ទៅប្រសើរជាងរស់នៅហើយប្រុងនឹងផ្តួលខ្លួន ប្រមៀលទម្លាក់មកពីលើកំពូលភ្នំឱ្យស្លាប់ គ្រានោះ ព្រះសាស្តាទ្រង់ជ្រាបហើយ ក៏ព្រះអង្គធ្វើ

បាដិហារ្យ ហាក់បីដូចជាព្រះអង្គយាងទៅគង់ចំពោះភក្ត្រវក្កលិ-ភិក្ខុនោះ ហើយបញ្ចេញព្រះរស្មី ៦ ប្រការ បោយព្រះហស្តហៅភិក្ខុវក្កលិថា នែ! វក្កលិៗ ហើយទ្រង់ប្រទានធម៌ទេសនាចំពោះមុខវក្កលិៗ ក៏មានចិត្តជ្រះថ្លាកើតឧព្វេង្គាបីតិ អណ្ដែតខ្លួនឡើងទៅលើអាកាស ហើយលឿនឆ្ពោះទៅកាន់វត្តជេតពន ក្នុងគ្រានោះ ប្រាជ្ញាក៏ចុះឃើញច្បាស់នូវចតុរារិយសច្ច បានសម្រេចព្រះអរហត្តកាត់កិលេសជាសមុច្ឆេទប្បហារ ដោយសារបាននៅក្នុងប្រទេសដ៏សមគួរ បរិបូណ៌ដោយវត្ថុសក្តិសិទ្ធិ មានព្រះពុទ្ធជាដើម ដូចបានអធិប្បាយមកខាងដើមនោះឯង ។

# មង្គលទី ៩

បុព្វេ ច កតបុញ្ញតា ភាវៈនៃបុគ្គលបានធ្វើបុណ្យទុកហើយក្នុងកាលមុន ជាមង្គលដ៏ឧត្តម ។

អធិប្បាយថាៈ ការធ្វើទានក្តី ការរក្សាសីល ៥ សីល ៨ ជាដើមក្តី ការធ្វើភាវនាខាងផ្លូវសមថៈ ឬវិបស្សនាក្តី ការធ្វើកងការកុសលដទៃៗ មានធ្វើពុទ្ធបូជា ធម្មបូជា សង្ឃបូជា ឬក៏រៀនធម៌ស្តាប់ធម៌ទេសនាជាដើមក្តី ហៅថាធ្វើបុណ្យទាំងអស់ បុណ្យដែលបុគ្គលនឹងធ្វើបាននោះ កើតមកអំពីហេតុ ៣ យ៉ាង គឺ ១-បសាទោ កើតមកអំពីភ្នែកឃើញរូប ត្រចៀកឮសំឡេងជាដើម ហើយចិត្តក៏កើតជ្រះថ្លាឡើង ធ្វើបុណ្យមានទានជាដើមនោះៗ ទៅ, ២-សំវេគោ កើតមកអំពីភ្នែកឃើញរូបមនុស្សចាស់ឈឺស្លាប់ជាដើម ហើយតក់ស្លុតរន្ធត់ក្នុងចិត្តក៏ធ្វើបុណ្យនោះៗ ទៅ ៣-តេសុចរិតា កើតមកអំពីបញ្ញាពិចារណាឃើញទោសក្នុងអំពើទុច្ចរិត ឃើញគុណក្នុងអំពើសុចរិតហើយធ្វើបុណ្យ មានទាននិងសីលជាដើមនោះៗ ទៅ ។ អំពើបុណ្យទាំងអស់នោះ បុណ្យណាមួយក្តី ដែលបុគ្គលប្រុស-ស្រី បានធ្វើបានសន្សំទុក

មកហើយក្នុងកាលមុន គឺៈ តាំងអំពីជាតិមុនៗ មក បុណ្យនេះឯងមិនភ្លេចបុគ្គលនោះឡើយ នឹងតាមរកបុគ្គលនោះឱ្យផលសុខ-ចំរើនតាមលំដាប់ភពគ្រប់ៗជាតិពុំឃ្លៀងឃ្លាត; ដូចរឿងព្រះបាទកបិនរាជ និងព្រះនាងអនោជាទេវីជាដើម, មានសេចក្ដីដំណាលរឿងនេះទុក្នុងគម្ពីរមង្គលត្ថទីបនីថាៈ គ្រានោះជាចន្លោះព្រះពុទ្ធសាសនា មានស្រុកមួយឈ្មោះថា បេសកគ្រាម គឺជាស្រុកជាងតម្បាញមានមនុស្ស ១000 គ្រួនៅក្នុងស្រុកនោះឯមេជាងដែលជាធំជាងគេនោះ ជាអ្នកមានសទ្ធាជ្រះថ្លាក្នុងការបុណ្យ គ្រានោះ មានព្រះបច្ចេកពុទ្ធមួយពាន់អង្គមកអំពីព្រៃហិមពាន្ត ហើយបានជួបនឹងមេជាងតម្បាញៗ ដែលជាធំជាងគេនោះឃើញហើយក៏ជ្រះថ្លា ពិតនិមន្តព្រះបច្ចេកពុទ្ធទាំង ១000 អង្គនោះ សូមឱ្យគង់នៅចាំវស្សាក្នុងស្រុកនោះ លុះព្រះបច្ចេក-ពុទ្ធទទួលនិមន្តហើយ មនុស្សក្នុងស្រុកនោះទាំងអស់គ្នា ក៏មានសទ្ធាជ្រះថ្លាកាន់អង្គ មួយនាក់មួយអង្គៗគ្រប់ទាំង ១000 អង្គ, លុះដល់ថ្ងៃចេញវស្សា ក៏នាំគ្នាប្រគេនសំពត់សាដកចំណាំវស្សាដល់ព្រះបច្ចេកពុទ្ធទាំងឡាយនោះគ្រប់ៗគ្នា ឯមេជាងតម្បាញដែលជាធំជាងគេព្រមទាំងភរិយា ជាអ្នកមានប្រាជ្ញាជាងគេ នៅ

វេលាប្រគេនសំពត់ចំណាំវស្សានោះ មិនប្រគេនទទេៗ ដូចគេទេ ភរិយាមេជាងតម្បាញនោះ បានបេះផ្កានាងព្រៃមានពណ៌លឿងៗ ស្រស់ល្អចំនួនពីរបី យកមកដាក់លើសំពត់នោះហើយប្រគេន, ហើយដំកល់សេចក្តីប្រាថ្នាថាៈ កើតជាតិកាលណាទៅឯអនាគតទៀត សូមឱ្យបានជាធំជាងគេ ធ្វើតែមេគេជាដរាបទៅហើយសូមឱ្យបាននាមថា អនោជា (ផ្កានាងព្រៃ) ព្រមទាំងសម្បុរកាយ និងគ្រឿងស្លៀកពាក់ក៏ឱ្យមានពណ៌សុទ្ធតែលឿងៗ ដូចជាពណ៌ផ្កានាងព្រៃដូច្នេះផង, ព្រះបច្ចេកពុទ្ធលោកក៏ទទួលធ្វើអនុមោទនាថាៈ ‹‹ឥច្ឆិតំ បត្ថិតំ តុយ្ហំ ខិប្បមេវ សមិជ្ឈតុ›› សេចក្តីប្រាថ្នាដែលអ្នកប្រាថ្នាហើយបានតម្កល់ទុកហើយក្នុងចិត្ត ចូរឱ្យបានសម្រេចឆាប់រួសរាន់ទាន់ចិត្តដល់អ្នកចុះ (កុំបីឃ្លាតឡើយ) ហើយក៏លោកចៀសចេញពីទីនៅហោះទៅកាន់ព្រៃហិមពាន្តវិញទៅ ឯពួកជាងតម្បាញទាំងឡាយនោះលុះដល់ធ្វើកាលកិរិយាស្លាប់ទៅ ក៏បានទៅកើតជាទេវបុត្តនៅក្នុងស្ថានសួគ៌ឈ្មោះតាវត្តិង្សទាំងអស់គ្នា ជាគណៈទេវបុត្ត មានវិមាននៅជួបជុំគ្នា ឯវិមានទេវបុត្រដែលជាមេជាងតម្បាញជាធំ

ជាងគេនោះនៅចំកណ្ដាល ហើយវិមានទេវបុត្រដែលជាកូនជាងតម្បាញទាំង ៩៩៩ អង្គទៀតនោះ នៅចោមរោមជុំវិញជាបរិវារវិមាននៃទេវបុត្តជាមេជាងតម្បាញដែលធំជាគេនោះ, ឯភរិយានៃទេវបុត្រដែលជាធំជាងគេនោះ ក៏មានសម្បុរលឿង គ្រឿងប្រើ-ប្រាស់ក៏សុទ្ធតែលឿងដូចជាផ្កាននោងព្រៃទាំងអស់ ។ លុះដល់មកសាសនាព្រះពុទ្ធកស្សបៈ ទេវបុត្រទាំងឡាយនោះ ក៏ចុតិមកកើតក្នុងស្ថានមនុស្សលោក បានសាងកុសលផ្សេងៗ ជាថ្មីថែមទៀត លុះអស់អាយុទៅបានទៅកើតជាទេវបុត្ត ក្នុងទេវលោក-សួគ៌នាយទៀត លុះដល់មកសាសនាព្រះសម្មាសម្ពុទ្ធ ទ្រង់ព្រះនាមគោតមបរមគ្រូជាម្ចាស់នៃយើងនេះ ទេវបុត្តទាំងឡាយនោះក៏ចុតិមកកើតជាមនុស្សទាំងអស់គ្នា ឯទេវបុត្តជាធំជាងគេនោះមកកើតក្នុងត្រកូលក្សត្របានជាស្ដេចសោយរាជ្យ ព្រះនាមព្រះបាទមហាកបិនរាជ ឯភរិយាទេវបុត្រដែលជាធំជាងគេនោះ ក៏ចុតិមកកើតជាមនុស្សក្នុងត្រកូលព្រាហ្មណ៍ ហើយមាននាមថាអនោជា ទាំងបានជាអគ្គមហេសីនៃព្រះបាទកបិនរាជនោះផង។

ឯពួកទេវបុត្តទាំង ៩៩៩ អង្គទៀតនោះ ក៏ចុតិមកកើតក្នុងត្រកូលអមាត្យ លុះធំឡើងក៏បានធ្វើជាអមាត្យមហាកបិនរាជ

ទាំងអស់គ្នា ឯព្រះមហាក្សត្រនិងអមាត្យទាំងអស់នេះ រមែងតែនាំគ្នាស្វែងរកសាសនាដែលនាំមកនូវសេចក្តីសុខ លុះសម័យមួយ ព្រះមហាក្សត្រព្រមទាំងរាជអមាត្យទាំងអស់នោះ ហែស្តេចយាងទៅក្រសាលឧទ្យាន ក៏បានជួបនឹងនាយឈ្មួញរទេះដែលនាំទំនិញចេញពីនគរសាវត្ថីមកជួញ លុះជួបហើយទ្រង់សួរថា នាយឈ្មួញអើយ អ្នកមកពីនគរនោះ បានដឹងដំណឹងអ្វីប្លែកដែលនាំមកនូវសេចក្តីសុខដល់ត្រចៀកខ្លះដែរ? នាយឈ្មួញនោះ ក៏ក្រាបទូលថាបានដឹងខ្លះដែរ ហើយព្រះអង្គឱ្យនាយឈ្មួញថាថ្វាយទ្រង់ព្រះសណ្តាប់ នាយឈ្មួញក៏ក្រាបទូលថា:

«ពុទ្ធោ ឧប្បន្នោ លោកេ ធម្មោ ឧប្បន្នោ លោកេ សង្ឃោ ឧប្បន្នោ លោកេ» ព្រះពុទ្ធជាម្ចាស់ ត្រាស់ឡើងហើយក្នុងលោក, ព្រះធម៌កើតឡើងហើយក្នុងលោក, ព្រះសង្ឃមានឡើងហើយក្នុងលោក, ។

តែពាក្យ ៣ ម៉ាត់ ឬ ៣ បទប៉ុណ្ណោះ ព្រះមហាក្សត្រព្រមទាំងរាជអមាត្យទ្រង់ព្រះសណ្តាប់ ហើយកើតបីតិទាំង ៥ ប្រការព្រឺព្រួចសព្វព្រះកាយា ហើយព្រះអង្គបូជានាយឈ្មួញនោះ ក្នុង

ពាក្យមួយម៉ាត់ ១ សែនកហាបនណៈ ៣ ម៉ាត់ ត្រូវជា ៣ សែនកហាបណៈ, ហើយបញ្ជូននាយឈ្នួញនោះទៅបើកប្រាក់ ព្រមទាំងនាំសារទៅថ្វាយដំណឹងព្រះនាងអនោជាទេវី ជាព្រះអគ្គ-មហេសីឱ្យបានជ្រាបផង, ចំណែកព្រះអង្គនិងរាជអមាត្យទាំង ៩៩៩ នាក់នោះ ក៏ឡើងសេះបរឆ្ពោះទៅកាន់សំណាក់ព្រះសាស្តាៗ ទ្រង់ជ្រាបហើយក៏ព្រះអង្គទ្រង់យាងទៅគង់ចាំទទួលនៅទៀបឆ្នេរស្ទឹង ហើយទ្រង់បញ្ចេញនូវព្រះរស្មីទាំង ៦ ពណ៌ ភ្លឺល្អឱភាសព្រោងព្រាយក្នុងទីនោះ ។ ឯព្រះរាជាព្រមទាំងរាជ-បរិវារ លុះធ្វើគមនាការទៅត្រូវឆ្លងស្ទឹង ៣ សង្កាត់ទើបដល់ ក្នុងស្ទឹងនិមួយៗ ទំហំ ៣ គាវុតក៏មាន ទំហំធំដល់ទៅកន្លះយោជន៍ក៏មាន ទំហំធំដល់ទៅ ១ យោជន៍ក៏មាន ព្រះអង្គទ្រង់អធិដ្ឋានហើយនឹកដល់ពុទ្ធគុណ ធម្មគុណ សង្ឃគុណ រួចហើយក៏បរសេះជាន់លើខ្នងទឹកនោះៗ ក៏រឹងដូចផែនដី អាចឱ្យសេះជាន់ដើរឆ្លងកាត់ទៅបានរហូតទាំង ៣ សង្កាត់ ឥតផុងជើងសេះឡើយ។ លុះទៅដល់ហើយស្តេចក៏ចុះចាកអស្សតរ ព្រមទាំងអមាត្យជាបរិវារ ថ្វាយបង្គំព្រះអង្គហើយ ក៏គង់ស្តាប់ធម៌ទេសនា លុះចប់ហើយក៏បានសម្រេចសោតាបត្តិផលគ្រប់ៗ គ្នា ក្នុងគ្រានោះ

ឯង ។ រីឯនាយឈ្មួញរទេះ នាំដំណឹងនោះទៅក្រាបទូលព្រះនាងអនោជាៗ បានជ្រាបហើយក៏រីតតែកើតសេចក្ដីជ្រះថ្លាជាត្រៃគុណ គឺក្នុងពាក្យ ១ ម៉ាត់ព្រះនាងបូជា ៣ សែនកហាបណៈ រួមពាក្យទាំង ៣ ម៉ាត់ គឺៈ ព្រះពុទ្ធ ១ ព្រះធម៌ ១ ព្រះសង្ឃ ១ ត្រូវជា ៩ សែនកហាបណៈ បើរួមទាំងប្រាក់ព្រះរាជា ៣ សែនផង នាយឈ្មួញរទេះនោះត្រូវបាន ១២ សែនកហាបណៈ ក្នុងគ្រានោះឯង ។ ឯព្រះនាងទេវីហៅប្រពន្ធអមាត្យទាំង ៩៩៩ នាក់ មកហើយត្រូវជា ១០០០ នាក់នឹងព្រះនាង ក៏នាំគ្នាឡើងលើរាជរថតូចៗ រៀងខ្លួន បរកាត់សំដៅទៅកាន់សំណាក់ព្រះសាស្ដា លុះទៅដល់ស្ទឹងទី ១ ទី ២ ទី ៣ ដែលនៅជាសង្កាត់ៗ រាំងផ្លូវនោះហើយ ព្រះនាងទេវីក៏អធិដ្ឋាន ហើយនឹកដល់គុណព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ មានទំនងដូចគ្នានឹងព្រះរាជាហើយបរព្រះរាជរថឆ្លងកាត់ទឹកនោះទៅបានដូចគ្នា ឥតមានទទឹកស្នាមដល់កង់ព្រះរាជរថ និងជើងសេះដល់បន្តិចបន្តួចសោះឡើយ ។ លុះព្រះនាងទេវីព្រមទាំងភរិយារាជអមាត្យទាំងអស់គ្នា ចូលទៅដល់ហើយ, គ្រានោះព្រះសាស្ដា ព្រះអង្គសំដែងបាដិហារ្យបាំងបិទជិត មិនឱ្យពួកជនទាំងពីរក្រុមនេះ

មើលគ្នាឃើញឡើយ ដើម្បីកុំឱ្យកើតកាមតណ្ហាក្នុងការឃើញរូបនោះ លុះព្រះនាងអនោជាទេវីរួមទាំងភរិយាអមាត្យត្រូវជា ១000 នាក់នោះ ថ្វាយបង្គំព្រះសាស្ដាហើយអង្គុយនៅស្ដាប់ធម៌ទេសនាចប់ បានសម្រេចមគ្គផលជាព្រះអរិយបុគ្គលក្នុងព្រះពុទ្ធសាសនា, ទើបព្រះសាស្ដាស្រាយឥទ្ធិបាដិហារ្យ ឱ្យជនទាំង ២ ពួកនេះបានឃើញគ្នា ។

ឯបុគ្គលដែលបានធ្វើបុណ្យពីក្នុងគ្រាមុនទុកមក នឹងបានតម្កល់សេចក្ដីប្រាថ្នាត្រូវល្អជាមូលបណិធិទុកមាំហើយ ក៏បានផលល្អដូចន័យអធិប្បាយមកនេះឯង ។

---

# មង្គលទី ៦

**អត្តសម្មាបណិធិ ច** កិរិយាដំកល់ខ្លួនទុកដោយប្រពៃជា មង្គលដ៏ឧត្តម ។

អធិប្បាយថា: បុគ្គលដែលបានតម្កល់ខ្លួនទុកនៅក្នុងសទ្ធាគឺការជឿកម្មជឿផល ជឿគុណព្រះពុទ្ធ, ព្រះធម៌, ព្រះសង្ឃ

ជាដើម នឹងតម្កល់ខ្លួនទុកនៅក្នុងសីល ៥ សីល ៨ ឬក្នុងកម្មបថ ១០ ប្រការ ឬដំកល់ខ្លួនទុកនៅក្នុងការស្តាប់ធម៌ទេសនា ក្នុងការបរិច្ចាគទ្រព្យធ្វើទាន ក្នុងការពិចារណាបញ្ចក្ខន្ធឱ្យឃើញថា អនិច្ចំ ជារបស់មិនទៀង ទុក្ខំ ជារបស់តែងជួបប្រទះតែនឹងសេចក្តីទុក្ខ អនត្តា ជារបស់មិនមែនខ្លួនប្រាណ មិននៅក្នុងអំណាចសេចក្តីអង្វរករ ឬបង្គាប់បញ្ជាជនណាឡើយ យ៉ាងនេះជាដើមឡើងទៅហើយ ទើបលោកឱ្យឈ្មោះថា តម្កល់ខ្លួនទុកដោយប្រពៃ ។

មានសេចក្តីដំណាល ដូចរឿងព្រាហ្មណ៍ម្នាក់ជាមនុស្សមិច្ឆាទិដ្ឋិខាងក្រៅព្រះពុទ្ធសាសនា បើគាត់ឮពាក្យគេពោលថា ត្រឹមតែព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃដូច្នេះក៏មិនបាន គាត់មានចិត្តខឹងភ្លាមមួយរំពេច ព្រោះគាត់ស្អប់ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃណាស់ ប៉ុន្តែនាងព្រាហ្មណីជាភរិយាគាត់នោះ ជាមនុស្សសម្មា-ទិដ្ឋិ យល់ត្រូវល្អជ្រះថ្លាក្នុងសីលធម៌ព្រះពុទ្ធសាសនា ។ សម័យថ្ងៃមួយនោះ គាត់ប្រឹក្សានឹងភរិយាថា យើងនឹងនិមន្តពួកព្រាហ្មណ៍មកធ្វើបុណ្យក្នុងផ្ទះយើង, នាងព្រាហ្មណីជាភរិយាក៏

ព្រមតាមបំណងស្វាមីឥតទទឹងទាស់ ។ ឯព្រាហ្មណ៍ជាស្វាមីនោះនិយាយប្ដេជ្ញានឹងភរិយាថា បើកាលណាពួកព្រាហ្មណ៍ទាំងនោះមកដល់ផ្ទះយើងហើយ ចូរនាងឯងប្រយ័ត្នមាត់កុំពោលថា ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃឡើយ បើនាងឯងពោលហើយ អញនឹងកាប់សម្លាប់នាងឯងដោយដាវមិនខាន, ថាហើយក៏នាំគ្នាចាត់ចែងភោជនាហារ លុះព្រាហ្មណ៍ចូលមកអង្គុយក្នុងផ្ទះជួបជុំគ្នាហើយនឹងបរិភោគ នាងព្រាហ្មណីដែលកំពុងតែខ្វល់ខ្វាយបំរើ ស្រាប់តែចំពប់ជើងភ្លាត់មាត់ថា នមោ តស្ស ភគវតោ ដូច្នេះជាដើម ។ ពួកព្រាហ្មណ៍ឮពាក្យនេះហើយ ក៏ខឹងច្រឡោត នាំគ្នាជេរប្រទេចព្រាហ្មណ៍ជាម្ចាស់ផ្ទះ ហើយក្រោកដើរបាត់អស់ទៅ ។ ឯព្រាហ្មណ៍ជាស្វាមីក្រោធខឹងនឹងភរិយាពេកណាស់ ជេរប្រទេចផ្ដាសាដោយប្រការផ្សេងៗ ហើយចូលទៅគាល់សម្ដេចព្រះបរមសាស្ដា ទូលសួរអំពីហេតុជាគ្រឿងកំចាត់បង់នូវសេចក្ដីសោយសោក និងដេកលក់ជាសុខ ។ ទើបព្រះអង្គទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ បុគ្គលសម្លាប់នូវកិលេសគឺសេចក្ដីសៅហ្មងមានទោសៈជាដើម ដោយអរិយមគ្គញ្ញាណ

រមែងដេកលក់ជាសុខ និង មិនមានសេចក្តីសោយសោកក្នុងលោកខាងមុខ ។ ព្រាហ្មណ៍បានស្តាប់ធម្មទេសនាហើយ មានសេចក្តីជ្រះថ្លា ទូលសុំបព្វជ្ជាឧបសម្បទា ក្នុងសំណាក់ព្រះបរមសាស្តា ខំចម្រើនវិបស្សនាមិនយូរប៉ុន្មាន ក៏បានសម្រេចព្រះអរហត្តកាត់កិលេសជាសមុច្ឆេទប្បហារ ដូចវិសជ្ជនាមកនេះឯង ៕

---

# មង្គលទី ៧

**ពាហុសច្ចៈ** ការបានស្តាប់ បានរៀនចេះចាំច្រើនជាមង្គលដ៏ឧត្តម ។

អធិប្បាយថាៈ ការបានស្តាប់បានរៀនចេះចាំច្រើន នូវធម៌របស់ព្រះពុទ្ធជាម្ចាស់ ឬសាវករបស់ព្រះអង្គ ឬក៏ជនជាសប្បុរសណាមួយ ទោះជាបព្វជិតក្តី គ្រហស្ថក្តី ដែលជាអ្នកអាចទេសនាចង្អុលបង្ហាញផ្លូវសួគ៌ផ្លូវនិព្វានបាន ហៅថា ពាហុសច្ចៈ ។ បើ

ជាបុគ្គលាធិដ្ឋាន ហៅថា ពហុស្សុត ([2]) ។ ពហុសូតនេះ មាន ២ យ៉ាងគឺៈ គ្រហស្ថជាអ្នកបានសិក្សារៀនសូត្រចេះចាំច្រើន អាចញុំាងប្រយោជន៍និងសេចក្តីសុខឱ្យកើតឡើង និងអាចដោះទុក្ខទោសរបស់ខ្លួន និងអ្នកដទៃបាន ដូចជាព្រះពោធិសត្វ កាលកើតជាមហិស្សាសកុមារ ។

មានសេចក្តីដំណាលថាៈ ក្នុងអតីតកាល, កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងក្រុងពារាណសី ព្រះពោធិសត្វបានសោយព្រះជាតិ ជាព្រះរាជបុត្ររបស់ព្រះរាជាអង្គនោះ ។ ដើម្បីរង់ចាំកាលនឹងគ្រងរាជសម្បត្តិ ព្រះពោធិសត្វក៏ដកព្រះអង្គថយទៅគង់នៅក្នុងព្រៃសិន ជាមួយនឹងព្រះអនុជ ២ ព្រះអង្គ ។ លុះយាងចូលទៅជិតស្រះមួយ ព្រះពោធិសត្វស្រេកទឹក ក៏ប្រើចន្ទកុមារជាព្រះអនុជបន្ទាប់ ឱ្យទៅដងទឹកខ្ចប់នឹងស្លឹកឈូកយកមកថ្វាយ ។ តែក្នុងស្រះនោះ មានអារក្សទឹកមួយហួងហែងរក្សា ។ ចន្ទកុមារឥតពិចារណាក៏ចុះភ្លាមទៅក្នុងស្រះ ត្រូវអារក្សទឹកនោះចាប់បង្ខាំងទុកមិនឱ្យត្រឡប់មកវិញ ។ ព្រះពោធិសត្វ

---

[2] -ពាក្យ «ពហុស្សុត និង ពហុសូត» ប្រើបានទាំងពីរ ។

ដល់បាត់ចន្ទកុមារយូរពេកមិនឃើញមក ក៏ទ្រង់ប្រើសុរិយកុមារជាព្រះអនុជពៅឱ្យទៅតាម ។ អារក្សទឹកក៏ចាប់សុរិយកុមារនោះលាក់ទុកទៀត ។ លុះបាត់ព្រះអនុជទាំងពីរមិនឃើញត្រឡប់វិញ ព្រះពោធិសត្វក៏ទ្រង់យាងទៅកាន់ស្រះដោយព្រះអង្គឯងទ្រង់ពិចារណាដោយវិចារណញ្ញាណជ្រាបច្បាស់ថាៈ ប្រាកដជាមានអារក្សទឹកអាស្រ័យនៅក្នុងស្រះ ដោយទ្រង់ឃើញតែស្នាមជើងមនុស្សចុះ ឯស្នាមជើងមនុស្សឡើងមកវិញគ្មាន ទ្រង់ក៏សួរទៅអារក្សទឹកដែលចូលមកកាន់សំណាក់ព្រះអង្គថាៈ ប្អូនយើងទាំងពីរ តើអ្នកឯងចាប់ទុកឬ? អារក្សទឹកក៏ឆ្លើយតាមពិតថា ខ្ញុំបានចាប់ទុកមែន ។ ទើបព្រះពោធិសត្វត្រាស់សួរទៅទៀតថាៈ អ្នកឯងអាចចាប់មនុស្សសត្វទាំងអស់ ដែលចុះមកក្នុងស្រះនេះឥតរើសមុខ ឬក៏មានលើកលែងបុគ្គលបែបណាដែរ? លុះទ្រង់ជ្រាបថា អារក្សទឹកមិនហ៊ានចាប់បុគ្គលដែលចេះទេវធម៌ ទ្រង់ក៏សំដែងទេវធម៌នោះ ប្រាប់អារក្សទឹកក្នុងកាលនោះឯង ។ អារក្សទឹកបានស្តាប់ធម្មទេសនានេះហើយ ក៏មានសេចក្តីជ្រះថ្លា ទើបនាំព្រះរាជកុមារទាំងពីរព្រះអង្គ មកថ្វាយព្រះពោធិសត្វវិញ ។

ព្រះពោធិសត្វជាពហូសូត ទើបអាចដោះព្រះអង្គនឹងព្រះអនុជទាំងពីរឱ្យរួចអំពីអន្តរាយបាន ។

មួយទៀត បព្វជិតជាពហូសូតជាអ្នកចេះចាំព្រះពុទ្ធវចនៈច្រើន ក៏រមែងបានលាភសក្ការៈច្រើន ដូចព្រះអានន្ទត្ថេរ ។

មានសេចក្ដីដំណាលថាៈ មានព្រាហ្មណ៍ម្នាក់មានសទ្ធាចង់បូជាព្រះធម៌ ទើបចូលទៅគាល់ព្រះបរមសាស្ដាហើយទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះពុទ្ធនឹងព្រះសង្ឃ ខ្ញុំព្រះអង្គបានបូជាហើយ នៅតែព្រះធម៌មិនទាន់បានបូជានៅឡើយ តើខ្ញុំព្រះអង្គនឹងបូជាព្រះធម៌នោះក្នុងទីណា? ទើបព្រះដ៏មានព្រះភាគជាម្ចាស់តបថាៈ ម្នាលព្រាហ្មណ៍បើអ្នកចង់បូជាព្រះធម៌ ចូរបូជាចំពោះភិក្ខុជាពហូសូតចុះ, ព្រាហ្មណ៍ក៏ដើរទៅសួរភិក្ខុសង្ឃៗក៏ប្រាប់ថាៈ ព្រះអានន្ទជាពហូសូត ទើបនាំចតុប្បច្ច័យទៅបូជាព្រះអានន្ទហើយចូលទៅគាល់ព្រះទសពល ក្រាបទូលហេតុគ្រប់ប្រការ ព្រះសាស្ដាក៏ទ្រង់ប្រទានស័ព្ទសាធុការពរសរសើរធម្មបូជារបស់ព្រាហ្មណ៍ ជាអនេកប្រការ ។ ឯពួកជនដទៃទៀតក៏នាំគ្នាយកចតុប្បច្ច័យ មកបូជាព្រះអានន្ទត្ថេរ ជាប់ជានិច្ចមិនដាច់ ដោយហេតុព្រះអានន្ទជាពហូសូតនោះឯង ។

# មង្គលទី ៨

**សិប្បៈ** សេចក្ដីឆ្លៀវឆ្លាសក្នុងសិល្បសាស្ត្រវិជ្ជាការទាំងពួង ជាមង្គលដ៏ឧត្ដម ។

អធិប្បាយថា: សិប្បៈ មាន ២ យ៉ាងគឺ: អគារសិប្បៈ ១ អនាគារសិប្បៈ ១ ។ អគារសិប្បៈ គឺសិប្បៈរបស់ព្រះគ្រហស្ថអ្នកគ្រប់គ្រងផ្ទះសម្បែង, ចែកទៅមាន ២ យ៉ាងគឺ: សិប្បៈសម្រាប់បុរសមានសិក្សារៀនសូត្រសិល្បសាស្ត្រផ្សេងៗ មានអក្សរ-សាស្ត្រ គណិតសាស្ត្រ វិទ្យាសាស្ត្រជាដើម ឬក៏កិច្ចការចិញ្ចឹមជីវិតមានការជាងឈើជាងផ្ទះ ឬពាណិជកម្មជាដើម ១, សិប្បៈសម្រាប់ស្ត្រីគឺ ការរៀបចំផ្ទះសំបែងចាត់ចែងភោជនាហារជាដើម ១ ។ សេចក្ដីឆ្លៀវឆ្លាសក្នុងសិប្បៈទាំងពីរនេះជាដើម ចាត់ថាជាមង្គល ព្រោះជាហេតុនាំមកនូវលាភសក្ការៈមកឱ្យ ។ ម្យ៉ាងទៀត សិប្បៈ សូម្បីតែមួយ ដែលបុគ្គលបានរៀនយ៉ាងស្ទាត់ជំនាញហើយ រមែងញ៉ាំងឧត្ដមប្រយោជន៍ឱ្យសម្រេចបាន, សិប្បៈ សូម្បីច្រើនតែមិនស្ទាត់ជំនាញ ក៏ឥតបានការ ក្លាយទៅជាថ្នាំពិស នាំឱ្យក្ដៅក្រហាយឥតអំពើ ។ ដូចរឿងបុរសខ្វិនម្នាក់

ជាតួយ៉ាង ដែលបានយសសក្តិដោយសិប្បៈដ៏ស្ទាត់ជំនាញរបស់ខ្លួន ។

សេចក្តីដំណាលថាៈ មានបុរសខ្វិនម្នាក់ ជាអ្នកប៉ិនប្រសប់ផ្ទាត់គ្រាប់គ្រួសទម្លុះស្លឹកឈើកើតជារូបដំរី រូបសេះ ពួកក្មេងគង្វាលគោ តែងនិយាយឱ្យផ្ទាត់គ្រាប់គ្រួសទម្លុះស្លឹកជ្រៃក្រឹមមួយដើមឱ្យកើតជារូបសត្វនោះផ្សេងៗ ហើយវាឱ្យបាយទឹកបរិភោគ ។ ថ្ងៃមួយព្រះរាជាក្រុងពារាណសី ស្តេចយាងទៅក្រសាលឧទ្យាន លុះស្តេចទៅដល់ដើមជ្រៃក្រឹមនោះហើយទ្រង់ទតឃើញរូបសេះ-ដំរីជាដើម នៅលើស្លឹកឈើ ក៏ត្រាស់សួររកជនអ្នកធ្វើ ។ បុរសខ្វិននោះ ក៏ក្រាបបង្គំទូលថាៈ ខ្ញុំព្រះអង្គធ្វើ ។ ទើបទ្រង់ឱ្យនាំបុរសខ្វិននោះមកហើយត្រាស់សួរថាៈ អ្នកអាចផ្ទាត់អាចម៍ពពែ ១ នាឡិ បញ្ចូលក្នុងមាត់បុរោហិតបានទេ ព្រោះបុរោហិតនោះមាត់រឹងណាស់ លុះទ្រង់ព្រះសណ្តាប់ថា បុរសខ្វិនអាចធ្វើបាន ទ្រង់ក៏ឱ្យគេនាំបុរសខ្វិននោះចូលទៅក្នុងព្រះបរម-រាជវាំង ឱ្យអង្គុយខាងក្នុងវាំងនន ។ កាលបុរោហិតនោះហាមាត់និយាយនឹងព្រះរាជា បុរសខ្វិនក៏ផ្ទាត់អាចម៍ពពែមួយដុំចូលក្នុងមាត់ ហើយផ្ទាត់ដរាបដល់អាចម៍ពពែ ១ នាឡិ រួចហើយក៏

អង្រួនវាំងននឱ្យសញ្ញាថា: អាចម៍ពពែអស់ហើយ ។ ព្រះរាជាមានព្រះរាជឱង្ការនឹងបុរោហិតថា: លោកអាចារ្យ! ខ្ញុំមិនអាចនិយាយនឹងលោកបានទៀតទេ ព្រោះលោកអាចលេបអាចម៍ពពែ អស់ ១ នាឡិបាន, បុរោហិតក៏ខ្មាសលែងហើបមាត់និយាយតទៅទៀតបាន ។ ព្រះរាជាមានព្រះទ័យសោមនស្សនឹងបុរសខ្វិនណាស់ ទ្រង់ប្រទានខ្ញុំប្រុស-ស្រីជាច្រើន ព្រមទាំងស្រុកសួយ ៨ ទៀត ។ បុរសខ្វិនបានយសបានសក្តិនេះ មកពីសិប្បៈដ៏ស្ទាត់ជំនាញរបស់ខ្លួននោះឯង ។

ឯអនាគារសិប្បៈ បានដល់សិប្បៈរបស់ពួកបព្វជិតអ្នកមិនមានកង្វល់ដោយផ្ទះសម្បែង មានការកាត់ចីវរជាដើម តាមកិច្ចព្រះវិន័យ ។ បុគ្គលដែលឈ្លាសវៃក្នុងកិច្ចនោះ ឈ្មោះថាបាននូវមង្គលដ៏ឧត្តម ព្រោះជាហេតុបាននូវគុណ មានសេចក្តីសរសើរជាដើម ដូចព្រះអានន្ទត្ថេរ ។

មានសេចក្តីដំណាលថា: កាលថ្ងៃមួយ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ពុទ្ធដំណើរទៅកាន់ក្រុងរាជគ្រឹះ ទ្រង់បានទតឃើញខ្វង់ស្រែរបស់អ្នកដែនមគធៈមានរបៀបរៀបរយល្អ ក៏ទ្រង់ត្រាស់នឹងព្រះអានន្ទថា: ម្នាលអានន្ទ! ចូរអ្នកកាត់ចីវរខ្វង់ដូចខ្វង់ស្រែ

របស់អ្នកដែនមគធៈនេះចុះ នឹងរួចសេចក្ដីអន្តរាយអំពីចោរ ។ ព្រះអានន្ទទទួលព្រះពុទ្ធដីកាហើយ ក៏ចាត់ចែងកាត់ចីវរឱ្យជាបញ្ចក្ខន្ធដេរជ្រលក់ហើយ នាំចូលទៅថ្វាយព្រះដ៏មានព្រះភាគ ព្រះអង្គទ្រង់សរសើរជាអនេកប្បការ ។

ការឈ្លាសវៃក្នុងសិប្បៈទាំងពួង ចាត់ថាជាមង្គលដ៏ឧត្តម ព្រោះជាហេតុនាំមកនូវគុណមានបសំសាជាដើម ដូចបានអធិប្បាយមកនេះឯង ៕

---

# មង្គលទី ៩

វិនយោ ច សុសិក្ខិតោ វិន័យដែលបុគ្គលសិក្សាដោយប្រពៃហើយ ជាមង្គលដ៏ត្តម ។

អធិប្បាយថាៈ វិន័យមាន ២ យ៉ាងគឺៈ អគារិយវិន័យ វិន័យសម្រាប់ពួកគ្រហស្ថ ១, អនាគារិយវិន័យ វិន័យសម្រាប់ពួកបព្វជិត ១ ។ អគារិយវិន័យ សំដៅយកសីល ៥ សីល ៨ និងកម្មបថ ១០ ។ អនាគារិយវិន័យ សំដៅយកការប្រព្រឹត្តក្នុង

បារិសុទ្ធិសីលទាំង ៤ របស់ភិក្ខុ សិក្ខាបទ ១០ ទណ្ឌកម្ម ១០ នាសនង្គៈ ១០ សេខិយវត្ត ៧៥ និងសិក្ខាបទក្នុងលោកវជ្ជៈ ៤៩ និងក្នុងវត្តទាំងឡាយមានខន្ធកវត្តជាដើម របស់ពួកសាមណេរ ។

បុគ្គលដែលមានសេចក្ដីប្រមាទ មិនរក្សាវិន័យរបស់ខ្លួន លោកហៅថា បុគ្គលទ្រុស្តសីល តែងរងទុក្ខក្នុងអបាយជាប្រាកដ ដូចមានបាលីថាៈ ទុស្សីលោ អបាយគតោ អាហុ បុគ្គលទ្រុស្តសីល លោកពោលថា តែងទៅកាន់អបាយជាប្រាកដ ។ ឯបុគ្គលមានសីល រមែងបានទទួលនូវអានិសង្សនៃសីលរបស់ខ្លួនៗ នឹងទទួលយកនូវផលផ្សេងៗ គ្នាដូច្នេះ ៖ ការមិនសម្លាប់សត្វ រមែងមានរូបល្អ មានអាយុវែង, ការមិនលួចទ្រព្យរបស់គេ រមែងមានភោគសម្បទគង់វង់ឋិតថេរ មិនវិនាសអន្តរាយទៅដោយហេតុផ្សេងៗ មានអន្តរាយអំពីចោរជាដើម ការមិនប្រព្រឹត្តខុសក្នុងកាម រមែងបានគ្រប់គ្រងគ្រួសារដោយសុវត្ថិភាព, ការមិនពោលមុសាវាទ រមែងមានសំឡេងពីរោះ មិនត្រូវពាក្យចោទ ពោលបង្កាច់របស់អ្នកដទៃ,

ការមិនផឹកសុរានិងមេរ័យ រមែងមានសតិបញ្ញា មិនឆ្កួតលេលាផ្តេសផ្តាស ។ នេះជាផលរបស់បុគ្គលដែលរក្សាសីល ៥ ។ ម្យ៉ាងទៀត បុគ្គលអ្នកមានសីល រមែងបានទៅកើតក្នុងស្ថានសួគ៌ជាប្រាកដ ដូចនិទានអំពីឈ្មួញសំពៅទាំង ៧០០ នាក់ ។

មានរឿងដំណាលថាៈ មានពាណិជ ៧០០ នាក់ ឡើងជិះសំពៅឆ្លងកាត់សមុទ្រ ដើម្បីធ្វើពាណិជកម្ម លុះដល់ថ្ងៃគំរប់ ៧ សំពៅក៏ធ្លាយនាកណ្តាលមហាសមុទ្រ ។ ពាណិជទាំងឡាយស្តាយជីវិតខ្លាចសេចក្តីស្លាប់ នាំគ្នាក្រាបសំពះបន់ស្រន់ទេវតាដែលខ្លួនរាប់អានគ្រប់ៗ គ្នា ។ គ្រានោះ ព្រះពោធិសត្វកើតជានាយសំពៅ កាលថ្ងៃនឹងចុះសំពៅនោះ បានថ្វាយទានដល់ព្រះសង្ឃនិងទទួលរក្សាសីល ។ ព្រះពោធិសត្វនោះអង្គុយកណ្តាលសំពៅ ពិចារណានូវទាននិងសីលរបស់ខ្លួន ឥតមានសេចក្តីតក់ស្លុតឡើយ ។ ពាណិជទាំងឡាយឃើញប្លែកដូច្នោះហើយ ទើបសួរអំពីហេតុដែលមិនមានភ័យ ព្រះពោធិសត្វប្រាប់ថាដោយហេតុដែលខ្ញុំបានរក្សាសីល ។ ពាណិជទាំងនោះក៏បានសុំសីលក្នុងសំណាក់ព្រះពោធិសត្វៗ ក៏ចាត់មនុស្សជា ៧ ពួក ក្នុង ១ ពួក ១ រយនាក់ រួចទើបឱ្យសីលមួយពួកម្តងៗ ។ ពួកទី ១

ទទួលសីលហើយទឹកលិចឡើងដល់កជើង, ពួកទី ២ ត្រឹមជង្គង់, ពួកទី ៣ ត្រឹមចង្កេះ, ពួកទី ៤ ត្រឹមផ្ចិត, ពួកទី ៥ ត្រឹមដោះ, ពួកទី ៦ ត្រឹមក, ពួគទី ៧ ទឹកដល់ត្រឹមមាត់ ។ លុះឱ្យសីលរួចហើយ ព្រះពោធិសត្វក៏ស្រែកប្រកាសថាៈ សីល ៥ នេះឯងជាទីពឹងពាក់របស់អ្នករាល់គ្នា មិនមានវត្ថុដទៃជាទីពឹងឡើយ ចូរអ្នកទាំងឡាយតាំងចិត្តខ្ជាប់ក្នុងសីលចុះ ។ លុះជនទាំងនោះធ្វើកាលកិរិយាទៅបានទៅកើតក្នុងស្ថានសួគ៌ទាំងអស់គ្នា ដូចវិសជ្ជនាមកនេះឯង ៕

---

# មង្គលទី ១០

**សុភាសិតា ច យា វាចា** វាចាដែលបុគ្គលពោលដោយប្រពៃ ប្រកបដោយប្រយោជន៍ ជាមង្គលដ៏ឧត្តម ។

អធិប្បាយថាៈ វាចាដែលបុគ្គលពោលដោយប្រពៃនោះសំដៅយកវាចាទន់ផ្អែម មិនបង្អាច់បង្អិនអ្នកដទៃ ពោលពាក្យជាទីសោមនស្សរីករាយរបស់មហាជន ពោលពាក្យមិនច្រឡំទៅ

ដោយបាបមានមុសាវាទជាដើម ឬពោលកថាវត្ថុ ១០ យ៉ាងគឺ: អប្បិច្ឆកថា ពោលអំពីហេតុនាំឱ្យមានសេចក្តីប្រាថ្នាតិច ១, សន្តុដ្ឋិកថា ពោលអំពីសេចក្តីសន្តោស ១, បវិវេកកថា ពោលអំពីសេចក្តីស្ងាត់កាយស្ងាត់ចិត្ត ១, អសំសគ្គកថា ពោលអំពីការមិននៅច្រឡូកច្រឡំដោយពួក ១, វីរិយារម្ភកថា ពោលអំពីការតាំងប្រារព្ធសេចក្តីព្យាយាម ១, សីលកថា ពោលអំពីសីល ១, សមាធិកថា ពោលអំពីសមាធិ ១, បញ្ញាកថា ពោលអំពីបញ្ញា ១, វិមុត្តិកថា ពោលអំពីព្រះនិព្វាន ១, វិមុត្តិញ្ញាណទស្សនកថា ពោលអំពីសេចក្តីដឹងឃើញនូវធម៌ជាគ្រឿងរំលត់ទុក្ខ គឺព្រះនិព្វាន ១, រួមជា ១០ ។ ការពោលវាចាមិនមែនជាសុភាសិត រមែងសាបសូន្យចាកលាភសក្ការៈដែលត្រូវបាន ។ ឯការពោលវាចាជាសុភាសិតវិញ រមែងបាននូវលាភសក្ការៈនិងសេចក្តីរាប់អានយ៉ាងពេញចិត្ត ដូចព្រាហ្មណ៍ជាម្ចាស់គោឈ្មោះនន្ទិវិសាល ។

មានសេចក្តីដំណាលថា: ក្នុងអតីតកាល ព្រះពោធិសត្វសោយព្រះជាតិជាគោឈ្មោះនន្ទិវិសាល ក្នុងត្រកូលព្រាហ្មណ៍

មួយ ជាគោមានកម្លាំងខ្លាំងអស្ចារ្យ ។ ថ្ងៃមួយគោឈ្មោះនន្ទ-វិសាល មានសេចក្ដីអាណិតព្រាហ្មណ៍ម្ចាស់ ក៏មានវាចាឱ្យទៅភ្នាល់នឹងសេដ្ឋីថាៈ ខ្លួនមានគោមានកម្លាំងមុះមុត អាចអូសរទេះមួយរយពេញដោយបន្ទុកបាន ។ ព្រាហ្មណ៍ក៏មានសេចក្ដីត្រេក-អរហើយទៅភ្នាល់នឹងសេដ្ឋី ដាក់ប្រាក់ ១ ពាន់ដំឡឹង ។ កាលព្រាហ្មណ៍ដឹកគោនន្ទវិសាលទៅនឹងទឹមនូវរទេះខាងមុខ ក៏ពោលពាក្យទ្រគោះជួជាតិថា អាគោកៀច! ចូរអូសរទេះទៅ! គោឮពាក្យនោះហើយក៏អស់កម្លាំងអូសលែងរួច រលាស់នឹមចេញពីកបោលទៅ ។ ព្រាហ្មណ៍ចាញ់សេដ្ឋី តូចចិត្តណាស់ត្រឡប់ទៅវិញ ។ គោនន្ទវិសាលឃើញព្រាហ្មណ៍ព្រួយចិត្តដូច្នោះ មានសេចក្ដីអាណិត ក៏និយាយនឹងព្រាហ្មណ៍ម្ដងទៀត ឱ្យទៅភ្នាល់នឹងសេដ្ឋីដាក់ប្រាក់ពីរពាន់ដំឡឹង ហើយផ្ដាំថាៈ កុំឱ្យនិយាយពាក្យអាក្រក់ដូចមុនទៀត ។ ព្រាហ្មណ៍ក៏ធ្វើតាមដូច្នោះនៅពេលដែលដឹកគោចូលទៅទឹម ក៏ពោលពាក្យជាទីស្រឡាញ់ថា អើគោដ៏ចំរើន ចូរអ្នកអូសរទេះទៅ! គោឮសម្ដីទន់ផ្អែមនោះហើយ មានកម្លាំងខ្លាំងក្លាក្រៃលែង អាចអូសរទេះនោះបានដោយយ៉ាងធូរ ។ ព្រាហ្មណ៍មានជំនះឈ្នះសេដ្ឋីបានចំណេញ

ប្រាក់មួយពាន់ដំឡឹង ដោយការពោលពាក្យផ្អែមល្ហែមមនោះ ឯង ៕

---

# មង្គលទី ១១-១២

**មាតាបិតុឧបដ្ឋានំ** ការបម្រើមាតានិងបិតា ជាមង្គលដ៏ឧត្តម ។

អធិប្បាយថាៈ បុត្រធីតាដែលជាអ្នកកតញ្ញូកតវេទី ត្រូវផ្គត់-ផ្គង់បំរើមាតាបិតាដោយស្ថាន ៥ យ៉ាងគឺៈ ចិញ្ចឹមមាតាបិតាដោយបាយទឹកសំពត់ស្លៀកដណ្តប់ជាដើម និងដោយការគក់ច្របាច់ដោយគោរព ១, ទទួលភារៈធ្វើកិច្ចការជំនួស ១, ដំកល់ទុកវង្សត្រកូលដែលខ្ពង់ខ្ពស់ និងលើកតម្កើងវង្សត្រកូលដែលខ្សត់ខ្សោយ ១, ប្រតិបត្តិឱ្យគួរដើម្បីទទួលមត៌ក ១, កាលមាតាបិតាធ្វើកាលកិរិយាទៅ ត្រូវខ្វល់ខ្វាយធ្វើកុសលឧទ្ទិសផលជូនទៅលោក ១ ។ ម្យ៉ាងទៀត បើមាតាបិតាមិនមានសទ្ធា ដឹកនាំឱ្យមានសទ្ធាឡើង ១, មិនមានសីល ដឹកនាំឱ្យរក្សាសីល ១,

មិនមានការស្តាប់ធម៌ ដឹកនាំឱ្យស្តាប់ធម៌ ១, មិនចេះបរិច្ចាគទាន នាំឱ្យបរិច្ចាគទាន ១, មិនមានបញ្ញា នាំឱ្យមានបញ្ញា ១ ។ អ្នកដែលបម្រើមាតាបិតា រមែងបានទទួលផលានិសង្សច្រើនណាស់ ទោះត្រូវទទួលទុក្ខទោសយ៉ាងណាក្តី ក៏នឹងអាចរួចចាកទុក្ខនោះបាន ដូចនិទានដែលនឹងនាំមកសំដែង ជាឧទាហរណ៍នេះស្រាប់ ។

ក្នុងអតីតកាល ព្រះពោធិសត្វកើតជាព្រះរាជបុត្ររបស់ក្សត្រ កាលទ្រង់គង់នៅក្នុងព្រះឧទរព្រះមាតានៅឡើយ មានក្សត្រមួយអង្គ ព្រះនាម វិលោកៈ លើកទ័ពមកដណ្តើមរាជសម្បត្តិ ។ ព្រះមហាក្សត្រក៏នាំព្រះរាជទេពីភៀសព្រះអង្គទៅគង់នៅក្នុងព្រៃ លុះកាលខាងក្រោយមក ព្រះបាទវិលោកជ្រាបរឿងនោះហើយ ក៏ឱ្យគេទៅចោមចាប់ព្រះរាជាអង្គនោះបានមក ។ ឯព្រះអគ្គទេពី ក៏គង់នៅក្នុងព្រៃតែមួយព្រះអង្គឯង លុះគ្រប់ទសមាសាហើយ ព្រះនាងក៏ប្រសូតព្រះរាជឱរស មានរូបសោភាគឺពោធិសត្វនោះឯង ។ លុះព្រះពោធិសត្វមានព្រះជន្ម ១៧ ឆ្នាំ ក៏ទូលសួររកព្រះបិតា ព្រះនាងក៏ប្រាប់ហេតុគ្រប់ប្រការ ។ ទើបព្រះរាជកុមារ ទូលលាព្រះវរជននីថានឹងទៅតាមព្រះបិតា ។

កាលព្រះអង្គយាងចូលដល់នគរហើយ រាជបុរសក៏នាំព្រះបិតាទៅកាន់ឃាតដ្ឋាន ទើបព្រះអង្គលះបង់ជីវិតទានដល់ព្រះបិតាទទួលទោសានុទោសគ្រប់ប្រការ ពេជ្ឈឃាតក៏នាំព្រះរាជកុមារទៅសម្លាប់កាប់ដោយដាវ ៣ ដង ក៏មិនមុតនាំទៅឱ្យដំរីព្រេចផលកតញ្ញូដ៏ខ្លាំងក្លា ដំរីសារក៏មិនហ៊ានចូលព្រេចឡើយ ទើបនាំទៅបោះក្នុងរណ្តៅរងើកភ្លើង មានផ្កាឈូកមាសធំផុសឡើងទទួលរងព្រះកាយមិនឱ្យត្រូវចំហាយកំដៅនៃព្រះអគ្គីបានឡើយ រួចក៏នាំទៅបោះក្នុងមហាសមុទ្រទៀត នាគរាជមកទទួលយកទៅធ្វើសក្ការៈ ព្រះពោធិសត្វរួចចាកមរណភ័យ ដោយសារផលនៃការផ្គត់ផ្គង់ជីវិតរបស់ព្រះបិតានោះឯង ។

ចំណែកអ្នកដែលមិនទំនុងបំរុងមាតាបិតា ត្រឡប់ជាប្រទូសរ៉ាយលោកទៅវិញនោះ រមែងបានទទួលសេចក្តីទុក្ខវេទនាដ៏ខ្លាំងក្លាក្នុងអបាយភូមិ ក្នុងជាតិខាងមុខជាប្រាកដ ឬខ្លះមានទទួលទុក្ខទោសក្នុងបច្ចុប្បន្នជាតិនេះទាន់ហន់ក៏មាន ដូចនិទានរឿងមិត្តវិន្ទុកកុមារតទៅនេះ ៖

មិត្តវិន្ទុកកុមារនោះ ជាបុត្រជាទីស្រឡាញ់នៃត្រកូលសេដ្ឋីមួយ លុះបិតាស្លាប់ចោលទៅ ថ្ងៃមួយក៏និយាយលាមាតាថានឹង

ទៅជួញសំពៅ មាតាក៏ឱបចាប់ដៃកូនឃាត់មិនឱ្យទៅ ដោយសេចក្ដីអាណិតស្រឡាញ់កូន ។ មិត្តវិន្ទុកកុមារមិនស្ដាប់ ទើបរលាស់ដៃមាតាដែលចាប់ឱបខ្លួនចេញ ទះតប់ច្រានដួលផ្ដាប់ផ្ងារ ហើយលោតរំលងរត់ឡើងសំពៅទៅ ដោយអំណាចដែលប្រទូស្ដចំពោះអ្នកមានគុណនោះ សំពៅបើកដល់ពាក់កណ្ដាលសមុទ្រ ក៏កឿងនឹងថ្កល់ដោយឥតហេតុ ។ នាយសំពៅក៏ធ្វើស្លាកឱ្យចាប់គ្រប់គ្នា ។ សលាកកាឡកិណ្ណីក៏ធ្លាក់មកលើដៃមិត្ត-វិន្ទុកកុមារ គ្រប់ទាំង ៣ ដង ទើបនាយសំពៅបណ្ដេញមិត្តវិន្ទុក-កុមារ ឱ្យចុះចាកសំពៅឡើងពោងពាយ ហើយបណ្ដែតចោលក្នុងមហាសមុទ្រនោះទៅ ឯសំពៅក៏បាត់កឿង ។ មិត្តវិន្ទុកកុមារក៏រណ្ដែតទៅដល់កោះមួយ កោះនោះគឺជាឧស្សទនរក ពួកសត្វនរកជាច្រើនកំពុងរងទុក្ខទោសនៅទីនោះ ។ មិត្តវិន្ទុកកុមារដល់កោះនោះហើយ ក៏កើតសេចក្ដីត្រេកអរនឹកក្នុងចិត្តថាៈ នគរនេះសប្បាយថ្កុំថ្កើងរុងរឿងណាស់ អញនឹងបានជាស្ដេចសោយរាជ្យនៅនគរនេះ ។ លុះដើរបន្តិចទៅបានឃើញសត្វនរកមួយកំពុងរងទុក្ខវេទនាទូលកងចក្រ វិលខ្ទាល់បំបែកអំបែងក្បាល មានឈាមហូរស្រោចពេញខ្លួន ស្រែកយំថ្ងូរយ៉ាងខ្លាំងៗ ដោយ

ទោសនៃការប្រហារទះតប់អ្នកមានគុណ ក៏បណ្ដាលឱ្យមិត្តវិន្ទុក-កុមារឃើញសត្វនរកនោះហើយយល់ថា ជាមនុស្សអ្នកមានបុណ្យមានយសសក្តិ ប្រដាប់ដោយមកុដលើក្បាល ឃើញឈាមដែលហូរស្រោចទាំងខ្លួន យល់ថាជាសង្វារមានពន្លឺភ្លឺពណ្ណរាយពេកណាស់, ឮសម្លេងដែលសត្វនរកនោះទ្រហោយំក៏យល់ថាជាសំឡេងច្រៀងពីរោះពន់ពេក ទើបចូលទៅជិតសត្វនរកនោះហើយ អង្វរសុំគ្រឿងអាភរណៈទាំងនោះមកនឹងពាក់កំសាន្តលេងសប្បាយ ។ សត្វនរកនោះ ក៏មានសេចក្ដីត្រេកអរណាស់ ដឹងថាបាបរបស់ខ្លួនអស់ហើយ ទើបមានមនុស្សដែលប្រទូស្តចំពោះមាតាដូចខ្លួនដែរ មកទទួលរងទោសជំនួសខ្លួន ក៏លើកកង់ចក្រនោះបំពាក់លើក្បាលមិត្តវិន្ទុកៈ ។ កង់ចក្រក៏វិលខ្វាល់ខ្វារបំបែងក្បាលមិត្តវិន្ទុកៈហូរឈាមសស្រាក់ ។ មិត្តវិន្ទុកៈស្រែកទ្រហោយំ រងទុក្ខវេទនាជាយូរអង្វែងក្នុងឧស្សទនរកនោះព្រោះការប្រទូស្តចំពោះមាតានោះឯង ។ ព្រោះហេតុនោះ ការផ្គត់ផ្គង់ទំនុកបម្រុងបម្រើមាតាបិតា រមែងនាំមកនូវសេចក្ដីសុខនិងសេចក្ដីចម្រើនក្នុងលោកនេះនិងលោកនាយ ទើបលោកចាត់ជាមង្គលដ៏ឧត្តម ដោយប្រការដូច្នេះឯង ៕

# មង្គលទី ១៣

បុត្តទារស្ស សង្គហោ ការសង្គ្រោះចំពោះបុត្រនិងភរិយា ជាមង្គលដ៏ឧត្តម ។

អធិប្បាយថា: កិច្ចដែលមាតាបិតាត្រូវសង្គ្រោះបុត្រនោះ ត្រូវសង្គ្រោះដោយស្ថាន ៥ យ៉ាងគឺ: ១-ប្រដៅហាមឃាត់បុត្រ-ធីតាមិនឱ្យធ្វើអំពើអាក្រក់ មានសម្លាប់សត្វជាដើម, ២-ដឹកនាំបុត្រធីតាឱ្យធ្វើអំពើល្អ មានការឱ្យទានរក្សាសីលជាដើម, ៣-ញុំាងបុត្រធីតា ឱ្យសិក្សារៀនសូត្រមន្តវិជ្ជាផ្សេងៗ តាមសម័យនិយម, ៤-រៀបចំផ្សំផ្គុំឱ្យមានស្វាមី-ភរិយា មានត្រកូលស្មើគ្នា, ៥-ចែកចាយទ្រព្យសម្បត្តិដល់បុត្រធីតាក្នុងសម័យ ២ យ៉ាងគឺ: និច្ចសម័យត្រូវចែកឱ្យបន្តិចៗ ជានិច្ចក្នុងកាលដែលកូននៅតូចៗ កំពុងសិក្សារៀនសូត្រ ១, កាលសម័យ ត្រូវឱ្យក្នុងកាលដែលកូនធ្វើកាលកិរិយាទៅ គឺធ្វើបុណ្យឧទ្ទិសជូនផលទៅឱ្យ ឬក្នុងកាលដែលកូនមានគូរស្រេករហើយ បំរុងនឹងបែកចេញអំពីខ្លួន ១ ។ បុត្រនោះមាន ៣ ពួកគឺ: អតិជាតបុត្ត បុត្រជាន់ខ្ពស់ មាននិស្ស័យវាសនាប្រសើរជាងមាតាបិតា អាចដឹកនាំ

មាតាបិតាជាអ្នកកំណាញ់ស្វិតស្វាញឱ្យចេះធ្វើទាន នាំមាតាបិតាដែលជាអ្នកទ្រុស្តសីលឱ្យរក្សាសីល នាំមាតាបិតាដែលល្ងង់ខ្លៅឱ្យចេះដឹងមានបញ្ញាស្គាល់ទោសគុណ បាបបុណ្យជាដើម ១, អនុជាតបុត្ត បុត្រជាន់មធ្យម មាននិស្ស័យវាសនាស្មើនឹងមាតាបិតា លុះក្នុងអំណាចនៃការទូន្មានប្រៀនប្រដៅ និងការដឹកនាំនៃមាតាបិតា ១, អវជាតបុត្ត បុត្រជាន់ទាបជាបុត្រគំរក់ មិនលុះក្នុងដំបូន្មានប្រៀនប្រដៅនៃមាតាបិតា ១ ។ បុត្រទាំង ៣ ពួកនេះ គួរមាតាបិតាសង្គ្រោះដោយស្ថាន ៥ យ៉ាងនោះឯង ។ ឯភរិយាមាន៧ ពួកគឺៈ អយ្យាភរិយា ភរិយាវាតអំណាចសង្កត់សង្កិនស្វាមីដូចជាម្ចាស់ ១, វធកាភរិយា ភរិយាបៀតបៀនធ្វើទុក្ខស្វាមីដូចជាអ្នកសម្លាប់ ១, ចោរីភរិយា ភរិយាដូចជាចោរលួចទ្រព្យរបស់ស្វាមី១, មាតាភរិយា ភរិយាដែលផ្គត់ផ្គង់ស្វាមីដូចមាតា១, ភគិនិភរិយា ភរិយាដែលចេះទំនុកបំរុងនិងចិត្តពិតត្រង់ស្មោះសរចំពោះស្វាមីដូចជាប្អូនស្រី ១, ទាសីភរិយា ភរិយាដែលគោរពប្រតិបត្តិស្វាមីដូចជាទាសី ១, សខីភរិយា ភរិយាដែលប្រតិបត្តិកោតខ្លាចចិត្តស្វាមី ស្មោះត្រង់និងមិនវៀច

វេរ ដូចជាមិត្រសម្លាញ់ ។ ភរិយាទាំង ៧ ពួកនេះ គួរស្វាមីសង្គ្រោះដោយស្ថាន ៥ យ៉ាងគឺៈ ពោលសំដីពីរោះផ្អែមល្ហែមទន់ភ្លន់ ដោយការរាប់អានដ៏ស្មោះចំពោះភរិយា ១, មិនមើលងាយភរិយាធ្វើទុក្ខបុកម្នេញដូចជាទាសី ១, មិនប្រព្រឹត្តក្បត់ចិត្តភរិយា ១, ផ្គត់ផ្គង់ផ្គាប់ចិត្តដោយគ្រឿងតែងតួគ្រប់ប្រដាប់ ១, ប្រគល់គ្រឿងឥស្សរិយយសដាច់មុខជាមេផ្ទះ ១ ។ បើបុគ្គលណាបានសង្គ្រោះបុត្រនិងភរិយាដោយស្ថាន ដូចបានរៀបរាប់មកហើយនេះ រមែងតែងបានគ្រប់គ្រងគ្រួសារសោយសុខសួស្តីឥតមានទាស់ទែងខ្វែងគំនិតគ្នា រហូតដល់ទីបំផុតជីវិតរៀងខ្លួនទាំងបានសេចក្តីសរសើរអំពីជនជាបណ្ឌិតទាំងឡាយ សូម្បីពួកទេវតា ក៏សរសើរមិនខាន និងបានជាទីគោរពរាប់អាន នៃពួកមនុស្សនិងទេវតាទាំងឡាយ មានព្រះឥន្ទ្រាធិរាជជាដើម ដូចមាននិទានជាតួយ៉ាង ដែលនឹងសំដែងតទៅនេះថាៈ មានកាលមួយថ្ងៃ សម្តេចព្រះឥន្ទ្រាធិរាជ ទ្រង់គង់លើវេជយ័ន្តរថ យាងទៅក្រសាលឧទ្យាន ។ មុននឹងស្តេចយាងទៅ ព្រះអង្គបានលើកហត្ថនមស្សការទិសទាំង ១០ សិន ។ មាតលីទេវបុត្រជាសារថី បានឃើញដូច្នោះ ក៏មានសេចក្តីសង្ស័យ ទើបក្រាបបង្គំ

ទូលសួររឿងនោះនឹងព្រះអង្គ ទើបព្រះអង្គទ្រង់ត្រាស់ថាៈ ‹‹ម្នាលមាតលី! បុគ្គលណាជាអ្នកមានសីល គោរពប្រតិបត្តិមាតាបិតា សង្គ្រោះបុត្រ-ភរិយាដោយធម៌, យើងថ្វាយបង្គំនូវបុគ្គលនោះ›› ។ មាតលីទេវបុត្រដឹងរឿងនេះហើយ ក៏ថ្វាយបង្គំដូចព្រះឥន្ទ្រាធិរាជដែរ ។ ដូច្នេះឃើញថាការសង្គ្រោះបុត្រ និងភរិយា ត្រឹមត្រូវតាមស្ថានការណ៍ ដែលបានពណ៌នាមកខាងដើម ឈ្មោះថាជាមង្គល ព្រោះជាហេតុនាំសេចក្ដីសុខ-ចំរើនមកប្រគល់ឱ្យបុគ្គលនោះៗ តែងនឹងបានទទួលនូវគុណមានសេចក្ដីសរសើរ គោរពរាប់អានអំពីជនដទៃៗ ដូចសេចក្ដីដែលបានអធិប្បាយមកនេះឯង ៕

---

# មង្គលទី ១៤

អនាកុលា ច កម្មន្តា ការងារមិនច្របូកច្របល់ គឺជាការងារ ដាច់ស្រេច ជាមង្គលដ៏ឧត្តម ។

អធិប្បាយថាៈ ក្នុងមង្គលនេះ លោកសំដៅយកសេចក្ដីព្យាយាមធ្វើការងារទាំងពួង ដោយម៉ឺងម៉ាត់ដរាបដល់ទីបំផុត មិនខ្ជិលច្រអូសបោះបង់ចោលការងារ ដែលកំពុងធ្វើមិនទាន់សម្រេចនោះឡើយ ដោយមិនមានសេចក្ដីធុញទ្រាន់សេចក្ដីប្រកាន់ខ្លួនថា ព្រឹកពេក, ល្ងាចពេក, រងាពេក, ក្ដៅពេក, ស្រេកពេក, ឃ្លានពេក និងធ្វើការងារទាំងពួងមិនកើត ។ មែនពិត កិច្ចការទាំងអស់ក្នុងលោក ដែលនឹងសម្រេចទៅបាន ក៏ព្រោះអាស្រ័យព្យាយាមជាហេតុ ។ ការរៀនសូត្រ បើប្រាសចាកព្យាយាមហើយ ធ្វើម្ដេចឡើយនឹងបានចេះដឹង នឹងបានចម្លងខ្លួនឱ្យផុតពីមូឡ្ហភាពទៅកាន់បណ្ឌិតភាពបាន បើល្ងង់ឥតវិជ្ជាហើយធ្វើម្ដេចនឹងរកសេចក្ដីសុខឃើញ សមដូចព្រះដ៏មានព្រះភាគត្រាស់ថាៈ ‹‹វីរិយេន ទុក្ខមច្ចេតិ គេអាចឆ្លងសេចក្ដីទុក្ខបាន

ដោយព្យាយាម›› ។ ការស្វែងរកទ្រព្យសម្បត្តិ បើប្រាសចាកព្យាយាមហើយ ធ្វើម្ដេចធនធានមានមាសប្រាក់ជាដើម នឹងរត់ចូលមកងាយៗ បាន ធ្វើម្ដេចនឹងរួចចាកទុគ្គតភាពទៅកាន់សុគតភាពបាន លុះតែប្រឹងប្រែងយ៉ាងពេញទំហឹងឥតសំចៃកម្លាំង មិនស្គាល់យប់ស្គាល់ថ្ងៃ ទើបឃើញស្រមោលនៃទ្រព្យខ្លះសមដូចពុទ្ធភាសិតថាៈ ‹‹ឧដ្ឋាតា វិន្ទតេ ធនំ អ្នកមានព្យាយាមប្រឹងប្រែង រមែងបាននូវទ្រព្យ››។ ការស្វែងរកធម៌ជាទីពឹងពាក់ពំនាក់អាស្រ័យក្នុងលោកខាងមុខ ក៏ត្រូវប្រកបដោយព្យាយាមដែរ សូម្បីព្រះបរមគ្រូជាម្ចាស់ ដែលនឹងបានត្រាស់ដឹងសព្វញ្ញុតញ្ញាណ ល្បីព្រះនាមថាជាសព្វញ្ញុពុទ្ធក្នុងលោកទូទៅបាន ក៏ដោយសារព្រះអង្គតម្កល់ព្យាយាមយ៉ាងតឹងរ៉ឹងបំផុត ក្នុងការដែលព្រះអង្គកំពុងធ្វើទុក្ករកិរិយា ដែលហៅថា មហាបធានគឺព្យាយាមប្រកបដោយអង្គ ៤ ថាៈ

កាមំ តចោ ចហារូ ច អដ្ឋិ ច អវសិស្សតុ
អវសុស្សតុ មេ សរីរេ សព្វន្តំ មំ សលោហិតំ ។

សូមឱ្យតែស្បែក, សរសៃ និងឆ្អឹងរបស់អាត្មាអញសល់នៅបានហើយ, ឯសាច់និងឈាមទាំងអស់ក្នុងសរីរៈរបស់អាត្មា ក៏សូមឱ្យជ្រួញស្វិតរីងខះអស់ទៅចុះ ។

ម្យ៉ាងទៀត បុគ្គលអ្នកមានព្យាយាមមិនបន្ធូរបន្ថយ សូម្បីក្នុងកិច្ចការមិនជាទីសង្ឃឹមកក់ក្ដៅក៏ដោយ រមែងបានជាទីគោរពរាប់អាន ជាទីប្រោសប្រាណ នៃពួកទេវតាទាំងឡាយក្នុងបច្ចុប្បន្នជាតិនេះ ដូចជាព្រះមហាជនកពោធិសត្វជាដើម ។

ក្នុងកាលដែលកន្លងទៅហើយ ព្រះពោធិសត្វទ្រង់យោនយកកំណើតឧប្បត្តិកើតឡើងក្នុងខត្តិយត្រកូលមួយ មាននាមថាព្រះមហាជនកៈ ។ នៅវេលាដែលព្រះអង្គស្ដេចយាងមកដើម្បីទទួលរាជសម្បត្តិ ទ្រង់បានធ្វើរាជដំណើរតាមសំពៅ លុះមកដល់ពាក់កណ្ដាលមហាសមុទ្រសំពៅក៏ធ្លាយ អន្តរាយជីវិតអ្នកសំពៅទាំងអស់ បានជាចំណីនៃឆ្លាមមករនិងក្រពើទាំងឡាយ ។ ឯព្រះពោធិសត្វទ្រង់ឡើងលើដងក្ដោងសំពៅ ហើយលោតផុតពីសេចក្ដីអន្តរាយអំពីសត្វសាហាវទាំងនោះ ហើយព្រះអង្គខំព្យាយាមហែលទឹកប្រែ ឆ្លងមហាសមុទ្រទាំងយប់ទាំងថ្ងៃឥតបង្អង់ ទោះបីសម្លឹងរកកោះរកត្រើយមិនឃើញក៏ដោយ អស់ ៧

ថ្ងៃ ទើបកើតសេចក្ដីអស្ចារ្យក្រៅក្រហាយដល់ទេវតាដែលនៅរក្សាសមុទ្រ ។ ទេវតានោះ ក៏មកកាន់សំណាក់ព្រះពោធិសត្វមុននឹងសង្គ្រោះជីវិតព្រះអង្គ ក៏សួរអំពីសេចក្ដីព្យាយាមឥតប្រយោជន៍នោះចំពោះព្រះពោធិសត្វ ។ ទើបព្រះអង្គទ្រង់ត្រាស់ថា:

វាយមេថេវ បុរិសោ យាវ អត្ថស្ស និប្ផទា

‹‹កើតមកជាកូនប្រុស ត្រូវតែព្យាយាម ដរាបដល់សម្រេចប្រយោជន៍›› ។ ទេវតាក៏មានចិត្តសោមនស្សចំពោះវាចាព្រះពោធិសត្វ ក៏នាំព្រះអង្គទៅដាក់ដល់សកដ្ឋានគឺទីលំនៅរបស់ព្រះអង្គហោង ។ សេចក្ដីព្យាយាម ក្នុងកិច្ចការគ្រប់ជំពូកមិនបន្ធូរបន្ថយ ដំអក់ទម្រន់ធ្វើទាល់តែសម្រេច មិនបណ្ដាក់បង្អង់ថាទុកស្អែកទុកថ្ងៃក្រោយ ឬឥតមានសេចក្ដីធុញទ្រាន់នឿយណាយរសាយចិត្តចាកការងារ ចាត់ថាជាមង្គល ព្រោះជាហេតុញុំាងប្រយោជន៍ទាំងពួងឱ្យសម្រេចបាន ដូចអធិប្បាយមកនេះឯង ៕

# មង្គលទី ១៨

## ទានំ ការឱ្យទាន ជាមង្គលដ៏ឧត្តម ។

អធិប្បាយថាៈ ទានមានច្រើនប្រការណាស់, ប៉ុន្តែប្រការដែលសំខាន់ជាងគេមាន ២ គឺៈ អាមិសទាន ១, ធម្មទាន ១ ។

ការចែករំលែកបច្ច័យទាំង ៤ គឺៈ គ្រឿងស្លៀកដណ្ដប់, គ្រឿងបរិភោគ, គ្រឿងទីសំណាក់អាស្រ័យ និងថ្នាំសម្រាប់ព្យាបាលរោគ ប្រគេនសមណៈព្រាហ្មណ៍អ្នកមានសីល ឬឱ្យដល់បរជនណាមួយ ហៅថា អាមិសទាន ។ ការឃោសនាពន្យល់មហាជនឱ្យស្គាល់ច្បាស់ថា ធម៌នេះជាកុសល, ធម៌នេះជាអកុសល, ធម៌នេះនាំឱ្យមានទោស, ធម៌នេះមិនមានទោស, ធម៌នេះពួកអ្នកប្រាជ្ញតែងតិះដៀល, ធម៌នេះអ្នកប្រាជ្ញសរសើរ, ធម៌នេះប្រព្រឹត្តទៅដើម្បីសេចក្ដីសាបសូន្យ, ដើម្បីសេចក្ដីទុក្ខ, ធម៌នេះប្រព្រឹត្តទៅដើម្បីប្រយោជន៍, ដើម្បីសេចក្ដីចម្រើន, ដើម្បីសេចក្ដីសុខ ហៅថាធម្មទាន ។ បណ្ដាទានទាំង ២ ប្រការនេះ ធម្មទានប្រសើរក្រៃលែងជាងអាមិសទាន ។ ព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់ទេសនាថាៈ សព្វទានំ ធម្មទានំ ជិនាតិ

‹‹ធម្មទានឈ្នះទានទាំងអស់›› ។ សេចក្ដីអធិប្បាយថាៈ ប្រសិនបើទាយក អាចប្រគេនចីវរដ៏មានសាច់ម៉ដ្ឋល្អដូចបណ្ដូលចេកដល់ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះខីណាស្រពទាំងឡាយ ដែលគង់កកកុញក្នុងផ្ទៃចក្រវាឡ រហូតដល់ទល់ព្រហ្មលោកក៏ដោយ ការអនុមោទនា ដោយគាថា ៤ បាទរបស់លោកទាំងនោះ ក្នុងសមាគមនោះប្រសើរជាង ។ ការធ្វើចីវរទាននោះ មានផលមិនដល់មួយចំណិតអំពីចំណែក ១៦ នៃអនុមោទនាគាថានោះផង ។ ការសម្ដែងធម៌ក្ដី ការបង្រៀនធម៌ក្ដី ការស្ដាប់ធម៌ក្ដី រមែងបានបំណាច់ធំយ៉ាងនេះ ។ បិណ្ឌបាតទានដ៏ប្រសើរដែលទាយកដាក់បំពេញបាត្រប្រគេនដោយគោរពក្ដី ភេសជ្ជៈទាំងឡាយមានទឹកដោះនិងប្រេងជាដើមក្ដី សេនាសនទានដ៏ប្រសើរដូចជាមហាវិហាររបស់អនាថបិណ្ឌិកសេដ្ឋី ឬលោហប្រាសាទរបស់មហាឧបាសិកាឈ្មោះវិសាខាក្ដី ក៏ឈ្មោះថាមិនប្រសើរដល់ធម្មទានឡើយ ។ ធម្មទាននេះដោយហោចទៅ សូម្បីតែការអនុមោទនាដោយគាថា ប្រកបដោយបាទ ៤ ប៉ុណ្ណោះ រមែងប្រសើរជាងអាមិសទាន ។ ព្រោះហេតុអ្វី? ព្រោះថា សត្វទាំងឡាយ ដែលនឹងធ្វើបុញ្ញកម្មទាំងនេះទៅបានអាស្រ័យការស្ដាប់

ធម៌ជាហេតុ, មិនមែនមិនស្តាប់ធម៌ហើយ ធ្វើបុញ្ញកម្មទាំងនេះកើតឡើយ ។ ប្រសិនបើសត្វទាំងនេះមិនបានស្តាប់ធម៌ទេ ម្ល៉េះមិនអាចនឹងឱ្យនូវបបរមួយបោយ ឬបាយមួយវែកបានឡើយ ។ មួយវិញទៀត លើកលែងព្រះពុទ្ធនិងព្រះបច្ចេកពុទ្ធចេញ ព្រះអរហន្តទាំងឡាយ មានព្រះសារីបុត្តត្ថេរជាដើម ដែលមានបញ្ញាលើសលប់អាចរាប់ដំណក់ទឹកភ្លៀង ដែលបង្អុរធ្លាក់ចុះអស់កប្បទាំងមូលបាន ក៏មិនអាចលុះមគ្គផលមានសោតាបត្តិមគ្គជាដើមតាមធម្មតារបស់ខ្លួនបានដែរ លុះតែបានស្តាប់ធម៌របស់ព្រះថេរៈទាំងឡាយមានព្រះអស្សជិតត្ថេរជាដើម ទើបធ្វើឱ្យជាក់ច្បាស់នូវសោតាបត្តិផលបាន ទាំងធ្វើឱ្យជាក់ច្បាស់នូវសាវកបារមីញាណបាន ព្រោះធម្មទេសនារបស់ព្រះបរមសាស្តាជាម្ចាស់ ។ ដោយហេតុទាំងអម្បាលនេះ ហើយធម្មទានទើបឱ្យឈ្មោះថាជាទានប្រសើរក្រៃលែង ។ ព្រោះហេតុនោះ បានជាព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថាៈ សព្វទានំ ធម្មទានំ ជិនាតិ ‹‹ធម្មទានឈ្នះទានទាំងពួង›› ។

ទាយកអ្នកធ្វើទានរមែងបានទទួលអានិសង្ស ៥ យ៉ាងគឺៈ

១-រមែងបានជាទីស្រឡាញ់ពេញចិត្តនៃជនច្រើនរូប

២-មនុស្សល្អតែងរាប់រក

៣-កិត្តិស័ព្ទពីរោះល្បីខ្ចរខ្ចាយទៅ

៤-បើចូលទៅកាន់ចំណោមណាមួយ ជាអ្នកក្លៀវក្លា មិនអឹមអៀម

៥-លុះរំលាយរាងកាយនេះទៅ តែងទៅកើតក្នុងសុគតិភព ។

ដោយហេតុនេះ ការឱ្យទានទើបព្រះដ៏មានបុណ្យទ្រង់ត្រាស់ថាជាមង្គល ព្រោះជាហេតុនៃសេចក្តីចំរើន និងសេចក្តីសុខក្នុងលោកនេះ និងលោកខាងមុខប្រាកដជាក់ស្តែង ដូចបានអធិប្បាយមកនេះឯង ។

---

# មង្គលទី ១៦

## ធម្មចរិយា ការប្រព្រឹត្តនូវធម៌ ជាមង្គលដ៏ឧត្តម ។

អធិប្បាយថាៈ ការប្រព្រឹត្តនូវធម៌ក្នុងទីនេះ សំដៅយកការប្រព្រឹត្តក្នុងកុសលកម្មបថទាំង ១០ យ៉ាង ។ ការប្រព្រឹត្តធម៌នោះឈ្មោះថាជាមង្គល ព្រោះជាហេតុនាំឱ្យបានកើតក្នុងសុគតិ-ភពជាដើម ។ ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ទុកក្នុងសាលេយ្យកសូត្រ ត្រង់បញ្ចមវគ្គ នៃមូលបណ្ណាសកៈថា ‹‹សត្វពួកខ្លះក្នុងលោកនេះ បានទៅកាន់សុគតិសួគ៌ទេវលោក ក្រោយអំពីកាលកិរិយា ព្រោះតែហេតុ នៃការប្រព្រឹត្តធម៌នេះឯង›› ។ ការប្រព្រឹត្តធម៌នេះ ដោយកាយមាន ៣ យ៉ាងគឺៈ មិនបៀតបៀនផ្តាច់ផ្តិលជីវិតសត្វ ១, មិនលួចទ្រព្យសម្បត្តិរបស់បរជន ១, មិនប្រព្រឹត្តខុសក្នុងកាមទាំងឡាយ១ ។ ដោយវាចាមាន ៤ យ៉ាងគឺៈ មិនពោលមុសាវាទ ១, មិនពោលចាក់ដោត១, មិនពោលពាក្យអាក្រក់ជួជាតិ ឬពាក្យអាសគ្រាម ១, មិនពោលពាក្យរោយរាយអសារឥតការណ៍ ឥតប្រយោជន៍ ១ ។ ដោយចិត្តមាន ៣ យ៉ាងគឺៈ មិនលោភទ្រព្យរបស់អ្នកដទៃ ១, មិន

ព្យាបាទគេ ១, មានទិដ្ឋិយល់ត្រូវ ១ ។ អ្នកប្រព្រឹត្តធម៌ប្រាថ្នាចង់កើតក្នុងត្រកូលខត្តិយមហាសាលក៏បាន, ព្រាហ្មណមហាសាលក៏បាន, គហបតីមហាសាលក៏បាន, ក្នុងទេវលោកជាន់ចាតុម្មហារាជិកាក៏បាន, ជាន់តាវត្តិង្សក៏បាន, ជាន់យាមាក៏បាន, ជាន់តុសិតក៏បាន, ជាន់និម្មានរតីក៏បាន, ជាន់បរនិម្មិតសវត្តីក៏បាន, ក្នុងព្រហ្មលោកទាំង ១៦ ជាន់ ជាន់ណាមួយក៏បាន ។ មួយវិញទៀត អ្នកប្រព្រឹត្តធម៌ ប្រាថ្នាចង់ធ្វើឱ្យជាក់ច្បាស់នូវចេតោវិមុត្តិ និង បញ្ញាវិមុត្តិ ជាហេតុអស់ទៅនៃអាសវធម៌ក៏សម្រេចតាមបំណង ។

អ្នកប្រព្រឹត្តធម៌ រមែងបាននៅជាសុខក្នុងលោកនេះ និងលោកខាងមុខ ទាំងបានជាទីពេញចិត្តនៃមនុស្សនិងទេវតា ដូចមានរឿងធម្មិកឧបាសកជាដើមជាឧទាហរណ៍ តទៅៈ

ធម្មិកឧបាសកជាអ្នកប្រព្រឹត្តធម៌ មានសីល មានកល្យាណធម៌ ត្រេកអរក្នុងការធ្វើទាន បានកសាងកុសលជាច្រើន ក្នុងព្រះពុទ្ធសាសនា ។ មុនពេលលោកនឹងទទួលមរណភាព កូនចៅបាននិមន្តព្រះសង្ឃមកស្វាធ្យាយសតិបដ្ឋានសូត្រ ។ ក្នុងឱកាសដែលលោកកំពុងផ្ទង់ស្មារតីស្តាប់ព្រះសូត្រ ស្រាប់តែមាន

ទេវតាមកពីទេវលោកទាំង ៦ ជាន់ តាក់តែងរាជរថល្អវិសេស ភ្លឺចិញ្ចែងចិញ្ចាច ទឹមដោយសេះសន្ធព ១០០០ៗ ឋិតនៅលើអាកាសរង់ចាំទទួលឧបាសក ហើយស្រែកអញ្ជើញលោក ឱ្យឡើងទៅឋិតនៅក្នុងរថរបស់ខ្លួនៗ ។ ឧបាសកបានក្រឡេកឃើញទេវតាទាំងនោះ ផ្ទាល់មំសចក្ខុរបស់ខ្លួន នឹងបានឮសម្លេងប្រត្យក្សដល់ត្រចៀក ហើយក៏ស្រែកប្រាប់ទៅវិញថា: ចូររង់ចាំសិន ទំរាំស្តាប់ធម៌ចប់ ។ រួចហើយឧបាសកឡើងទៅឋិតនៅក្នុងរថរបស់ទេវតា ដែលមកពីឋានតុសិត ក្រោយអំពីកាលកិរិយារបស់ខ្លួន បានសោយទិព្វសម្បត្តិជាសុខក្រៃលែងក្នុងទេវលោកនោះឯង ។

ការប្រព្រឹត្តធម៌ ចាត់ជាមង្គលអាស្រ័យហេតុដូចបានអធិប្បាយមកនេះឯង ៕

# មង្គលទី ១៧

ញាតកានញ្ច សង្គហោ ការសង្គ្រោះញាតិទាំងឡាយជាមង្គលដ៏ឧត្តម ។

អធិប្បាយថាៈ ជនដែលបុគ្គលគួរស្គាល់ ហៅថាញាតិ ។ ញាតិនោះ រាប់តាំងពីដូនតាទី ៧ ខាងមាតានិងខាងបិតាចុះមក ។ ការជួយសង្គ្រោះទុក្ខក្រុមញាតិដែលកំពុងសាបសូន្យហិនហោចចាកទ្រព្យសម្បត្តិ ដោយការផ្ដល់ទ្រព្យសម្បត្តិឱ្យក្រុមញាតិដែលកំពុងតែឈឺចាប់រ៉ាំរ៉ៃ ដោយការជួយអភិបាលរក្សា រោគាព្យាធិនោះជាដើមឈ្មោះថា ការសង្គ្រោះញាតិ ។ ការសង្គ្រោះញាតិនោះ ព្រះបរមគ្រូជាម្ចាស់ត្រាស់ថាជាមង្គល ព្រោះជាហេតុបាននូវគុណវិសេសក្នុងជាតិខាងមុខផង ជួនកាលបានទៅកាន់ឋានសួគ៌ទាំងបច្ចុប្បន្នជាតិនេះផងក៏មាន ។ ហេតុនេះការសង្គ្រោះញាតិនោះ ជាកិច្ចគឺបុគ្គលគ្រប់រូបត្រូវតែធ្វើ គួរយកតម្រាប់តាមព្រះពោធិសត្វ ។ ធម្មតាព្រះពោធិសត្វទាំងឡាយទ្រង់តែងប្រព្រឹត្តប្រយោជន៍ចំពោះញាតិ សង្គ្រោះញាតិដរាប

សូម្បីទ្រង់បិននៅក្នុងព្រះជាតិជាសត្វតិរច្ឆានក៏ដោយ ដូចមានរឿងដំណាលថាៈ

កាលពីព្រេងនាយ ព្រះពោធិសត្វទ្រង់សោយព្រះជាតិជាសុនខ មានហ្វូងនៃសុខនដ៏ធំជាបរិវារ អាស្រ័យនៅក្នុងព្រៃស្មសាន ។ ក្នុងកាលមួយ ព្រះរាជាពារាណសីទ្រង់យាងក្រសាលឧទ្យានពេញមួយថ្ងៃ លុះព្រះអាទិត្យអស្តង្គតហើយទើបទ្រង់គង់លើព្រះរាជរថយាងត្រឡប់ទៅកាន់រាជធានីវិញ ។ ក្នុងពេលយប់នោះ ភ្លៀងបង្អុរចុះមកទទឹករាជរថ ដែលមនុស្សទាំងឡាយដាក់ក្នុងព្រះលានស្តេច ។ ឆ្កែទាំងឡាយដែលរាជត្រកូលចិញ្ចឹមក៏ស៊ីនូវខ្សែជ្រាមស្បែកនៃរាជរថនោះអស់រលីង ។ ព្រឹកឡើង ពួកមនុស្សទូលព្រះរាជាថាៈ មានឆ្កែចូលតាមរន្ធលូហើយទំពាស៊ីខ្សែជ្រាមស្បែកនៃរាជរថ ។ ព្រះរាជាទ្រង់ខ្ញាល់ក៏បង្គាប់ឱ្យពិឃាតឆ្កែទាំងអស់ដែលប្រទះឃើញ ។ ពេលនោះមហាភ័យបានឡើងដល់ឆ្កែទាំងឡាយ ។ ព្រះពោធិសត្វមានសេចក្តីមេត្តាចង់សង្គ្រោះញាតិ ក៏ប្រថុយជីវិតសុខចិត្តចូលទៅគាល់ព្រះរាជាផ្ទាល់ខ្លួន ហើយសួរដំណើររឿងនោះ ចំពោះព្រះរាជាថាៈ បពិត្រមហារាជ ទ្រង់បញ្ជាការឱ្យពិឃាតឆ្កែទាំង

អស់តាមតែប្រទះឬ? ឬលើកលែងឆ្កែពួកណាដែរ? លុះព្ទថា ព្រះរាជាលើកលែងឆ្កែក្នុងខត្តិយត្រកូល ព្រះពោធិសត្វក៏ពោលថា បើដូច្នេះទ្រង់នឹងលុះក្នុងអគតិហើយ ការលុះក្នុងអគតិមិនគួរទេ មិនជារាជធម៌ទេ ធម្មតាស្តេចត្រូវធ្វើឱ្យដូចជញ្ជីងថ្លឹងឱ្យស្មើជាដរាប ។ ព្រះរាជាទ្រង់សួរថាៈ ម្នាលបណ្ឌិតអ្នកដឹងឬឆ្កែណាដែលស៊ីខ្សែជ្រាមស្បែក? ព្រះពោធិសត្វលុះទូលព្រះរាជាថា ឆ្កែក្នុងខត្តិយត្រកូលស៊ីខ្សែនោះហើយ បង្គាប់ឱ្យគេយកតក្កៈនិងស្មៅចិញ្ច្រៀនច្របាច់លាយគ្នា ពួតយកទឹកឱ្យឆ្កែទាំងនោះផឹក ។ ឆ្កែទាំងនោះ ក៏ក្អួតមកសុទ្ធតែខ្សែស្បែក ។ ព្រះរាជាទ្រង់សោមនស្សចំពោះព្យាករណ៍នោះ ទើបបូជាព្រះពោធិ-សត្វដោយស្វេតច្ឆ័ត្រ ព្រះពោធិសត្វសំដែងធម៌ ហើយថ្វាយស្វេតច្ឆ័ត្រដល់ព្រះរាជា ទើបត្រឡប់ទៅកាន់កន្លែងរបស់ខ្លួនវិញ ។ ព្រះរាជាទ្រង់ប្រទានអភ័យដល់សត្វទាំងអស់ ផ្គត់ផ្គង់និច្ចភត្តដ៏មានតម្លៃ ដូចជាក្រយាស្ងោយរបស់ព្រះអង្គ ចំពោះសុខនទាំងឡាយ មានព្រះពោធិសត្វជាដើម ។

ចំណែកខាងបុគ្គលណា ដែលប្រមូលទ្រព្យសន្សំទុកបានច្រើន មិនបរិភោគប្រើប្រាស់ខ្លួនឯង មិនសង្គ្រោះពួកញាតិ

បុគ្គលនោះលោកពោលថា ស្មើគ្នានឹងសត្វស្លាបឈ្មោះមយ្ហកៈ(៣) សមដូចព្រះពោធិសត្វសំដែងធម៌ចំពោះមុខប្អូនរបស់លោក ដែលសម្លាប់បុត្ររបស់លោក ព្រោះហេតុនៃទ្រព្យថាៈ

បក្សីឈ្មោះមយ្ហកៈ ហើរទៅកាន់ដើមល្វាមានផ្លែទុំហើយគិតតែយំថា ‹‹របស់អញៗ›› បក្សីឯទៀតមកដល់ហើយស៊ីផ្លែល្វាហើយហើរទៅវិញអស់ក្តី ក៏នៅតែកន្ទក់កន្ទេញថា ‹‹របស់អញ›› ដដែល យ៉ាងណាមិញ, បុគ្គលពួកខ្លះក្នុងលោកនេះ សន្សំទ្រព្យបានច្រើន មិនហ៊ានចាយវាយប្រើប្រាស់ដោយខ្លួនឯង មិនគិតសង្គ្រោះនូវញាតិទាំងឡាយ កាលបុគ្គលនោះកំពុងហួងហែងរក្សាទន្ទេញថា ‹‹របស់អញៗ›› ស្រាប់តែពួករាជការ ឬចោរទាំងឡាយមកកំហែងយកទ្រព្យនោះអស់រលីងទៅ ក៏នៅតែទន្ទេញថា ‹‹របស់អញៗ›› ដដែល ដោយឥតប្រយោជន៍យ៉ាងនោះឯង ។ ចំណែកខាងបណ្ឌិតទាំងឡាយមិនដូច្នោះឡើយ បើមានភោគសម្បទហើយ លោកមិនសន្សំទុកតែងសង្គ្រោះញាតិទាំងឡាយ ហេតុនេះទើបលោកមានកិត្តិស័ព្ទ

---

[៣] -ឈ្មោះបក្សីមួយពួក ដែលយំថា មយ្ហកៈៗ ‹‹របស់អញៗ›› ។

ពីរោះពិសាល្បីខ្ចរខ្ចាយទៅក្នុងលោកខាងមុខ ។ ដូចន័យដែលបានអធិប្បាយមកនេះឯង ៕

---

# មង្គលទី ១៨

**អនវជ្ជានិ កម្មានិ** ការងារទាំងឡាយ ដែលមិនមានទោសជាមង្គលដ៏ឧត្តម ។

អធិប្បាយថា: ការងារទាំងឡាយដែលមិនមានទោសសំដៅយកការសមាទាននូវអង្គនៃឧបោសថទាំង ៨ មានបាណាតិបាតា វេរមណី ជាដើម មានឧច្ចាសយនមហាសយនា វេរមណីជាទីបំផុត, ការខ្វល់ខ្វាយបម្រើចាស់ព្រឹទ្ធាចារ្យនិងអ្នកមានសីលជាដើម ការដាំសួនឈើមានផ្កា សួនឈើមានផ្លែ សង់ស្ពាន ជីកអណ្តូង ជីកស្រះឱ្យទានទឹក និងសង់សាលាសម្រាប់សំណាក់ជាដើម ទាំងអស់នេះឈ្មោះថា អំពើមិនមានទោស ។ មែនពិត បុគ្គលអ្នកប្រាថ្នានូវសេចក្តីសុខសួស្តី ហើយសមាទាននូវអង្គនៃឧបោសថដោយប្រពៃ ខំរក្សាមិនឱ្យសៅហ្មង តើអ្នក

ណានឹងអាចទៅចាប់ទោសអូសដំណើរបុគ្គលនោះបាន? បុគ្គលនោះ រមែងបានទទួលយកនូវអានិសង្សនៃឧបោសថសីលតែម្យ៉ាង ។ បុគ្គលដែលឈឺឆ្អាលខ្វល់ខ្វាយបម្រើបុគ្គលអ្នកចំរើនដោយគុណ មានសីលគុណជាដើម ក៏រមែងបាននូវសុខតែម្យ៉ាងដូចគ្នា ។ បុគ្គលដែលជាអ្នកដាំសួនផ្កា សួនផ្លែ សង់ស្ពាន ជីកស្រះអណ្តូង ឱ្យទានទឹក ឱ្យទីដេកសំណាក់អាស្រ័យជាដើម ក៏សុទ្ធតែជាអ្នកឥតមានទោសទាំងអស់ មានតែគុណានិសង្សម្យ៉ាង ដូចព្រះពុទ្ធភាសិតថា:

អារាមរោបា វនរោបា យេ ជនា សេតុការកា
បបញ្ច ឧទបានញ្ច យេ ទទន្តិ ឧបស្សយំ
តេសំ ទិវា ច រត្តោ ច សទា បុញ្ញំ បវឌ្ឍតិ
ធម្មដ្ឋា សីលសម្បន្នា តេ ជនា សគ្គគាមិនោ

ជនទាំងឡាយណា ដាំសួនឈើមានផ្កា-សួនឈើមានផ្លែ សង់ស្ពាន ជីកស្រះ អណ្តូង ឱ្យទីសំណាក់អាស្រ័យ បុណ្យរមែងចម្រើនទាំងថ្ងៃទាំងយប់គ្រប់វេលា ដល់ជនទាំងឡាយនោះ, ជន

ទាំងនោះឈ្មោះថាជាអ្នកឋិននៅក្នុងធម៌ បរិបូណ៌ដោយសីល រមែងបានទៅកើតក្នុងឋានសួគ៌ជាប្រាកដ ។

បុគ្គលណា ប្រព្រឹត្តធ្វើនូវការងារមិនមានទោសនេះ រមែងបាននូវប្រយោជន៍និងសេចក្តីសុខ-ចម្រើន ទាំងបានទៅកើតក្នុងទេវលោកទៀត ដូចអតីតនិទានដំណាលថា:

ក្នុងបុរាណសម័យ មានបុរសម្នាក់បបួលមិត្តសម្លាញ់បាន ៣៣ នាក់ នាំគ្នាជម្រះផ្លូវ សង់សាលាសម្រាប់សំណាក់ ដងទឹកដាក់ពាងទុកសម្រាប់អ្នកដំណើរ ថែមទាំងបំរើអ្នកជម្ងឺ មានមេត្តាករុណាចំពោះអ្នកដទៃមិនរើសមុខ ។ មានឥស្សរជនម្នាក់មានសេចក្តីឈ្នានីសចំពោះពួកជនទាំងនោះ ក៏ចូលទៅគាល់ព្រះរាជាក្រាបបង្គំទូលបង្កាច់ថា: ជនទាំងនោះបញ្ឆុះបញ្ឆូលមហាជននឹងមកដណ្តើមរាជ្យ ។ ព្រះរាជាទ្រង់ខ្ញាល់ដោយឥតពិចារណា ក៏ត្រាស់បង្គាប់ឱ្យហៅជនទាំងនោះមកឱ្យដំរីព្រេច ។ ដោយតេជះនៃមេត្តាចិត្តនិងសុចរិតធម៌នៃជនទាំងនោះ ដំរីមិនអាចនឹងព្រេចឡើយ ត្រឡប់ជាថយក្រោយទៅវិញ ។ ព្រះរាជាទតឃើញដូច្នោះ ក៏ត្រាស់សួរ លុះជ្រាបថាជនទាំងនោះ ជាអ្នកប្រព្រឹត្តត្រឹមត្រូវល្អទេ ក៏ទ្រង់ប្រទានដំរីនោះ និងឥស្សរជនអ្នក

ពោលបង្គាប់នោះ ព្រមទាំងគ្រួសារ ឱ្យជាអ្នកបម្រើនៃជនទាំងនោះ ។ ពួកជនទាំងនោះ ក៏រឹងរឹតខំធ្វើអំពើដ៏ប្រពៃនោះយ៉ាងម៉ឺងម៉ាត់ ឥតធ្វេសប្រហែស រហូតដល់អស់ជីវិតរៀងខ្លួន ក៏បានទៅកើតជាព្រះឥន្ទ ជាទេវបុត្ត សោយសម្បត្តិទិព្វក្នុងឋានសួគ៌ទាំងអស់គ្នា ។ ឯបុរសជានាយជាមេគំនិត បានជាប្រធាននៃទេវតាទាំងនោះ មាននាមថា សក្កទេវរាជ គឺព្រះឥន្ទ សោយទិព្វសម្បត្តិអស់កាលជាយូរអង្វែង ។

ការងារដែលមិនមានទោស ចាត់ជាមង្គល ព្រោះជាហេតុឱ្យបាននូវសេចក្ដីសុខចម្រើន មានការកើតក្នុងទេវលោកជាដើម ដូចបានអធិប្បាយមកយ៉ាងនេះឯង ៕

---

# មង្គលទី ១៩

អារតី វិរតិ ចាថា ការមិនត្រេកអរក្នុងបាប និងកិរិយាវៀរចាកបាប ជាមង្គលដ៏ឧត្តម ។

អធិប្បាយថា: អារតិ ប្រែថា សេចក្ដីមិនត្រេកអរដោយចិត្ត ។ វិរតិ ប្រែថា ការវៀរដោយកាយនិងវាចា ដោយអំណាចនៃកម្មនិងទ្វារ ។ វិរតិនោះមាន ៣ យ៉ាងគឺ:

១-សម្បត្តវិរតិ ការវៀរចំពោះវត្ថុដែលដល់មកព្រមរបស់បុគ្គលដែលឥតបានសមាទានសីល ដោយបានពិចារណានូវជាតិ វ័យ និងសេចក្ដីចេះដឹងរបស់ខ្លួនថា មិនគួរនឹងធ្វើអំពើបែបនោះ ហើយអាក់ខានលែងធ្វើអំពើលាមកនោះទៅវិញ ដោយឯងៗ តែម្ដង ។

២-សមាទានវិរតិ ការវៀរចាកអំពើដ៏លាមក មានបាណាតិបាតជាដើម ដោយបានសមាទានសីល ។

៣-សមុច្ឆេទវិរតិ ការវៀរដាច់ស្រឡះ មិនធ្វើបាបកម្មតាំងពីកំណើត របស់ព្រះអរិយបុគ្គលដែលបានសម្រេចមគ្គផល ។

បាប គឺអំពើដ៏លាមក ជាគ្រឿងញ៉ាំងសត្វឱ្យសៅហ្មង ក្នុងទីនេះសំដៅយកកម្មក្កិលេស ៤ យ៉ាងគឺៈ **បាណាតិបាត** ការសម្លាប់សត្វ ១, **អទិន្នាទាន** ការលួចទ្រព្យរបស់គេ ១, **កាមេសុមិច្ឆាចារ** ការប្រព្រឹត្តខុសក្នុងកាម ១, **មុសាវាទ** ការពោលពាក្យកុហក ១ ។

ការមិនត្រេកអរក្នុងបាប និងការវៀរចាកបាប មិនប្រព្រឹត្តធ្វើអំពើអកុសលផ្សេងៗ សូម្បីព្រោះហេតុនៃជីវិត រមែងបានសេចក្ដីសុខក្នុងលោកនេះ និងលោកខាងមុខ ជួនកាលអាចរួចចាកគ្រោះថ្នាក់ ដែលមានប្រាកដក្នុងទីចំពោះមុខផង ដូចមាននិទានដំណាលថាៈ

មានឧបាសកម្នាក់ បានសមាទានសីលក្នុងសំណាក់ព្រះពុទ្ធរក្ខិតត្ថេរ ហើយទៅភ្ជួរស្រែ គាត់បានឡើងទៅលើភ្នំ ដើម្បីរកគោរបស់គាត់ដែលបាត់ ។ ស្រាប់តែមានពស់ថ្លាន់មួយធំសម្បើម ស្ទុះមករឹតគាត់ជាប់ ។ ឧបាសករៀបនឹងកាត់ក្បាលពស់ថ្លាន់នោះ នឹងកាំបិតព្រាទៅហើយ លោតែនឹកឃើញសីលដែលគាត់បានសមាទានដ៏ម៉ត់ចត់ អំពីព្រះថេរៈនោះទាន់, ក៏គិតថាៈ អញមិនគួរធ្វើអំពើបាណាតិបាតឡើយ ទោះបីពស់ថ្លាន់

នោះសម្លាប់អញក៏ដោយ ហើយក៏គ្រវែងកាំបិតដែលលីលើស្មា ចោលទៅដី ឱ្យផុតស្រឡះពីដៃទៅ ។ ដោយអំណាចនៃចិត្តដ៏បរិសុទ្ធវៀរចាកអំពើបាបនៃឧបាសកនោះ ក៏ស្រាប់តែពស់ថ្លាន់លាខ្លួនដោះលែងក្នុងខណៈនោះទៅ ។

ការមិនត្រេកអរនិងការវៀរចាកបាប ឈ្មោះថាជាមង្គល ព្រោះជាហេតុឱ្យបាននូវលទ្ធផលដូចអធិប្បាយមកនេះឯង ៕

---

# មង្គលទី ២០

មជ្ជបានា ច សញ្ញមោ សេចក្ដីសង្រួមចាកកិរិយាផឹកនូវទឹកស្រវឹង ជាមង្គលដ៏ឧត្ដម ។

អធិប្បាយថាៈទឹកស្រវឹងមាន ២ យ៉ាងគឺៈ សុរា និងមេរ័យ សុរាមាន ៥ យ៉ាងគឺៈ បិដ្ឋសុរា សុរាធ្វើដោយម្សៅ ១, បូវសុរា សុរាធ្វើដោយនំ ១, ឱទនសុរា សុរាធ្វើដោយបាយ ១, កិណ្ណ-បក្ខិត្តសុរា សុរាធ្វើដោយដាក់ជាតិសុរាចាស់ ១, សម្ភារ-សំយុត្តសុរា សុរាដែលធ្វើដោយគ្រឿងផ្សំផ្សេងៗ មានផ្លែ

សម៉ជាដើម ១, មេរ័យមាន ៥ យ៉ាងគឺៈ បុប្ផាសវៈ ទឹកត្រាំដោយផ្កាឈើ ១, ផលាសវៈ ទឹកត្រាំដោយផ្លែឈើ ១, មធ្វាសវៈទឹកត្រាំដោយទឹកឃ្មុំ ១, គុឡាសវៈ ទឹកត្រាំដោយទឹកអំពៅ ១, សម្ភារសំយុត្តាសវៈ ទឹកត្រាំប្រកបដោយគ្រឿងផ្សំដោយរសនៃផ្លែឈើមានផ្លែសម៉ជាដើម ១ ។ ការផឹកនូវទឹកស្រវឹងគឺសុរានិងមេរ័យនេះ ជាហេតុនាំឱ្យកើតទោសទាន់ហន់ក្នុងបច្ចុប្បន្ន ។ បុគ្គលអ្នកផឹកនូវទឹកស្រវឹង តែងជាអ្នកមានសេចក្តីប្រមាទធ្វេសប្រហែស ក្លាហានមិនសមទំនង ហ៊ានធ្វើអំពើបាបផ្សេងៗ ធ្វើខ្លួនឱ្យសាបសូន្យចាកប្រយោជន៍ ដែលត្រូវបានក្នុងបច្ចុប្បន្នជាតិនេះ ។ អ្នកផឹកទឹកស្រវឹងត្រូវទទួលទោស ៦ យ៉ាងជាប្រាកដក្នុងជាតិនេះគឺៈ

១-សន្ទិដ្ឋិកា ធនជានី វិនាសហិនហោចទ្រព្យសម្បត្តិទាន់ហន់ឃើញជាក់ស្តែងនឹងភ្នែកគេឯង

២-កលហប្បវឌ្ឍនី នាំបង្កបង្កើតជម្លោះ

៣-រោគានំ អយតនំ ជាសម្បុកនៃរោគផ្សេងៗ មានងងឹតភ្នែកជាដើម

៤-អភិត្តិសញ្ជនី ធ្វើឱ្យអសោចិ៍កេរ្តិ៍ឈ្មោះ

៥-កោបិនដិទំសនី បើកបង្ហាញកេរខ្មាសដោយឥតអៀន

៦-បញ្ញាយ ទុព្វលីករណី ធ្វើឱ្យខ្សោយប្រាជ្ញាស្មារតី ។ លុះទំលាយរាងកាយនេះទៅត្រូវទៅសោយទុក្ខក្នុងនរកទៀត ។ ដោយសេសសល់ផលបាបកម្មនោះ បានមកកើតជាមនុស្សវិកលចរិតឆ្កួតលេលាផ្តេសផ្តាស មិនដូចជនទាំងពួង ។ ចំណែកខាងការសង្រួម វៀរចាកការផឹកនូវទឹកស្រវឹង រមែងបានអានិ-សង្សមិនក្តៅក្រហាយស្តាយក្រោយ ដូចព្រះរាជាដែលនឹងនិទានតទៅនេះ៖

ក្នុងអតីតកាល មានព្រះរាជាមួយព្រះអង្គ ក្នុងក្រុងពារាណសី ទ្រង់មិនអាចសោយក្រយា ដែលឥតមានសាច់និងសុរាឡើយ ។ ថ្ងៃមួយ នាយពិសេសរកទិញសាច់មិនបាន, ទ្រង់ដែលកំពុងតែងុលងប់ដោយសុរា ក៏បង្គាប់ឱ្យយកព្រះរាជបុត្រជាទីស្រឡាញ់មកពិឃាត យកព្រះមំសាធ្វើជាក្រយាថ្វាយទ្រង់ លុះទ្រង់ស្វាងសុរាហើយ ក៏មានសេចក្តីសោកស្តាយព្រះរាជ-បុត្រក្រៃពេក ទើបទ្រង់ឃើញទោសសុរា ហើយលែងប្រព្រឹត្ត

តាំងពីកាលនោះមក ។ ការវៀរចាកទឹកស្រវឹង រមែងមិនក្ដៅក្រហាយស្ដាយក្រោយ ដូចនិទានដែលនាំមកនេះ រមែងបាននូវអានិសង្ស គឺសេចក្ដីសុខកាយសប្បាយចិត្ត ចម្រើនទ្រព្យសម្បត្តិ មិនភ្លាំងភ្លាត់វង្វេងស្មារតី មិនធ្វើកេរ្ដិ៍ឈ្មោះឱ្យអប្រីយ៍ មានសេចក្ដីថ្លៃថ្នូរជាដរាប ព្រោះហេតុនោះបានព្រះដ៏មានព្រះភាគត្រាស់ថាជាមង្គលដ៏ឧត្ដមដូចបានអធិប្បាយមកយ៉ាងនេះឯង ។

---

# មង្គលទី ២១

អប្បមាទោ ច ធម្មេសុ សេចក្ដីមិនប្រមាទក្នុងធម៌ទាំងឡាយ ជាមង្គលដ៏ឧត្ដម ។

អធិប្បាយថា: ការមិនប្រមាទគឺមិនធ្វេសប្រហែសក្នុងកុសលធម៌ទាំងពួង នេះជាកំពូលនៃកុលសធម៌ទាំងអស់ អប្បមាទោ អមតំ បទំ សេចក្ដីមិនប្រមាទនេះ ជាឧបាយនាំខ្លួនទៅកាន់ព្រះនិព្វាន ដែលមិនមានសេចក្ដីស្លាប់ទៀតឡើយ អ្នកដែលមិនប្រមាទ គឺអ្នកដែលមិនស្លាប់ស្មារតីៗ នៅរស់រវើក

ជានិច្ចទាំងយប់ទាំងថ្ងៃឥតរលត់ឡើយ រមែងមានសតិដាស់តឿនចិត្តឱ្យរឭកដល់ការកុសល ដែលខ្លួនបានធ្វើមកហើយរឿយៗផង កុលសងណាដែលខ្លួនមិនធ្លាប់ធ្វើ សតិដាស់តឿនចិត្តឱ្យប្រញាប់ប្រញាល់ធ្វើឡើង កុំបង្អែបង្អង់ទុកថា ចាំថ្ងៃនេះថ្ងៃនោះ ខែនេះខែនោះ ឆ្នាំនេះឆ្នាំនោះសឹមធ្វើ ព្រោះនៅក្រយ៉ាងនេះជាដើម ហៅថាមិនប្រមាទ អ្នកដែលមិនប្រមាទរមែងបានកសាងកុសល ១០ យ៉ាងគឺៈ

**ទានំ ទេតិ** ឱ្យទានដល់ពួកសត្វមគ្រប់ប្រភេទឥតរើសមុខ ១

**សីលំ រក្ខតិ** រក្សាសីល ៥ សីល ៨ ជាដើម ១

**ភាវនំ ភាវេតិ** ចំរើនកម្មដ្ឋាន ៤០ មានពុទ្ធានុស្សតិជាដើម ១

**អបចាយនំ ករោតិ** គោរពកោតខ្លាចត្រកូលរៀមច្បងជាដើម ១

**វេយ្យាវច្ចំ ករោតិ** ធ្វើការខ្វល់ខ្វាយបំរើសង្ឃ ១

**បត្តិទានំ ទេតិ** ផ្សាយចែកចំណែកផលដល់អ្នកដទៃ ១

**ធម្មទេសនំ ទេសេតិ** សំដែងធម៌ដល់អ្នកដទៃស្តាប់ ១

**ធម្មស្សវនំ សុណាតិ** ស្តាប់ធម៌អ្នកដទៃសំដែងដល់ខ្លួន ១

**អនុមោទនំ ករោតិ** ធ្វើអនុមោទនាត្រេកអរតាមបុណ្យគេឱ្យ ១

**ទិដ្ឋុជុកម្មំ ករោតិ** ធ្វើទិដ្ឋិគឺសេចក្ដីយល់ឃើញឱ្យត្រូវផ្លូវធម៌១ (រួមជា ១០ ប្រការ ហៅថាបុញ្ញកិរិយាវត្ថុ) ។

ឯអ្នកដែលមិនប្រមាទនេះ រមែងបានទៅកាន់ព្រះនិព្វានឈ្មោះអមតៈ ដូចរឿងព្រះថេរៈឈ្មោះអានន្ទលោកមិនប្រមាទ គឺតាំងពីក្រោយថ្ងៃដែលព្រះសាស្ដាស្ដេចចូលបរិនិព្វានទៅ លោកពុំហ៊ានសឹងខំចំរើនធម៌ លុះដល់ថ្ងៃទៀបនឹងបឋមសង្គាយនាព្រះសង្ឃទាំងឡាយ ដាស់តឿនលោកៗ ក៏មានព្យាយាមរឹតតែខ្លាំងក្លា ខំចម្រើនកាយានុស្សតិកម្មដ្ឋាន យប់នោះតាំងពីព្រលប់ទៅទល់គ្នានឹងថ្ងៃបែកបច្ចូសសម័យភ្លឺស្រាងៗ លោកក៏មិនទាន់បានសម្រេចព្រះអរហត្តរកកល់តែអស់សង្ឃឹម ទើបលោកគិតនឹងសឹងសម្រាកកាយ តែព្រះទ័យលោកមិនបានលះបង់ព្រះកម្មដ្ឋាន ហើយបែរភក្ត្រឆ្ពោះទៅកាន់វិហារ ក៏ទំរេតកាយចុះនឹងសឹង ព្រះបាទទាំងពីរដាក់មិនទាន់ដល់ផែនក្ដារ ព្រះសិរសាក៏ដាក់មិនទាន់ដល់ខ្នើយ ក៏លោតែបានសម្រេចហើយនូវព្រះ

អរហត្តផលព្រមទាំងបដិសម្ភិទា លះកិលេសជាសមុច្ឆេទប្រហារដាច់ចាកសន្តាន ។

ព្រះអានន្ទត្ថេរ ដែលបានសម្រេចព្រះអរហត្តផលនេះ ក៏បានព្រោះអាស្រ័យសេចក្តីមិនប្រមាទ មិនតែព្រះអានន្ទត្ថេរមួយអង្គទេ នៅមានច្រើនតទៅទៀត ដូចរឿងអញ្ញតរភិក្ខុមួយអង្គលោកមិនប្រមាទខំព្យាយាមដើរចង្រ្កមនៅក្នុងព្រៃ តាំងពីព្រលប់ដល់ពាក់កណ្តាលអាធ្រាត្រ លោកក៏រោយជង្គង់ហើយវារចង្រ្កមខំចម្រើនព្រះកម្មដ្ឋានក្នុងទីចង្រ្កមណ៍ ។ គ្រានោះមានព្រាហ្មណ៍ម្រឹគម្នាក់ដើរបាញ់សត្វ លុះទៅដល់ទីនោះ ឃើញភិក្ខុនោះគិតស្មានថាជាម្រឹគ ក៏ពួយលំពែងទៅត្រូវពោះភិក្ខុនោះៗ ក៏ស្រែកដោយសម្រែកយ៉ាងខ្លាំង ឯនាយព្រានព្រៃលុះដឹងថាត្រូវមនុស្សទេ ក៏ភិតភ័យគេចរត់បាត់ទៅ ភិក្ខុនោះខំដកលំពែងចេញអំពីកាយ ហើយយកស្មៅស្ងួតមកចុកត្រង់មុខអារុធ ចងរុំដោយសំពត់ជាប់ ក៏តាំងសតិចុះក្នុងព្រះវិបស្សនាញាណ ខំវារចង្រ្កមទៅ ក៏បានសម្រេចព្រះអរហត្តផល ហើយក៏ចូលព្រះនិព្វានក្នុងគ្រានោះឯង ។

ឯអ្នកមិនប្រមាទ រមែងបានទៅកាន់ព្រះនិព្វានដូចបានអធិប្បាយមកនេះឯង ៕

---

# មង្គលទី ២២

គារវោ ច សេចក្តីគោរព ក្នុងបុគ្គលដែលគួរគោរពជាមង្គលដ៏ឧត្តម ។

អធិប្បាយថា: ឯពាក្យថាគោរពនោះ គឺធ្វើកាយវាចាចិត្តឱ្យធ្ងន់ គឺការឱនលំទោនទៅរកបុគ្គលជាបុព្វការី ឬបុព្វបុរសរបស់ខ្លួន មានមាតាបិតាជាដើម បុគ្គលគួរគោរពនោះ ចែកជា ៣ ពួក គឺ: ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះអរហត្តសាវកព្រះពុទ្ធ ជាបុគ្គលជាន់ខ្ពស់, មាតាបិតាគ្រូជាបុគ្គលជាន់កណ្តាល, បងប្រុសបងស្រីក្នុងត្រកូលជាបុគ្គលជាន់ទាប ។ ឯបុគ្គលគួរគោរពនោះមានច្រើនប្រការតទៅទៀត តែមិនបានលើកមកសំដែងឱ្យអស់ជើងដៃក្នុងទីនេះទេ នឹងសំដែងតែអំពីគោលគារវធម៌ គឺធម៌ដែលលាយដោយបុគ្គលគួរគោរពនោះ មាន៧ប្រការ ដូចតទៅនេះគឺ:

ពុទ្ធគារវតា គោរពក្នុងព្រះពុទ្ធមួយ

ធម្មគារវតា គោរពក្នុងព្រះធម៌មួយ

សង្ឃគារវតា គោរពក្នុងព្រះសង្ឃមួយ

សិក្ខាគារវតា គោរពក្នុងសិក្ខាមួយ

សមាធិគារវតា គោរពក្នុងសមាធិមួយ

អប្បមាទគារវតា គោរពក្នុងអប្បមាទមួយ

បដិសណ្ឋារគារវតា គោរពក្នុងបដិសណ្ឋារមួយ ។

ឯការគោរពក្នុងព្រះពុទ្ធនោះ គឺត្រូវគោរពក្នុងព្រះពុទ្ធរូប ព្រះចេតិយ ព្រះសារីរិកធាតុ មហាពោធិព្រឹក្ស ទីដែលព្រះអង្គប្រសូត ទីដែលព្រះអង្គត្រាស់ដឹង ទីដែលព្រះសំដែងធម្មចក្រ ទីដែលព្រះអង្គដាក់បង់នូវអាយុសង្ខារ ទីដែលព្រះអង្គចូលនិព្វាន ទីទាំងអស់នេះ ហៅថាបូជនីយស្ថាន ។ គោរពក្នុងព្រះធម៌នោះ គឺគោរពក្នុងវិន័យ ព្រះសូត្រ ព្រះបរមត្ថអភិធម្ម បើពេលលោកសំដែងធម៌ ត្រូវអង្គុយស្តាប់ឱ្យល្អ កុំជជែកគ្នា កុំនិយាយគ្នា កុំដើរចុះឡើង កុំដេកស្តាប់ធម៌ កុំជួតក្បាល កុំបាំង

ឆ័ត្រ កុំបាំងតាំងយូ កុំអង្គុយត្របោមក្បាលជង្គង់ស្ដាប់ធម៌ កុំដេកទ្រាលស្ដាប់ជាដើម ។

គោរពក្នុងព្រះសង្ឃនោះ គឺមានកាយវាចាចិត្តឱនលំទោនក្រាបថ្វាយបង្គំ និងមិនពោលពាក្យអាក្រក់ជួជាតិ មិនមើលងាយមិនត្មះតិះដៀលដល់ព្រះសង្ឃ ។

គោរពក្នុងសិក្ខានោះ គឺខំសិក្សារៀនសូត្រធម៌វិន័យឱ្យដឹងជាក់ច្បាស់តាមភូមិរបស់ខ្លួនជាគ្រហស្ថ ឬបព្វជិត មានចិត្តសង្រួមក្នុងសីលសិក្ខារបស់ខ្លួន ។

គោរពក្នុងសមាធិនោះ គឺតាំងសតិនឹករឭកដល់សមថ-កម្មដ្ឋានទាំង ៤០ មានអនុស្សតិ ១០ ជាដើម ហើយធ្វើអង្គឈានឱ្យកើតឡើងរឿយៗ ផង ។

គោរពក្នុងសេចក្ដីមិនប្រមាទនោះ គឺឱ្យមានសតិប្រឹងលះបាបចេញ ហើយខំបំពេញបុណ្យ ខំរក្សាបុណ្យទុក និងធ្វើសីលសមាធិបញ្ញាឱ្យផូរផង់ជានិច្ច ។

គោរពក្នុងបដិសណ្ឋារៈនោះ គឺត្រូវធ្វើបដិសណ្ឋារៈដល់ភ្ញៀវដោយគ្រឿងអាមិសៈ ១, បដិសណ្ឋារៈដោយធម៌ គឺណែនាំប្រាប់ពន្យល់ផ្លូវទៅកាន់ព្រះនិព្វាន ១ ។

ម្យ៉ាងទៀត បុគ្គលដែលគួរនឹងគោរពមាន ៣ ពួកគឺៈ

អាយុវុឌ្ឍោ បុគ្គលដែលចំរើនដោយអាយុ គឺមនុស្សចាស់ជាងខ្លួនមួយ ។

គុណវុឌ្ឍោ បុគ្គលដែលចម្រើនដោយគុណ គឺមាតាបិតា និងអ្នកមានសីលជាដើមមួយ ។

បុញ្ញវុឌ្ឍោ បុគ្គលដែលចំរើនដោយបុណ្យ មានក្សត្រនិងព្រាហ្មណ៍ជាដើមមួយ ។

ឯបុគ្គល ៣ ពួកនេះ ន័យខ្លះលោករាប់ថា វយវុឌ្ឍោ គុណវុឌ្ឍោ ជាតិវុឌ្ឍោ ដូច្នេះវិញក៏មាន ។ បើគោរពលោកអ្នកមានបុណ្យឱ្យគិតថា លោកនេះពីដើមលោកមានសទ្ធា មានសីលៈ មានសុតៈ មានចាគៈ មានបញ្ញា ទើបលោកបានកើតក្នុងត្រកូលខ្ពង់ខ្ពស់ បើគិតដូច្នេះជាមុន ទើបគោរពកើតទៅជាបុណ្យ ។

ឯការគោរពដល់គ្នានឹងគ្នា តាមលំដាប់វស្សាចាស់ខ្ចីជាដើមនេះ លោកចាត់ទុកថាជាមង្គលដ៏ឧត្តម នឹងបានសេចក្ដីសុខសេចក្ដីចំរើន ក្នុងលោកនេះនិងលោកខាងមុខបាន ដូចមានរឿង

ដំណាលក្នុងគម្ពីរមង្គលត្ថទីបនីថា:

ព្រះពុទ្ធសមណគោតមបរមគ្រូជាម្ចាស់យើង ព្រះអង្គសោយព្រះជាតិជាសត្វទទា នៅក្នុងព្រៃហិមពាន្ត ទំអាស្រ័យនៅនឹងដើមជ្រៃធំមួយដើមជាទីលំនៅ គ្រានោះមានសត្វជាសំឡាញ់នឹងគ្នាពីរទៀតគឺ: ដំរី១, ស្វា១ រួមជាបីនឹងពោធិសត្វ ។ សត្វទាំងបីនេះនៅជាមួយគ្នា គ្រាក្រោយមក ទទាពោធិសត្វសួរដំរីនិងស្វាថា: ម្នាលសម្លាញ់ទាំងពីរ យើងទាំងបីនាក់នេះ តើអ្នកណាចាស់ជាងអ្នកណា បើអ្នកណាចាស់យើងត្រូវនាំគ្នាគោរពអ្នកនោះ ដំរីឆ្លើយថា: ម្នាលសំឡាញ់ កាលខ្ញុំនៅពីតូចខ្ញុំដើរតាមមេខ្ញុំមក ដើមជ្រៃនោះនៅក្រោមពោះខ្ញុំនៅឡើយ ខ្ញុំចាំបានមិនភ្លេច, ឯស្វាក៏ឆ្លើយថា: ម្នាលសម្លាញ់កាលខ្ញុំនៅជាកូនស្វាតូចនៅឡើយនោះ ខ្ញុំមកជាមួយនឹងមេខ្ញុំ ដើមជ្រៃនេះនៅកំពស់ស្មើនឹងក្បាលខ្ញុំៗ បានបេះត្រួយស៊ីជាអាហារ, ទទាពោធិ-សត្វឆ្លើយថា ម្នាលសំឡាញ់ទាំងពីរ ក្នុងទីឯណោះមានដើមជ្រៃមួយធំ ខ្ញុំបានពាំផ្លែជ្រៃនោះមកស៊ីជាអាហារ ហើយមកបន្ទោបង់ឧច្ចារៈក្នុងទីនេះឯង ដើមជ្រៃនេះដុះពីវច្ចៈនៃខ្ញុំៗ ត្រូវចាស់ជាងអ្នកទាំងពួង គឺទទាចាស់ជាងស្វាៗ ចាស់ជាងដំរី ហើយសត្វ

ទាំងបីនោះ គោរពគ្នានឹងគ្នាតាមលំដាប់វស្សាចាស់ខ្ចី ពោធិសត្វក៏ឱ្យសត្វស្វានិងដំរីសមាទានសីល ៥ សត្វទាំងពីរនោះ ក៏គោរពសត្វទទា លុះធ្វើកាលកិរិយាទៅសត្វទាំងបីក៏បានទៅកើតក្នុងស្ថានសួគ៌ ដោយសេចក្ដីគោរពគ្នានិងគ្នា និងរក្សាសីល ៥ ប្រការជាប់ជានិច្ច ។

មួយវិញទៀត ឯលក្ខណៈគោរពនេះមាន ៣ ប្រការគឺៈ

កាយបណាម គោរពដោយកាយមានថ្វាយបង្គំក្រាបសំពះជាដើមមួយ, វចីបណាម គោរពដោយវាចា មានពោលពាក្យសរសើរគុណជាដើមមួយ, មនោបណាម គោរពដោយចិត្ត មានចិត្តមិនប្រមាថមើលងាយជាដើមមួយ ។ (រួមជាបីប្រការ)

ព្រះពុទ្ធសាសនាដែលនឹងតាំងនៅមាំមួនបាន ក៏អាស្រ័យនឹងគោរព ៧ ប្រការនេះៗ ស្ថិតនៅត្រឹមណា ព្រះពុទ្ធសាសនាក៏ស្ថិតនៅត្រឹមនោះ បើគោរព ៧ ប្រការនេះអស់ហើយ ព្រះពុទ្ធសាសនាក៏រលត់ផងដែរ ដូចអធិប្បាយមកនេះឯង ៕

---

# មង្គលទី ២៣

## និវាតោ ច កិរិយាប្រព្រឹត្តបន្ទាបខ្លួន ជាមង្គលដ៏ឧត្តម ។

អធិប្បាយថាៈ ឯពាក្យថាបន្ទាបខ្លួននេះ បានដល់ការដាក់បង់នូវសក្កាយទិដ្ឋិនិងអស្មិមានៈចេញចាកសន្តាន ឬគ្រាន់តែធ្វើឱ្យស្រាលស្តើងក៏ជាមង្គល អ្នកដែលមិនប្រកាន់ជាតិត្រកូលថា យើងជាជាតិក្សត្រ យើងជាជាតិព្រាហ្មណ៍ យើងជាជាតិសេដ្ឋីគហបតី ឬថាយើងជាមហាត្រកូល យើងមានយសសក្តិច្រើន យើងមានបរិវារច្រើន យើងមានទ្រព្យច្រើន ឬមិនមានមានៈដោយទិដ្ឋិថា ខ្លួនយើង ខ្លួនគេ របស់យើង របស់គេ ឬក៏មិនប្រកាន់ថា សត្វលោកទៀងទាត់ស្ថិតស្ថេរថិរកាលមិនប្រែប្រួលនោះឡើយ ។

ឯមានៈ និងទិដ្ឋិទាំងពីរនេះ ជាធម៌នាំឱ្យមានសេចក្តីវិនាសទាំងជាតិនេះផងជាតិមុខផង, ឯវិនាសជាតិនេះនោះ ដូចរឿងសត្វចចក បានឮមន្តបុរោហិតម្នាក់នៅក្នុងនគរពារាណសីកំពុងស្វាធ្យាយ ចចកចាំបានហើយនាំយកមន្តនោះ ទៅសំដែងកណ្តាលព្រៃ ពួកសត្វទាំងឡាយមានរាជសីហ៍ជាដើម ខ្លាច

អំណាចមន្តក៏នាំគ្នាចុះចូលចចកៗ ក៏តាំងខ្លួនជាស្ដេច ធ្វើសត្វទាំងឡាយនោះឱ្យជាបរិវារ លុះចំណេរតមកនោះ ស្ដេចចចកក៏កាន់តែមានមានៈច្រើនឡើងៗ តណ្ហានិងទិដ្ឋិក៏កាន់តែកើតច្រើនឡើងដែរ ហើយគិតនឹងដណ្ដើមយករាជសម្បត្តិស្ដេចពារាណសី ស្ដេចចចក ក៏ប្រជុំពួកសត្វជាច្រើនប្រមាណ ១២ យោជន៍ ហើយចចកក៏ឡើងជិះលើខ្នងរាជសីហ៍ធំ នាំគ្នាចូលទៅចោមរោមព័ទ្ធជុំវិញក្រុងពារាណសី ។ ឯកោ ព្រាហ្មណោ មានព្រាហ្មណ៍ម្នាក់ មានប្រាជ្ញាឡើងទៅលើឈើខ្ពស់ហើយសួរថាៈ អ្នកចោមរោមព្រះនគរនេះប្រាថ្នាចង់បានអ្វី? ស្ដេចចចកក៏ប្រាប់ថា យើងចង់បានរាជសម្បត្តិ ធ្វើជាក្សត្រសោយរាជ្យក្នុងនគរពារាណសីនេះ ព្រាហ្មណ៍នោះ សួរថា ចុះអ្នកនឹងគិតធ្វើដូចម្ដេច ទើបនឹងយករាជសម្បត្តិក្នុងនគរពារាណសីបាន? ចចកថា យើងនឹងឱ្យរាជសីហ៍ធំដែលយើងជិះនេះស្រែកឡើង មនុស្សទាំងឡាយនឹងស្លាប់អស់ទាំងនគរ យើងនឹងបានរាជសម្បត្តិ ធ្វើជាក្សត្រនគរពារាណសី, ព្រាហ្មណ៍សួរទៀតថាៈ ចុះអ្នកនឹងឱ្យរាជសីហ៍ស្រែកសម្រែកក្នុងវេលាណា? ចចកប្រាប់ថា នៅតែ ៧

ថ្ងៃទៀតទេ អ្នកចូរប្រជុំគ្នាចាំស្ដាប់ចុះ ។ លុះព្រាហ្មណ៍នោះដឹងច្បាស់ក៏យកសេចក្ដីក្រាបទូលព្រះបរមក្សត្រ។ ស្ដេចឱ្យប៉ាវគងប្រាប់អ្នកស្រុកក្នុងនគរទាំងអស់ ឱ្យយកម្សៅសណ្ដែកបុកលាយនឹងសំឡី ហើយចុកត្រចៀកឱ្យជិតគ្រប់ៗ គ្នា ដរាបដល់សត្វមានឆ្អែតឆ្អាជាទីបំផុត លុះដល់ថ្ងៃជាគម្រប់ ៧ ជនទាំងឡាយក៏ធ្វើដូច្នោះគ្រប់ៗ គ្នា ។ គ្រានោះ ព្រាហ្មណ៍ក៏ទៅកាន់ទីដែលចចកនៅនោះហើយ បង្គាប់ឱ្យស្ដេចចចកធ្វើសង្គ្រាម ស្ដេចចចកក៏ឡើងឈរលើខ្នងរាជសីហ៍ ហើយទន្ទ្រំជើង ៣ ដងឱ្យរាជសីហ៍ស្រែក រាជសីហ៍ក៏ស្រែកដោយសម្រែកយ៉ាងខ្លាំង ពួកសត្វទាំងអស់ភ្ញាក់ផ្អើល ដំរីក៏បោលធ្លាក់ស្ដេចចចកចុះចាកខ្នងរាជសីហ៍ សត្វទាំងឡាយក៏ជាន់ចចកក្ស័យជីវិតទៅ សត្វក្រៅពីនោះទៀតក៏បោលជាន់គ្នាប្រគរលើផែនដី ត្រឡប់ជាបានដៃអ្នកនគរពារាណសី ធ្វើងៀតទៅវិញ ។

ជនទាំងឡាយ បបួលគ្នាយករទេះមកដឹកអូសជញ្ជូនសត្វទាំងឡាយមានឈ្លូស រមាំងជាដើម ហើយអារសាច់បានច្រើនយកទៅប្រឡាក់អំបិលហាលថ្ងៃ ធ្វើងៀតទុកអាស្រ័យបានយូរ

ឯអ្នកស្រុកពារាណសី ក៏ធ្វើរៀតតាំងពីគ្រានោះជាប់មកដរាបដល់សព្វថ្ងៃនេះ ។

ពួកជនមិនមានសក្កាយទិដ្ឋិ អស្មិមានៈ តែងបានសុខ អ្នកប្រកាន់ខ្លួន លើកតម្កើងខ្លួនតែបានទុក្ខ ដូចអធិប្បាយមកនេះឯង ។

---

# មង្គលទី ២៤

**សន្តុដ្ឋី** ៥ សេចក្តីត្រេកអរ ចំពោះរបស់ដែលមានជាមង្គលដ៏ឧត្តម ។

អធិប្បាយថាៈ សេចក្តីត្រេកអរចំពោះរបស់ដែលមាន គឺបានដល់អ្នកដែលមានចិត្តសន្តោសៗ នេះ ចែកដោយបុគ្គលមាន ២ យ៉ាងគឺៈ បព្វជិតសន្តោស ១, គហដ្ឋសន្តោស ១ ។ ឯបព្វជិតសន្តោសនោះ បានដល់លោកអ្នកបួសដែលត្រេកអរក្នុងទីស្ងាត់នៅក្នុងព្រៃ ឬក្នុងកុដិក្នុងគុហាស្ងាត់តែម្នាក់ឯង មិនត្រូវការនឹងឥតរិតរបច្ច័យ គឺបច្ច័យដែលច្រើនលើសលប់ ត្រេក-

អរតែក្នុងបច្ច័យ ៤ តាមមានតាមបាន គឺបានមកយ៉ាងណាក៏បរិភោគយ៉ាងនោះ មិនល្មោភក្នុងអាហារជាអាការនាំឱ្យជ្រះថ្លាដល់បុគ្គលដែលមិនទាន់ជ្រះថ្លា ដូចមានរឿងដំណាលពីព្រាហ្មណ៍ម្នាក់ មិនទាន់ជ្រះថ្លាក្នុងព្រះពុទ្ធសាសនា សម័យថ្ងៃមួយ ព្រាហ្មណ៍នោះគិតថា ភិក្ខុនេះជាអ្នកមិនត្រូវការចង់បានរបស់ច្រើនក្នុងអាហារ អញល្បងលោកមើលបន្តិចចុះ គិតហើយក៏យកបាយមួយផ្តិលទៅកាន់ទីវិហារ គ្រានោះភិក្ខុសង្ឃ ៣០ រូបកំពុងប្រជុំគ្នាឆាន់, ព្រាហ្មណ៍ក៏លើកផ្តិលបាយចូលទៅប្រគេនព្រះថេរៈៗ ក៏ចាប់បន្តិចហើយហុចផ្តិលបាយនោះតៗ ទៅប្រគេនភិក្ខុដទៃទៀតដរាបដល់គ្រប់ភិក្ខុសង្ឃទាំង ៣០ រូប លុះព្រាហ្មណ៍នោះបានឃើញដូច្នោះហើយក៏កើតជ្រះថ្លា បរិច្ចាគទ្រព្យសាងវិហារសាងចេតិយជាច្រើន ធ្វើឱ្យរុងរឿងក្នុងព្រះពុទ្ធ-សាសនា ។ ឯការសន្តោសនេះ លោកចែកចេញទៅទៀតមាន ៣ ប្រការគឺៈ

១-យថា លាភសន្តោស សន្តោសគឺត្រេកអរតាមបានតាមមាន ។

២-យថា ពលសន្តោស សន្តោសតាមកម្លាំងខ្លួនប្រើប្រាស់បាន ។

៣-យថា សារុប្បសន្តោស សន្តោសតាមសមគួរដល់ឋានៈរបស់ខ្លួន គឺបើបានរបស់ល្អ ឬរបស់ប្លែកថ្មោងថ្មី មិនហ៊ានប្រើប្រាស់ មិនហ៊ានឆាន់ខ្លួនឯង ស៊ូយកទៅប្រគេនលោកដែលមានគុណលើខ្លួន ។

បើចំណែកខាងគ្រហស្ថ សន្តោសភរិយាស្វាមីរបស់ខ្លួន គឺ មានតែមួយនឹងមួយ មិនល្មោភក្នុងកាម បើមិនសន្តោសទេនឹងនាំឱ្យមានសេចក្តីវិនាស ដូចរឿងដំណាលពីខត្តិយបុត្រ ១ អង្គមានទោសត្រូវបិតាបណ្តេញចេញចាកនគរ ហើយនាំភរិយាចូលទៅនៅក្នុងព្រៃ ថ្ងៃមួយខត្តិយបុត្តនោះ បានឃើញនាងកិន្នរីមួយមានរូបល្អក៏លះបង់ភរិយាខ្លួន ហើយដើរតាមនាងកិន្នរីនោះដោយសេចក្តីស្រឡាញ់ចង់បាននាងកិន្នរី, ឯភរិយានឹកតូចចិត្តណាស់ ព្រោះឃើញគេលះបង់ចោលខ្លួនហើយ ក៏ចូលទៅកាន់សំណាក់ឥសី សូមរៀនកសិណក៏បានសម្រេចអភិញ្ញាហោះទៅកាន់អាកាស ចំណែកខត្តិយបុត្រដែលដើរទៅតាមកិន្នរីនោះ

លុះរៀបនឹងជិតកិន្នរីៗ នោះក៏ស្ទុះហើរឡើងទៅតាមអាកាសបាត់ទៅ ខត្តិយបុត្តនោះ ក៏ខុសបំណងមិនបានសម្រេចដូចសេចក្តីប្រាថ្នា ហើយក៏ត្រឡប់មករកភរិយាវិញក៏មិនឃើញ ទើបនឹកស្តាយក្រោយតូចចិត្តណាស់ ក៏អង្គុយយំនៅក្នុងព្រៃម្នាក់ឯង, រឿងខត្តិយបុត្តដែលនាំមកសំដែងនេះ ជាបុគ្គលាធិដ្ឋាន ដើម្បីសរឱ្យឃើញថាអ្នកធ្លាយសន្តោសហើយ រមែងបានសេចក្តីវិនាស តែងកើតវិប្បដិសារីក្តៅក្រហាយនឹកស្តាយក្រោយ ។ ឯសន្តោសនោះបើថាឱ្យខ្លីចុះ បព្វជិតត្រូវមានចិត្តសន្តោសក្នុងបច្ច័យ ៤ គឺប្រើប្រាស់តាមបានតាមមានតាមកម្លាំងកាយខ្លួនតាមសមគួរដល់កម្លាំងបុណ្យ ឬឋានៈរបស់ខ្លួន ។ បើគ្រហស្ថវិញ ត្រូវឱ្យមានចិត្តសន្តោសក្នុងកាមគុណ ៥ គឺ រូប, សម្លេង, ក្លិន, រស, សម្ផស្ស, ប្រើប្រាស់តាមបានតាមមានដូចគ្នា កុំឱ្យមានចិត្តអន្ទះសាក្តៅក្រហាយក្នុងកាមគុណអ្នកដទៃ និងធ្លាយសន្តោសហើយ ដល់នូវសេចក្តីវិនាស ដូចរឿងដែលបានអធិប្បាយខាងលើនេះឯង ៕

# មង្គលទី ២៨

**កតញ្ញុតា** ភាពនៃបុគ្គលជាអ្នកដឹងនូវឧបការគុណដែលអ្នកដទៃធ្វើហើយដល់ខ្លួន ជាមង្គលដ៏ឧត្តម ។

អធិប្បាយថាៈ បុគ្គលណាមួយដែលដឹងនូវឧបការគុណអ្នកដទៃគេធ្វើដល់ខ្លួន បុគ្គលនោះឈ្មោះថាកតញ្ញូបុគ្គលៗ នេះត្រូវធ្វើកតវេទីតបឧបការគុណគេវិញ ទើបបុគ្គលនោះបានឈ្មោះថា កតញ្ញូកតវេទីបុគ្គល បើហៅជាធម៌ថា កតញ្ញូកតវេទិតាធម៌ បើហៅដោយបុគ្គលក្រមានពីរយ៉ាងក្នុងលោកគឺៈ បុព្វការីបុគ្គល ៗ ដែលធ្វើឧបការគុណលើគេមុន ១, កតញ្ញូកតវេទីបុគ្គលៗ ដែលដឹងថា គេមានគុណហើយធ្វើតបឧបការគុណគេវិញ ១ បុគ្គលទាំងពីរនេះក្រដូចគ្នា ។

ឯបុព្វការីបុគ្គលនោះ ទី ១ គឺព្រះពុទ្ធជាម្ចាស់ ព្រោះព្រះអង្គខំកសាងជាច្រើនអសង្ខេយ្យកប្ប ទើបបានត្រាស់ជាព្រះពុទ្ធហើយទ្រង់ប្រដៅសត្វក្នុងផ្លូវសួគ៌និងព្រះនិព្វាន, ទី ២ គ្រូឧបជ្ឈាយាចារ្យ លោកជាអ្នកបំបួសខ្លួនហើយជាអ្នកប្រដៅ ជាអ្នកពន្យល់ចង្អុលប្រាប់មគ្គផល ក្នុងផ្លូវសួគ៌និងព្រះនិព្វានផង,

ទី៣ មាតាបិតា លោកជាអ្នកបង្កើតបុត្រហើយចិញ្ចឹមបីបាច់ថែរក្សាឱ្យជីវិតបុត្រផង, ទី៤ ជីដូនជីតា និងក្រុមញាតិសាលោហិតលោកជាអ្នកជួយចិញ្ចឹមថែរក្សាខ្លួន ជួយឧបត្ថម្ភទំនុកបម្រុងខ្លួនជួសមាតាបិតាដែលមិននៅ ឬស្លាប់ចោលខ្លួនទៅផង, ទី ៥ អ្នកដទៃទេ ប៉ុន្តែគេបានឧបត្ថម្ភខ្លួន ដោយជួយចិញ្ចឹមថែរក្សាតាំងពីតូចមកក្តី ធំហើយក្តី ដោយគេឱ្យគ្រឿងស្លៀកពាក់ជាដើម, បុគ្គលទាំង ៥ ពួកនេះ ឈ្មោះថាបុព្វការីបុគ្គល គឺបុគ្គលដែលបានធ្វើឧបការគុណមុន ។

ឯកតញ្ញូកតវេទីបុគ្គល និងបុព្វការីបុគ្គល ចែកទៅមាន ២ ក្រុមដូចគ្នាគឺ លោកជាអ្នកបួស ១, ជាគ្រហស្ថ ១ ។ បើជាអ្នកបួសត្រូវគោរពក្នុងស្ថាន ៧ ប្រការ មានពុទ្ធគារវតាជាដើម រហូតដល់ឧបត្ថម្ភលោកដោយបច្ច័យ ៤ ផង និងធ្វើវត្តផ្សេងៗ ដល់លោក្នុងវត្តទាំង ១៤ មានឧបជ្ឈាយវត្ត និងអាចរិយវត្តជាដើមផង ។ ឯកិច្ចវត្តដែលសិស្សានុសិស្សត្រូវធ្វើដល់គ្រូឧបជ្ឈាយ៍ ឬអាចារ្យនោះ គឺបើឃើញលោកមកត្រូវក្រោកទទួល បើលោកត្រឡប់ទៅវិញ ត្រូវជូនដំណើរនិងធ្វើការបំរើលោកដោយទឹកក្តៅទឹកត្រជាក់ គក់ច្របាច់បាទានិងកិច្ចនានាមានគក់លាងជ្រលក់

ចីវរជាដើម ។ ម្យ៉ាងទៀត បុគ្គលក្នុងលោកនេះ ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ទេសនាថាៈ ចត្តារោមេ ភិក្ខវេ បុគ្គលា ម្នាលភិក្ខុទាំងឡាយ បុគ្គលក្នុងលោននេះមាន ៤ ពួកគឺៈ

១-តមោតមបរាយនោ បុគ្គលងងឹតហើយតែងងងឹតទៅ គឺបុគ្គលល្ងង់មានចិត្តអាក្រក់ស្រាប់ហើយ ធ្វើអំពើបាបថែមទៀត,

២-តមោជាតិបរាយនោ បុគ្គលងងឹតហើយត្រឡប់ជាភ្លឺវិញ គឺបុគ្គលនោះពីដើមល្ងង់ ហើយត្រឡប់ទៅជាភ្លឺវិញ ឬពីដើមអាក្រក់ហើយក្រោយមកត្រឡប់ជាល្អវិញ,

៣-ជោតិតមបរាយនោ បុគ្គលភ្លឺហើយត្រឡប់ទៅជាងងឹតវិញ គឺបុគ្គលនោះពីដើមចេះក្រោយមកត្រឡប់ទៅជាល្ងង់វិញ ឬពីដើមល្អក្រោយមកត្រឡប់ជាមនុស្សអាក្រក់វិញ,

៤-ជោតិជោតិបរាយនោ បុគ្គលភ្លឺហើយភ្លឺរហូត គឺបុគ្គលនោះ ពីក្មេងចេះហើយចាស់ខ្លួនទៅ នៅតែចេះចាំច្បាប់សីលធម៌សាសនាដដែល ឬពីក្មេងជាមនុស្សល្អមានសីលធម៌ ក៏ល្អរហូតដល់ថ្ងៃស្លាប់ ។

ឯបុគ្គលងងឹតរហូតអស់មួយជីវិត ដូចរឿងនាយចន្ទសូករិក ជាអ្នកចិញ្ចឹមជីវិតដោយការសម្លាប់ជ្រូកលក់ ឬដូចរឿងនាយគោឃាតកៈចិញ្ចឹមជីវិតដោយការសម្លាប់គោលក់ បុគ្គលក្នុងរឿងទាំងពីរនេះ ស្លាប់ទៅៗ សោយទុក្ខវេទនាក្នុងអវីចិមហានរកទាំងអស់គ្នា ។

ឯបុគ្គលងងឹតហើយត្រឡប់ទៅជាភ្លឺវិញនោះ ដូចរឿងនាងខុជ្ជុត្តរា ពីដើមនាងតែងកិបលិបស៊ីប្រាក់នាងសាមាវតីជាថៅហ្វាយ ប្រើឱ្យទិញផ្កាអំពីផ្ទះនាយសុមនមាលាផ្កា ថ្ងៃក្រោយបានស្តាប់ធម៌ទេសនា ព្រះសម្មាសម្ពុទ្ធទៅកាលណា ក៏ដឹងថាខ្លួនខុសមានទោសធ្ងន់ណាស់ ក៏សូមខមាទោសនឹងព្រះនាងជាថៅហ្វាយ ហើយក៏លះបង់អំពើខុសនោះរហូតទៅ ។

ឯបុគ្គលភ្លឺហើយត្រឡប់ទៅជាងងឹតវិញនោះ ដូចរឿងភិក្ខុទេវទត្តពីដើមស្រឡាញ់ព្រះពុទ្ធ ជ្រះថ្លាព្រះពុទ្ធធ្វើត្រូវល្អ ហើយទើបទៅបួសតាមព្រះអង្គ ក្រោយមកត្រូវលាភគ្របសង្កត់ ក៏ត្រឡប់ជាស្អប់ព្រះពុទ្ធ រករឿងធ្វើឱ្យព្រះពុទ្ធវិនាសព្រះអង្គទៅវិញ ទាល់តែព្រះធរណីស្រូបខ្លួនធ្លាក់ទៅសោយទុក្ខវេទនាក្នុងនរកឈ្មោះមហាអវីចិ ។

ឯបុគ្គលភ្លឺហើយភ្លឺរហូតនោះ ដូចរឿងនាងលាជទេវធីតា កាលពីខ្លួននៅជាស្ត្រីចាំស្រែស្រូវ បានយកលាជទៅដាក់បាត្រព្រះមហាកស្សប លុះពស់ចឹកស្លាប់បានទៅកើតជាទេវធីតាឈ្មោះនាងលាជា នៅក្នុងទិព្វវិមានព្វដ៏ស្ថានត្រៃត្រិង្សសួគ៌ា ក៏ពិចារណាមើលបុណ្យខ្លួនដឹងច្បាស់ថា សម្បត្តិដែលខ្លួនបាននេះមកពីយកលាជទៅដាក់បាត្រព្រះមហាកស្សប ហើយក៏ចុះមកលបធ្វើវត្តប្រគេនព្រះមហាកស្សប មានបោសសម្រាមនិងដងទឹកដាក់ពាងជាដើម ប្រគេនលោករាល់ៗយប់ លុះព្រះថេរៈជ្រាបក៏ហាមឃាត់មិនឱ្យធ្វើវត្តតទៅ, នាងក៏នៅតែទទូចសូមធ្វើវត្ត ទាល់តែព្រះថេរៈគម្រាមបណ្ដេញចង្អុលមុខឱ្យចៀសចេញទៅ ក៏ស្រែកយំក្ដែងៗ ហេតុនេះជ្រាបដល់ព្រះពុទ្ធជាម្ចាស់ៗព្រះអង្គសំដែងធម៌ដល់នាងលាជទេវធីតាថា ការសង្រួមជាភារៈរបស់កស្សបៈ ដែលមិនចង់ឱ្យជាប់នាមថាមានស្រីបម្រើ, ឯការធ្វើវត្តជាភារៈរបស់នាងអ្នកប្រាថ្នាបុណ្យ លុះចប់ធម៌ទេសនានាងលាជទេវធីតាក៏បានសម្រេចសោតាបត្តិផល ហើយថ្វាយបង្គំលាទៅកាន់ស្ថានទេវលោកវិញ ។

បើរួមរឿងបុគ្គលទាំង ៤ ពួកបញ្ចូលមកតែក្នុងរឿងមួយ ឱ្យឃើញរូបបុគ្គលអាក្រក់និងល្អនោះ ក៏គួរគិតឱ្យយល់ដូចក្នុងផ្ទៃរឿងឆទន្តជាតកដែលដំណាលថាៈ ទេវទត្តជាបុគ្គលអាក្រក់ក្រៃលែងអាក្រក់ ព្រោះថារឿងទេវទត្តសរសេចក្តីឱ្យឃើញរូបបុគ្គលអកតញ្ញូ រឿងដំរីឆទន្តៈសរសេចក្តីឱ្យឃើញរូបបុគ្គលល្អខាងមានចិត្តមេត្តាករុណាធំក្រៃលែង ដោយព្រះអង្គស្វែងរកបារមីធម៌ក្នុងផ្ទៃរឿងនោះវែងណាស់ តែរួមឱ្យខ្លីទៅថាទេវទត្តកាលនោះជាព្រាន មកប្រាថ្នាដើម្បីសម្លាប់ព្រះពោធិសត្វយកភ្លុក ព្រះអង្គកាត់ភ្លុកឱ្យជាទាន ហើយជូនបង្ហាញផ្លូវ ទេវទត្តព្រាននោះបានភ្លុកទៅលក់ស៊ីចាយអស់ ហើយមកសូមកាត់ភ្លុកព្រះអង្គទៀត ព្រះអង្គក៏ចេះតែឱ្យកាត់យកបន្តិចម្តងៗ ដរាបដល់ជាប់ភ្លុកដែលនៅក្នុងសាច់ទៀត ក៏ចេះតែឱ្យឥតមានព្រះទ័យរួញរា ដរាបដល់សោយព្រះវិលាល័យទៅ, ឯទេវទត្តព្រានជាមនុស្សពាលអកតញ្ញូ ក៏ដល់នូវសេចក្តីវិនាសក្នុងគ្រានោះ គឺព្រះធរណីស្រូបទៅៗកើតក្នុងអវិចិនរក សោយទុក្ខវេទនាជាអង្វែងឆ្នាំ គួរឱ្យឃើញថាព្រះអង្គល្អក្រៃលែងល្អ, ឯទេវទត្តអាក្រក់ក្រៃលែងអាក្រក់ បុគ្គលអ្នកប្រាថ្នាល្អគួរយកតម្រាប់តាមព្រះពោធិសត្វ កុំ

យកតម្រាប់តាមទេវទត្តព្រាននោះឡើយ ដោយន័យដូចបាន អធិប្បាយមកនេះឯង ។

---

## មង្គលទី ២៦

កាលេន ធម្មស្សវនំ បុគ្គលបានស្តាប់ធម៌រឿយៗ តាមកាល ជាមង្គលដ៏ឧត្តម ។

អធិប្បាយថាៈ កាលនៃធម៌មាន ៤ យ៉ាងគឺៈកាលដែល បុគ្គលគួរសំដែងធម៌ហៅថា កាលេន ធម្មទេសនា ១, កាល ដែលបុគ្គលគួរស្តាប់ធម៌ទេសនាហៅថា កាលេន ធម្មស្សវនា ១, កាលដែលបុគ្គលគួរសាកសួរធម៌ ឬសន្ទនាធម៌គ្នាហៅថា កាលេន ធម្មសាកច្ឆា ១, កាលដែលបុគ្គលគួរពិចារណាធម៌ ហៅថា កាលេន វិបស្សនា ១ ( រួមជា ៤ ) ។

ឯពាក្យថាស្តាប់ធម៌តាមកាលក្នុងទីនេះ សំដៅកាលឧបោ-សថសីលក្នុង ១ ខែមាន ៦ ដង តាមបាលីគឺថ្ងៃ ៨ កើត ៨ រោច ១៤ កើត ១៤ រោច ១៥ កើត ១៥ រោច រួមជា ៦ ថ្ងៃ, បើតាម

អដ្ឋកថា ក្នុង ១ ខែមាន ៨ ដង គឺថ្ងៃ ៥ កើត ៥ រោច ៨ កើត ៨ រោច ១៤ កើត ១៤ រោច ឬ ១៣ រោចបើខែខ្វះ ១៥ កើត ១៥ រោច (រួមជា ៨ ថ្ងៃ) ។ បើបុគ្គលណាបានស្តាប់ធម៌រឿយៗ តាមកាលនេះនឹងបានអានិសង្ស ៥ យ៉ាងគឺៈ

១-អស្សុតំ សុណាតិ រមែងបានស្តាប់នូវធម៌ណាដែលខ្លួនមិនធ្លាប់ស្តាប់,

២-សុតំ បរិយោ ទបេតិ រមែងធ្វើធម៌ដែលខ្លួនធ្លាប់ស្តាប់ហើយ ឬទើបនឹងស្តាប់ថ្មីៗ ឱ្យផូរផង់បាន គឺរឹតតែមានបញ្ញាចាំច្បាស់លាស់ឡើង,

៣-កង្ខំ វិនោទេតិ រមែងកាត់បង់នូវសេចក្តីសង្ស័យក្នុងចិត្តបាន,

៤-ទិដ្ឋឹ ឧជុំ ករោតិ រមែងធ្វើទិដ្ឋិរបស់ខ្លួនឱ្យត្រង់ ក្នុងព្រះពុទ្ធសាសនាបាន,

៥-ចិត្តមស្ស បសីទតិ រមែងញុំាងចិត្តរបស់ខ្លួនឱ្យជ្រះថ្លានឹងកើតបញ្ញាឃើញកងទុក្ខទាំងពួងបាន ។

ឯការស្តាប់ធម៌នេះ នឹងមានអានិសង្ស ៤ យ៉ាងផ្សេងពីនេះ

ទៀតគឺៈ

១-ពុទ្ធសាសនំ វិរោចេតិ ការស្តាប់ធម៌រមែងញុំាំងព្រះពុទ្ធសាសនាឱ្យរុងរឿងអស់កាលជាអង្វែងតទៅ,

២-សុគតិបរាយនោ វេលាស្លាប់នឹងបានទៅកើតក្នុងស្ថានសួគ៌ទេវលោកនាយ,

៣-បដិវេធំ នឹងបានត្រាស់ដឹងនូវមគ្គនិងផល,

៤-ពហុស្សុតោ នឹងបានជាពហូសូត អ្នកប្រាជ្ញព្រោះស្តាប់ធម៌ (រួមជា ៤ ប្រការ) ។

ឯអ្នកស្តាប់ធម៌ទេសនានេះ មិនមែនគ្រាន់តែមានអានិសង្ស ៥ ឬ ៤ យ៉ាងប៉ុណ្ណោះទេ នឹងមាននិស្ស័យក្នុងធម៌ ៤ យ៉ាងតទៅទៀតគឺៈ

១-សោតំ ធាវតិ ក្រសែធម៌ស្ទុះចូលកាន់ត្រចៀក,

២-ឧគ្គណ្ហាតិ កើតរៀនសូត្រទន្ទេញធម៌ ព្រះវិន័យ ព្រះសូត្រ ព្រះបរមត្ថ,

៣-វាចេតំ ក៏នឹងបានប្រាប់ធម៌ សំដែងធម៌ដល់អ្នកដទៃផង,

៤-សជ្ឈាយំ បានរៀនសូត្រទន្ទេញស្វាធ្យាយធម៌ដោយ

ខ្លួនឯង និស្ស័យ ៤ យ៉ាងនេះ ជាភាវូបនិស្ស័យ នឹងកើតមានឡើងដល់អ្នកធ្វើបុណ្យអ្នកស្តាប់ធម៌ដោយពិត ។

ម្យ៉ាងទៀត ព្រះពុទ្ធសាសនានឹងសាបសូន្យអួនថយទៅជាថោកទាបបានមកអំពីពុទ្ធបរិស័ទទាំង ៤ ពួកមិនប្រតិបត្តិធម៌ដោយគោរព ១, មិនរៀនធម៌ដោយគោរព ១, មិនទ្រទ្រង់ធម៌ដោយគោរព ១, មិនពិចារណាធម៌ដោយគោរព ១ ។ ឯការស្តាប់ធម៌នេះ រមែងនាំឱ្យមានឧបនិស្ស័យដល់ចិត្ត ទោះបីជាតិជាមនុស្សក្តី ជាទេពតាក្តី ជាសត្វតិរច្ឆានក្តី នឹងបានឧបនិស្ស័យដូចគ្នា ដូចរឿងកុក្កុដមេមាន់ញីមួយ អាស្រ័យដេកនៅជិតទីសាលាធម្មសភា គ្រានោះ មានភិក្ខុស្វាធ្យាយធម៌ មានបានស្តាប់ហើយមានចិត្តត្រេកអរក្នុងធម៌ ។ *អបរភាគេ* លុះកាលជាខាងក្រោយមក មានខ្លែងមួយមកឆាបយកមេមាន់នោះ ទៅស៊ីជាអាហារ មាន់នោះលុះធ្វើកាលកិរិយាស្លាប់ទៅ បានទៅកើតជាកូនក្សត្រ លុះមានវ័យវឌ្ឍនាការចំរើនធំឡើង បានចេញបព្វជ្ជាជាឥសិនីនៅក្នុងព្រៃ ហើយចម្រើនបានឈានជាលោកីយ៍ លុះធ្វើកាលកិរិយាទៅបានទៅកើតក្នុងព្រហ្មលោក លុះដល់ចុតិអំពី

ព្រហ្មលោកបានមកកើតជាកូនសេដ្ឋី លុះស្លាប់អំពីកូនសេដ្ឋីទៅកើតជាកូនជ្រូកស្រុក បានឃើញព្រះពុទ្ធអង្គមានចិត្តសោមនស្សត្រេកអរ លុះស្លាប់អំពីកូនជ្រូក បានទៅកើតជាកូនក្សត្រ ស្លាប់អំពីកូនក្សត្រ បានទៅកើតក្នុងស្រុកវាសិគ្រាម លុះស្លាប់អំពីនោះទៀត បានទៅកើតជាកូនពាណិជ, ស្លាប់អំពីកូនពាណិជ បានទៅកើតជាកូននាយសំពៅ, ស្លាប់អំពីកូននាយសំពៅ បានទៅកើតជាកូនអ្នកស្រុកអនុរាធបុរី, លុះស្លាប់អំពីទីនោះទៅទៀត បានទៅកើតជាកុដុម្ពិនីឈ្មោះនាងសុមនា ឯនាងសុមនានោះ លុះចម្រើនវ័យធំឡើង នាងក៏បានជាភរិយានៃអមាត្យស្តេច ។ ឯកស្មឹ សមយេ សម័យថ្ងៃមួយ ព្រះឧត្តរត្ថេរនាំព្រះសង្ឃចូលបិណ្ឌបាត បានឃើញនាងសុមនា ក៏ប្រាប់ភិក្ខុ-សង្ឃទាំងពួងថា កូនជ្រូកបានមកកើតក្នុងទីនេះហើយ ឯនាងសុមនាបានស្តាប់ថេរវាចាថា ខ្លួនជាកូនជ្រូកដូច្នោះ នាងនោះក៏មានចិត្តសង្វេគពន់ប្រមាណណាស់ ហើយនាងក៏មានចិត្តនឿយណាយចាកឃរាវាស ទើបលាស្វាមីចេញទៅបួសៗជាភិក្ខុនីរួចហើយ បានស្តាប់ធម៌ទេសនា លោកសំដែងអំពី

សតិបដ្ឋានទាំង ៤ ប្រការគឺៈ កាយ, វេទនា, ចិត្ត, ធម៌ ខំផ្ចង់សតិបញ្ញាចុះកាន់វិបស្សនាញាណ ហើយបានសម្រេចព្រះអរហត្ត កាត់កិលេសជាសមុច្ឆេទប្រហារ ផុតចាកកងទុក្ខទាំងពួងអស់ពីខន្ធសន្តាន លុះដល់ទីបំផុតនៃអាយុសង្ខារ រំលត់បញ្ចក្ខន្ធចូលកាន់ព្រះនិព្វានទៅ ។ លោកអ្នកដែលបានស្ដាប់ធម៌ទេសនាបរមត្ថសច្ចហើយ យកចិត្តទុកដាក់ខំរៀនឱ្យចាំខំគិតពិចារណាតាមឱ្យចូលចិត្តជាក់ច្បាស់ និងបានជាភាវនូបនិស្ស័យ សម្រេចព្រះអរហត្ត កាត់ចោលជាតិភពជាដើមចេញបាន, ដូចវត្ថុនិទាន ដែលបាននាំមកអធិប្បាយយ៉ាងនេះឯង ។

---

# មង្គលទី ២៧

ខន្តិ ច សេចក្ដីអត់ធន់ជាមង្គលដ៏ឧត្តម ។

អធិប្បាយៈ សេចក្ដីអត់ធន់ គឺមិនមានចិត្តក្រោធខឹងអាឃាតព្យាបាទចងពៀរដល់មនុស្សសត្វណាឡើយ, ឯសេចក្ដី

ក្រោធខឹងកើតឡើងដោយហេតុ ៩ យ៉ាងគឺៈ កើតដោយហេតុខ្លួនឯង ៣ កើតដោយហេតុស្រឡាញ់ ៣ កើតដោយហេតុស្អប់ ៣ (រួមជា ៩) ហៅថា អាឃាតវត្ថុ ៩ នេះ ថាតាមបាលីគឺពុទ្ធដីការាប់បញ្ចូល អដ្ឋានកោបៈ ១ ទៀតទៅជា ១០ ហៅតាមអដ្ឋកថាថាហេតុឱ្យកើតទោសមាន ១០ យ៉ាង ឬហេតុឱ្យកើតសេចក្តីក្រោធខឹងមាន ១០ យ៉ាង ។

ឯសេចក្តីក្រោធកើតឡើងដោយហេតុខ្លួនឯង ៣ នោះគឺៈ ខ្លួនគិតថា អ្នកនេះឯងបានប្រទូស្តដល់អញក្នុងកាលដែលកន្លងទៅហើយ ១, អ្នកនេះឯងបានប្រទូស្តដល់អញក្នុងគ្រាឥឡូវនេះ ១, អ្នកនេះឯងនឹងប្រទូស្តដល់អញទៅខាងមុខ ១ ។

សេចក្តីក្រោធខឹងដែលកើតឡើងដោយហេតុស្រឡាញ់ ៣ នោះគឺៈ គិតថាអ្នកនេះឯងបានប្រទូស្តដល់របស់ជាទីស្រឡាញ់នៃអញកន្លងទៅហើយ ១, អ្នកនេះឯងបានប្រទូស្តដល់របស់ជាទីស្រឡាញ់នៃអញក្នុងគ្រាឥឡូវនេះ ១, អ្នកនេះឯងនឹងប្រទូស្តដល់របស់ជាទីស្រឡាញ់នៃអញទៅខាងមុខ ១ ។

សេចក្តីក្រោធខឹងដែលកើតឡើងដោយហេតុស្អប់ ៣ នោះគឺៈ គិតថា អ្នកនេះឯងបានស្រឡាញ់របស់ដែលអញស្អប់កន្លង

ទៅហើយ ១, អ្នកនេះឯងបានស្រឡាញ់របស់ដែលអញទើបនឹងស្អប់ថ្មីៗ ១, អ្នកនេះឯងនឹងស្រឡាញ់ដល់របស់ដែលអញស្អប់ទៅខាងមុខ ១ (រួមជា ៩) រាប់បញ្ចូលអដ្ឋានកោបវត្ថុ គឺវត្ថុមិនគួរខឹង ដូចដី, ទឹក, ភ្លើង, ខ្យល់ ជាដើមចូល ១ ទៀត ត្រូវជាហេតុក្រោធមាន ១០ យ៉ាង ។

ហេតុដែលឱ្យកើតស្អប់-ស្រឡាញ់នេះ បើពោលដោយសង្ខេបមានត្រឹមតែពីរក្នុងហេតុមួយៗ ដូចនេះគឺៈ

១-បេមា ទោសោ ជាយតិ ស្អប់កើតពីស្រឡាញ់ ។

២-ទោសា ទោសោ ជាយតិ ស្អប់កើតពីស្អប់ ។

ហេតុដែលឱ្យកើតស្រឡាញ់មានពីរយ៉ាងគឺៈ

១-ទោសោ បេមំ ជាយតិ ស្រឡាញ់កើតពីស្អប់

២-បេមា បេមំ ជាយតិ ស្រឡាញ់កើតពីស្រឡាញ់ ។

ម្យ៉ាងទៀត លក្ខណៈនៃសេចក្តីក្រោធខឹងស្អប់មាន ៣ គឺៈ

១-បទុស្សតិ ទោសោ ខឹងស្អប់ប្រទូស្តដល់សត្វនិងសង្ខារហើយរលត់ទៅ,

២-បរហរតិ ឋោសោ ខឹងស្អប់ប្រហារដល់សត្វនិងសង្ខារ ដែលកន្លងទៅ,

៣-វេរានុវេរវសេន ឋោសោ ខឹងស្អប់ដោយអំណាចចងពៀរ ប្រទូស្តដល់សត្វនិងសង្ខារតទៅ ។

ឯទោសោ សេចក្តីស្អប់ខឹងប្រទូស្តនេះ លោកចែកជាពីរគឺៈ

១-អត្តជាបិ ទុស្សតិ ប្រទូស្តដល់ខ្លួនដោយខ្លួនឯងផង

២-បរស្សបិ ទុស្សតិ ប្រទូស្តដល់អ្នកដទៃផង ។

ទោសៈនេះមានឧបមាបីដូចភ្លើងឆេះ ក្នុងទីនេះហើយរាល ទៅឆេះក្នុងទីដទៃៗ ទៀត តៗ ទៅ ឥតកំណត់ទីភ្លើងឈប់ឆេះ នោះបានឡើយ ។ ឯភ្លើងគឺទោសៈដែលកើតឡើងហើយនេះ នឹងរលត់ទៅវិញបានដោយខន្តី គឺសេចក្តីអត់ធន់ ឬអត់សង្កត់ ចិត្តខឹងបានដោយសារការហាត់ចិត្តទុកមកច្រើនជាតិ ដូចរឿង ខន្តិវាទីតាបស គឺអង្គព្រះពុទ្ធជាម្ចាស់សាសនារបស់យើង កាល នៅជាពោធិសត្វបានឃើញទោសក្នុងគេហសិត ហើយលះ សម្បត្តិចេញបួសជាតាបសឥសីនៅក្នុងព្រៃហិមពាន្ត ខំចម្រើន

ឈានបានក៏ហោះមកដោយអាកាស មកនៅក្នុងឧទ្យានស្ដេចពារាណសី ។

ថ្ងៃមួយស្ដេចពារាណសី យាងទៅក្រសាលក្នុងឧទ្យានបានទស្សនាទតឃើញតាបសហើយសួរថា ព្រះករុណាខ្ជាប់ខ្លួនក្នុងអ្វី? តាបសក៏ឆ្លើយថា អាត្មាភាពខ្ជាប់ខ្លួនក្នុងខន្តី ស្ដេចទ្រង់សួរថាខន្តីគឺអ្វី? តាបសឆ្លើយថាខន្តីគឺសេចក្ដីអត់សង្កត់ចិត្តមិនខឹង មិនប្រទូស្តតបដល់អ្នកដែលប្រទូស្តដល់ខ្លួន ស្ដេចទ្រង់ព្រះសណ្ដាប់ហើយ ទើបត្រាស់បង្គាប់ថា បើដូច្នោះចូរអ្នកទាំងឡាយចាប់តាបសមកប្រហារហើយសួររកធម៌ខន្តី ជនទាំងឡាយក៏ធ្វើតាមព្រះរាជបង្គាប់ហើយសួររកខន្តី តាបសក៏ឆ្លើយដូចពាក្យដើមថា ខន្តីគឺសេចក្ដីអត់ធន់ ឬសេចក្ដីអត់សង្កត់ចិត្តមិនក្រោធខឹងនឹងអ្នកឯណា ស្ដេចក៏ឱ្យកាត់ដៃកាត់ជើងកាត់ច្រមុះហើយសួររកខន្តី តាបសក៏ឆ្លើយដូចពាក្យដើមថា ខន្តីមិនបានស្ថិតនៅនឹងដៃនឹងជើងនឹងច្រមុះនេះទេ គឺស្ថិតនៅក្នុងចិត្តទេតើ ស្ដេចក៏ទ្រង់ខ្ញាល់ខ្លាំង លើកព្រះបាទឡើងធាក់ត្រង់កណ្ដាលដើមទ្រូងតាបសឱ្យដួលផ្ងារទៅ ស្ដេចពារាណសីត្រឡប់ពីធាក់ព្រះពោធិសត្វ មកដល់ក្លោងទ្វារឧទ្យានវេលាណា ផែនដីក៏បែកសញ្ញែក

ស្រូបស្តេចពាលនោះ ទៅកាន់អវីចិមហានរកក្នុងវេលានោះឯង ចំណែកព្រះពោធិសត្វដោយទ្រង់សោយទុក្ខវេទនាខ្លាំង ក៏ធ្វើកាលកិរិយាទៅកើតក្នុងព្រហ្មលោកដោយផលនៃឈាន ដូចបានអធិប្បាយខាងដើមនោះឯង ៕

---

# មង្គលទី ២៨

**សោវចស្សតា** ភាពនៃខ្លួនជាបុគ្គលគឺគេប្រដៅងាយ ជាមង្គលដ៏ឧត្តម ។

អធិប្បាយថា: ភាពនៃខ្លួនជាបុគ្គលដែលគេប្រដៅងាយនោះ គឺមនុស្សនោះជាអ្នកស្តាប់បង្គាប់ ជាអ្នកធ្វើតាមឱវាទ ជាអ្នកមិនប្រកាន់ខ្លួន ជាអ្នកមានប្រាជ្ញា ជាអ្នកឈ្លាស ក្នុងកិច្ចពិចារណាហេតុនិងផល ជាអ្នកមិនងងឹតងងល់ជ្រុលជ្រប់ទៅក្នុងអំណាចអវិជ្ជា គឺជាអ្នកទទួលឱវាទនានាដោយគោរព ដូចរឿងពួកឈ្មួញសំពៅ ៥០០ នាក់ ចេញទៅជួញ លុះទៅដល់ពាក់កណ្តាលសមុទ្រក៏ធ្លាយសំពៅ ជនទាំងអម្បាលនោះក៏បបួលគ្នា

ហែលទឹកឡើងទៅអាស្រ័យនៅក្នុងកោះលង្កា, គ្រានោះ មាននាងយក្ខិនីទាំងឡាយ ក្លែងខ្លួននាំគ្នាដើររកប្រុសបញ្ឆោតទុកធ្វើជាស្វាមី ដោយឧបាយប្រាជ្ញានៃខ្លួន ។ ឯយក្ខិនីទាំងឡាយដែលតែងតែដើរបោកបញ្ឆោតប្រុសយកមកទុកធ្វើជាស្វាមីនោះ លុះបានប្រុសថ្មីមកធ្វើជាប្ដី ក៏នាំគ្នាស៊ីប្រុសចាស់នោះអស់ទៅ ដែលធ្វើមកដូច្នេះនេះ ជាយូរអង្វែងឆ្នាំណាស់មកហើយ ថ្ងៃមួយយក្ខិនីទាំងឡាយនោះ បានមកជួបប្រទះនឹងប្រុស ៥០០ នាក់ដែលធ្លាយសំពៅហើយហែលទៅនៅនឹងកោះលង្កានោះ ក៏យក្ខិនីទាំងអម្បាលនោះ និយាយបញ្ឆោតថាៈ ស្វាមីយើងទាំង-ឡាយទៅជួញដោយសំពៅៗ ធ្លាយកណ្ដាលសមុទ្ទ គាត់ក៏ស្លាប់អស់ហើយ យើងទាំងអម្បាលនេះ ជាស្ត្រីមេម៉ាយ ៣ ឆ្នាំហើយ អញ្ជើញអ្នកទាំងឡាយមកទៅនៅជាមួយនឹងយើងចុះ ពួកឈ្មួញទាំង ៥០០ នោះ បានឮដូច្នោះហើយក៏មានចិត្តសោមនស្សត្រេកអរ ហើយនាំគ្នាទៅនៅមូលរួមសង្វាលនឹងនាងយក្ខិនីនោះ លុះយូរបន្តិចទៅ ពាណិជជាធំបានឃើញអាការមិនស្រួល ទើបប្រឹក្សានឹងជនពួកឈ្មួញទាំងអម្បាលនោះថា អ្នកទាំងឡាយពួកយើងនឹងនៅក្នុងទីនេះមុខជាមិនស្រួល ហើយយល់ឃើញថា

នឹងមានអន្តរាយដល់ជីវិតទៅថ្ងៃមុខមិនលែងឡើយ ព្រោះស្រីទាំងអស់នេះសុទ្ធតែជាយក្ខិនីក្លែងធ្វើកលឧបាយបញ្ឆោតយើងទេ មិនមែនមនុស្សទេ ។ ពួកឈ្មួញទាំងអម្បាលនោះ ជនណាដែលប្រដៅងាយ ក៏ជឿតាមស្ដាប់យល់តាមពាក្យពាណិជជាធំព្រមព្រៀងគ្នាបាន ២៥០ នាក់ នៅសល់ ២៥០ នាក់ទៀត ជាមនុស្សមិនយល់ការណ៍ ដោយសារចិត្តជាប់ក្នុងកាមជាមនុស្សប្រដៅក្រ មិនព្រមយល់តាមក៏ក្រាញនៅក្នុងទីនោះទៅ, ឯពាណិជជាធំក៏នាំមនុស្សប្រដៅងាយ ២៥០ នាក់ រត់គេចខ្លួនចេញពីទីនោះទៅ គ្រានោះ ព្រះពោធិសត្វទៅកើតជាសេះពលាហកៈ នៅក្នុងកោះលង្កា បានឃើញពាណិជទាំងអម្បាលនោះដើរមកក៏សួរថាៈ អ្នកទាំងឡាយនាំគ្នាទៅណា ពាណិជទាំងឡាយប្រាប់ថាយើងខ្ញុំទាំងអស់គ្នានឹងទៅជម្ពូទ្វីប សេះពលាហកៈនោះក៏ពោលថា បើដូច្នោះអ្នកទាំងឡាយចូរមកនៅជាមួយនឹងយើងខ្ញុំៗ នឹងនាំទៅជូនទៅឱ្យដល់ត្រើយសមុទ្រ ឱ្យដល់ជម្ពូទ្វីបដូចបំណង ។ ពាណិជទាំងឡាយនោះត្រេកអរណាស់ ខ្លះឡើងជិះលើខ្នង ខ្លះតោងកន្ទុយសេះពលាហកៈនោះៗ ក៏ហោះចេញអំពីកោះលង្កាកាត់មសុទ្រ មកដល់ឆ្នេរ

កោះជម្ពូទ្វីប ហើយនាំជូនទៅដាក់ដល់គេហស្ថានទីទៃៗ, ឯមនុស្សដែលក្រាញនៅទាំង ២៥០ នាក់នោះ ក៏បានទៅជាចំណីយក្ខិនីទាំងអស់គ្នា ។ ឯមនុស្សដែលគេប្រដៅងាយ ក៏រមែងបានរួចខ្លួនពីសេចក្ដីស្លាប់ដូច្នេះ, ចំណែកពួកមនុស្សដែលគេប្រដៅក្រក៏រមែងបានសេចក្ដីអន្តរាយដល់ជីវិត ទៅជាអាហាររបស់យក្ខិនីដូចសេចក្ដីអធិប្បាយនាំរឿងរៀបរាប់មកយ៉ាងនេះឯង ៕

---

# មង្គលទី ២៩

*សមណានញ្ច ទស្សនំ* កិរិយាបានឃើញ បានជួបនូវសមណៈទាំងឡាយ ដែលមានឥន្ទ្រិយស្ងប់រម្ងាប់ហើយ ជាមង្គលដ៏ឧត្តម ។

អធិប្បាយថាៈ ការឃើញការមើលនេះមាន ២ យ៉ាងគឺ ចក្ខុទស្សនា ការមើលរូបដោយចក្ខុ ១, ញាណទស្សនំ កិរិយាឃើញដោយប្រាជ្ញាគឺឃើញធម៌ ជាផ្លូវប្រតិបត្តិឱ្យផុតចាកទុក្ខ គឺសីល, សមាធិ, បញ្ញា១ ។ ឯការមើលសមណៈលោកជាអ្នក

មានសីលមានធម៌ដោយបញ្ញាចក្ខុ ភ្នែកគឺប្រាជ្ញានោះ រមែងកើតនិស្ស័យចិត្តគិតដល់មគ្គផលនិព្វាន, ដូចមានរឿងដំណាលថាៈ

សម័យថ្ងៃមួយ ព្រះពុទ្ធអង្គគង់នៅឥន្ទសាលាគុហា គ្រានោះ មានសត្វមៀមមួយអាស្រ័យនៅក្នុងប្រទេសនោះ លុះបានឃើញព្រះពុទ្ធជាម្ចាស់ ក៏កើតចិត្តជ្រះថ្លាក្នុងព្រះអង្គ កាលបើព្រះពុទ្ធជាម្ចាស់ស្ដេចនិមន្តទៅបិណ្ឌបាត សត្វមៀមនោះក៏ហើរជូនតាមព្រះអង្គទៅ លុះដល់ពាក់កណ្ដាលផ្លូវទើបត្រឡប់មកវិញ មានកាលមួយនោះ មៀមឃើញព្រះពុទ្ធអង្គគង់នៅជាមួយនឹងភិក្ខុសង្ឃក្នុងពេលល្ងាច មៀមក៏ហើរចុះចូលទៅកណ្ដាលជំនុំសង្ឃ ហើយសម្របស្លាបទាំងឆ្វេងស្ដាំធ្វើអញ្ជលិកម្ម ថ្វាយបង្គំដោយស្លាបប្រណម្យក្បាលឱនចុះក្រោម ធ្វើនមស្សការសម្ដេចព្រះសាស្ដាចារ្យ និងភិក្ខុសង្ឃដោយគោរព ។ សម្ដេចព្រះពុទ្ធអង្គ ទ្រង់ទតឃើញអាការៈសត្វមៀមធ្វើដូច្នោះហើយ ក៏ព្រះអង្គទ្រង់ធ្វើព្រះឱស្ឋញញឹមឱ្យប្រាកដ ។ គ្រានោះ ព្រះអានន្ទឃើញព្រះអង្គញញឹមហើយ ក៏ក្រាបទូលសួរហេតុញញឹមឱ្យប្រាកដ ព្រះអង្គក៏ទ្រង់សម្ដែងព្យាករណ៍ប្រាប់ថាៈ ម្នាលអានន្ទសត្វមៀមនេះ មានចិត្តជ្រះថ្លាក្នុងយើងទាំងឡាយ ជាអ្នកមាន

សីល មានធម៌ ដោយគោរព មៀមនេះលុះទំលាយខន្ធពីសត្វមៀមទៅ នឹងបានទៅកើតក្នុងសុគតិភព ហើយអន្ទោលជាតិទៅមកតែក្នុងមនុស្ស និងទេពតានៅនាស្ថានសួគ៌នេះ អស់មួយសែនកប្ប លុះដល់ទីបំផុតជាតិ នឹងបានត្រាស់ជាព្រះបច្ចេកពុទ្ធមួយអង្គមាននាមថា សោមនស្សៈ ដោយផលដែលបានឃើញព្រះអរិយៈហើយជ្រះថ្លា ធ្វើនមស្សការដោយគោរពនេះឯង ។

សំដែងមកក្នុងសមណានញ្ច ទស្សនមង្គល អំពីការឃើញព្រះអរិយៈជាសមណៈទាំងឡាយ ដែលមានចិត្តស្ងប់រម្ងាប់ប្រកបដោយសីលនិងធម៌ដ៏បរិសុទ្ធប្រពៃ ហើយបានធ្វើសេចក្តីជ្រះថ្លាក្នុងសមណៈទាំងឡាយនោះ ក៏រមែងបានសម្រេចផលប្រយោជន៍ក្នុងជាតិនេះនិងជាតិខាងមុខ ដូចរឿងដែលបានអធិប្បាយមកយ៉ាងនេះឯង ៕

# មង្គលទី ៣០

កាលេន ធម្មសាកច្ឆា កិរិយាសន្ទនាសាកសួរនូវធម៌តាមកាល ជាមង្គលដ៏ឧត្តម ។

អធិប្បាយថាៈ ធម្មសាកច្ឆាកិរិយាសន្ទនាសាកសួរធម៌ដល់គ្នានឹងគ្នាទៅវិញទៅមក ដើម្បីរិះរកសេចក្តីប្រតិបត្តិឱ្យបានត្រឹមត្រូវតាមផ្លូវព្រះពុទ្ធសាសនា និងធ្វើកាយវាចាចិត្តឱ្យបរិសុទ្ធ ផុតចាកសេចក្តីសៅហ្មង ហើយធ្វើឱ្យត្រូវតាមកាលវេលាផង នោះលោកកំណត់ពាក្យដែលត្រូវពោលក្នុងធម៌នេះគឺ ទសកថាវត្ថុ ១០ យ៉ាង ពាក្យដែលមិនត្រូវយកមកពោលនោះគឺ តិរច្ឆានកថា ៣២ ប្រការ, ឯកាលដែលគួរពោលគួរសន្ទនាសាកសួរធម៌គ្នានោះ លោកំណត់យកកាលឧបោសថក្នុង១ខែមាន៨ថ្ងៃជាដើមទុកជាកាលគួរធ្វើធម្មសាកច្ឆា ពុទ្ធបរិស័ទអ្នកមានប្រាថ្នាចង់បានសេចក្តីចម្រើន ដោយការចេះដឹងធម៌វិន័យ ច្បាប់ព្រះពុទ្ធ-សាសនាក្តី ប្រាថ្នាដុសខាត់កាយវាចាចិត្តរបស់ខ្លួន ឬសីលដែលខ្លួនបានសមាទានហើយក្នុងថ្ងៃនោះក្តី ឬក៏ប្រាថ្នាបំពេញកិច្ចឧបោសថដោយការសាកសួរធម៌ ដោយការស្តាប់ធម៌ក្នុងថ្ងៃឧបោសថនោះ ឬថ្ងៃដទៃក្រៅអំពីថ្ងៃឧបោសថនោះក្តី គប្បីណាត់កាលវេលា គឺពេលដែលត្រូវមកប្រជុំគ្នានិងទីកន្លែងដែលត្រូវចូលទៅប្រជុំគ្នា មានទីវត្តអារាមជាដើម ព្រមទាំងត្រូវរើសរករូបលោកអ្នកប្រាជ្ញ ដែលចេះដឹងផ្លូវធម៌អាចក្នុងព្រះពុទ្ធសាសនា

មកប្រជុំជាមួយផង, បើធ្វើយ៉ាងនេះ ទើបហៅថា ប្រជុំធ្វើធម្មសាកច្ឆាបាន ។

ឯពួកលោកអ្នកស្តាប់ធម៌នោះទាំងអម្បាលម៉ាន ក៏កើតប្រាជ្ញា ព្រោះប្រាជ្ញានឹងការចេះដឹង កើតមកពីស្តាប់គេនិយាយប្រាប់ ១, កើតមកពីការគិតតាមពាក្យគេនិយាយពន្យល់ ១, កើតមកពីសាកសួរបញ្ជាក់រកហេតុ-ផលឱ្យឃើញច្បាស់ប្រាដក ១, កើតមកពីបានកត់ត្រាទុកបង្ការក្រែងភ្លេចភ្លាំងទៅវិញ ១ ទាំង ៤ យ៉ាងនេះ លោកទុកជាសម្បទានៃវិជ្ជា ។

ម្យ៉ាងទៀត លោកថាហេតុដែលឱ្យកើតប្រាជ្ញាមាន ៣ យ៉ាងគឺៈ ឧស្សាហ៍ស្តាប់គេនិយាយរឿយៗ មិនខ្ជិលស្តាប់ ១, ឧស្សាហ៍គិតតាមឮតាមឃើញរឿយៗ មិនខ្ជិលគិត ១, ឧស្សាហ៍ធ្វើភាវនាក្នុងការកុសលរឿយៗ មិនខ្ជិលធ្វើ ១, ទាំង ៣ យ៉ាងនេះ ជាថ្នាលសំណាបបណ្តុះពូជបញ្ញាឱ្យកើតឡើងបាន អាចនឹងយកទៅផ្តាច់បង់នូវកងវិចិកិច្ឆា គឺសេចក្តីសន្ទិះសង្ស័យមិនចេះដាច់ស្រេច ឱ្យដាច់ស្រឡះបាន, ឯការសាកសួរធម៌គ្នានេះជាការប្រពៃ សូម្បីព្រះមោគ្គល្លានក៏មានសាកសួរធម៌ព្រះសារីបុត្រៗ ក៏មានការសាកសួរបញ្ហាធម៌នឹងព្រះមោគ្គល្លាន

ដោយរឿងដែលសត្វស្លាប់ទៅសោយសុខ-ទុក្ខក្នុងស្ថានសួគ៌ ស្ថាននរកជាដើម ឱ្យអ្នកស្តាប់អស់សង្ស័យ ។

ឯធម្មសាកច្ឆានេះ រមែងកាត់បង់នូវសេចក្តីសង្ស័យបានផង រមែងនាំឱ្យមានប្រាជ្ញាបានត្រាសដឹងនូវមគ្គនិងផលបានផង ដូចរឿងព្រាហ្មណ៍ម្នាក់ឈ្មោះអទិន្នបុព្វកៈ មានសេចក្តីសង្ស័យក្នុងពុទ្ធគុណ ក៏ទូលសួរព្រះសាស្តាថា បុគ្គលមិនដែលបានឱ្យទាន មិនដែលបានរក្សាសីល មិនដែលបានធ្វើភាវនាម្តងណាសោះ ហើយគ្រាន់តែមានចិត្តជ្រះថ្លាក្នុងគុណព្រះសាស្តាប៉ុណ្ណោះ លុះស្លាប់បានទៅកើតស្ថានសួគ៌ខ្លះឬទេ? ព្រះសាស្តាសំដែងថា ម្នាលព្រាហ្មណ៍ បុគ្គលគ្រាន់តែមានចិត្តជ្រះថ្លាក្នុងតថាគត ហើយស្លាប់បានទៅកើតក្នុងស្ថានសួគ៌នោះ នឹងរាប់ថាដប់ថាម្ភៃ ថាមួយរយ ថាមួយពាន់ ថាមួយម៉ឺន ថាមួយសែនដូច្នេះពុំបានឡើយ គឺមានច្រើនជាអនេកដូចជាមដ្ឋកុណ្ឌលីកូនអ្នកឯង ដែលញុំាងចិត្តឱ្យជ្រះថ្លាក្នុងរស្មីតថាគត ហើយស្លាប់ទៅកើតក្នុងស្ថានត្រ័យត្រិង្ស មានវិមានមាសកំពស់ ៣០ យោជន៍ មានស្រីទេព-អប្សរមួយពាន់ជាបរិវារនោះដែរ ។ កាលព្រះសាស្តាត្រាស់ទេសនាប្រាប់ព្រាហ្មណ៍តែប៉ុណ្ណោះ ក៏ទ្រង់អធិដ្ឋានឱ្យមដ្ឋកុណ្ឌលី

ទេវបុត្រនោះចុះមកទាំងវិមានយ៉ាងល្អអស្ចារ្យ ហើយចាកវិមាន ចូលទៅថ្វាយបង្គំគាល់ព្រះសាស្តាៗ សួរថា ម្នាលទេវបុត្រពីជាតិ មុននោះអ្នកបានធ្វើបុណ្យដូចម្តេច ទើបបានវិមាននិងស្រីទេព-អប្សរដ៏បវរដូច្នេះ ។ ទេវបុត្រនោះ ក៏លើកហត្ថឡើងប្រណម្យ ថ្វាយបង្គំទូលព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ នេះគ្រាន់តែមានចិត្តជ្រះថ្លាក្នុងរស្មីព្រះអង្គប៉ុណ្ណោះ លុះទម្លាយ បញ្ចក្ខន្ធទៅ ក៏ទៅកើតក្នុងស្ថានត្រ័យត្រិង្សសួគ៌សោយទិព្វ-សម្បត្តិដូចនេះឯង លុះព្រះអង្គសាកសួរចប់ធម្មសាកច្ឆា ព្រាហ្មណ៍ជាបិតាព្រមទាំងទេវបុត្រ ក៏បានសម្រេចសោតាបត្តិ-ផល ពួកមហាជនក៏បានដល់នូវធម្មាភិសម័យជាច្រើនគ្នា, ឯ ផលនៃការធ្វើធម្មសាកច្ឆា ដូបានអធិប្បាយមកនេះឯង ៕

---

## មង្គលទី ៣១

តបោ ៥ សេចក្តីព្យាយាមដុតនូវបាបធម៌ គឺញុំាងកិលេស ដែលនៅក្នុងខន្ធសន្តានឱ្យក្តៅរីងស្ងួតបានជាមង្គលដ៏ឧត្តម ។

អធិប្បាយថាៈ សេចក្តីព្យាយាមធ្វើកងការកុសលផ្សេងៗ គឺធ្វើទានរក្សាសីល ធ្វើភាវនាក្តី ស្តាប់ធម៌ទេសនាធ្វើពុទ្ធបូជា ធម្ម-បូជា សង្ឃបូជាក្តី ឬចេញបួសជាបព្វជិតក្នុងព្រះពុទ្ធសាសនាក្តី ហៅថា តបោ ប្រែថាព្យាយាមញុាំងកិលេសឱ្យក្តៅ គឺព្យាយាមដុតបំផ្លាញចោលនូវបាបធម៌ទាំងឡាយ មានរាគៈជាដើម ឬថាចម្រាញ់នូវខ្លាញ់គឺកិលេសឱ្យចេញចាកចិត្តបាប បីដូចជាគេចម្រាញ់ខ្លាញ់ជ្រូក ឱ្យចេញចាកក្រសោមខ្លាញ់បាន ដោយកំដៅភ្លើងដូច្នោះដែរ, ឯពាក្យដែលហៅថាកិលេសៗនោះ មានច្រើនប្រការ ប៉ុន្តែតួកិលេសធំៗ ដែលជាមេគេមានត្រឹមតែ ៣ គឺរាគៈ ១, ទោសៈ ១, មោហៈ ១ ។ បណ្តាកិលេសទាំងអស់នេះ កើតមកអំពីសុភនិមិត្តអំពីសុភសញ្ញា ទើបញុាំងសមុទ័យគឺតណ្ហាទាំង ១០៨ ឱ្យកើតឡើងព្រមផង ។

បុគ្គលដែលព្យាយាមនឹងរំលត់កិលេសតណ្ហាទាំងអស់នេះបាន ត្រូវព្យាយាមតាមផ្លូវសម្បទា ៤ យ៉ាងគឺៈ ព្យាយាមបិទភ្ជិតបាបថ្មីមិនឱ្យកើតឡើងក្នុងសន្តានបាន ដោយការមានសតិសង្រួមរវាំងទោសក្នុងឥន្ទ្រិយទាំង ៦ គឺ ភ្នែកឃើញរូបក្តី

ត្រចៀកឮសម្លេងក្តី ច្រមុះធុំក្លិនក្តី អណ្តាតដឹងរសក្តី កាយដឹងសម្ផស្សក្តី ចិត្តដឹងធម៌ក្តី ធ្វើចិត្តឱ្យនៅនឹងជាកណ្តាលមិនឱ្យស្អប់មិនឱ្យស្រឡាញ់ឡើយ គឺត្រូវមានសតិសំវរៈនៅគ្រប់ទ្វារទាំង ៦ សង្រួមបិទមិនឱ្យបាបថ្មីចូលមកទៀតបាន ហៅថាសំវរប្បធាន ១, ព្យាយាមបាចស្តារបាបចាស់ដែលធ្លាប់មានដក់ត្រាំនៅក្នុងចិត្តស្រាប់មកយូរហើយ ឱ្យចេញចាកចិត្តបាន ហៅថាបហានប្បធាន ១, ព្យាយាមធ្វើបុណ្យថ្មីដែលមិនទាន់មានដូចទាន-សីលជាដើម ធ្វើឱ្យកើតមានឡើង ហៅថាភាវនាបធាន ១, ព្យាយាមរក្សាបុណ្យកុសលចាស់ដែលធ្លាប់មានមកស្រាប់ និងថែរក្សាបុណ្យថ្មី ដែលទើបនឹងមានឱ្យគង់នៅបាន ហៅថាអនុរក្ខនាបធាន ១ (រួមជា ៤) ព្យាយាម ៤ យ៉ាងនេះឯងហៅថាតបោ ដែលប្រែមកហើយថា ព្យាយាមដុតកំដៅបាប ឬកិលេសឱ្យរីងស្ងួតចាកខន្ធសន្តានបាន ។

ម្យ៉ាងទៀតបាប គឺអំពើអាក្រក់ទាំងអម្បាលម៉ាន ដែលកើតឡើងមិនបាន ដោយសារបុគ្គលនោះមាន ហិរិ និង ឱត្តប្បៈ គឺសេចក្តីខ្មាសនិងសេចក្តីតក់ស្លុតខ្លាចក្នុងការបាប បានពិចារណាដោយឧបាយនៃបញ្ញា គឺសមថៈនិងវិបស្សនា ។ កាលបើហិរិនិង

ឱត្តប្បៈមិនមានហើយ ឥន្ទ្រិយសំវរៈក៏មិនមានផង បើឥន្ទ្រិយ-សំវរៈមិនមានហើយ សីលក៏មិនមានផង នឹងដាច់ចាកនិស្ស័យក្នុងព្រះពុទ្ធសាសនា ។ ម្យ៉ាងទៀតថា បើសីលមិនមានហើយ សម្មាសមាធិមិនមានផង បើសម្មាសមាធិមិនមានហើយ វិបស្ស-នាបញ្ញាក៏មិនមានផង នោះនឹងដាច់ចាកនិស្ស័យមគ្គផលព្រះនិព្វាន, លោកអ្នកដែលមានតបៈគឺព្យាយាមល្អ រមែងបានសម្រេចមគ្គផលមិនខាន ដូចវត្ថុនិទានពីរឿងព្រាហ្មណ៍ម្នាក់បានឃើញភិក្ខុសង្ឃទាំងឡាយឃ្លុំចីពរៗ ក៏ទទឹកទៅដោយទឹកសន្សើម ដែលជាប់នៅលើចុងស្មៅ ព្រាហ្មណ៍ក៏ជម្រះស្មៅនៅទីនោះឱ្យស្អាតរលីងឥតស្មៅ លុះព្រឹកឡើង ឃើញភិក្ខុឃ្លុំចីពរៗប្រឡាក់ចុងជាយដោយធុលីដី ព្រាហ្មណ៍នោះ ក៏យកខ្សាច់មកចាក់រាយវាចឱ្យពេញរាបស្មើ, លុះថ្ងៃក្រោយមកទៀត ព្រាហ្មណ៍ឃើញភិក្ខុទាំងឡាយគង់ឆាន់ចង្ហាន់ត្រូវក្តៅ ព្រាហ្មណ៍ក៏ធ្វើសាលាសម្រាប់ឆាន់ប្រក់ស្លឹកមួយប្រគេន លុះយូរទៅសាលានោះចាស់គ្រាំគ្រា ភ្លៀងមកលេចទទឹកចីពរព្រះសង្ឃ ព្រាហ្មណ៍ក៏រកឈើមកធ្វើសាលាថ្មីមួយទៀតព្រះគេនព្រះសង្ឃ នៅវេលាធ្វើបុណ្យឆ្លងសាលា ព្រាហ្មណ៍ក៏និមន្តព្រះសាស្តានិងព្រះសង្ឃ

ធ្វើភត្តកិច្ចរួចស្រេច ព្រះសាស្តាទ្រង់ទេសនាសរសើរអានិសង្ស សាលា ដែលព្រាហ្មណ៍ជ្រះថ្លាធ្វើប្រគេនព្រះសង្ឃថា មានផល ច្រើនក្រៃលែង លុះចប់ធម៌ទេសនា ព្រាហ្មណ៍នោះ ក៏បាន សម្រេចសោតាបត្តិផល ដោយអំណាចកុសលពីបុព្វជាតិ និង បច្ចុប្បន្នផ្សំគ្នាជួយគាំពារព្រាហ្មណ៍ឱ្យបានសុខចំរើនៗ ឡើង រាល់ៗ ជាតិ ដរាបដល់បានសម្រេចមគ្គផលព្រះនិព្វាន ។ លោក អ្នកដែលមានព្យាយាមមិនដាក់ធុរៈចោល ក្នុងការកុសលណា មួយៗ ដែលខ្លួនកាន់ រមែងបានសម្រេចមគ្គផលព្រះនិព្វាន ដូច អធិប្បាយមកនេះឯង ៕

---

# មង្គលទី ៣២

ព្រហ្មចរិយញ្ច កិរិយាប្រព្រឹត្តនូវធម៌ដ៏ប្រសើរ ជាមង្គល ដ៏ឧត្តម ។

អធិប្បាយថាៈ ធម៌ដ៏ប្រសើរហៅថាព្រហ្មចរិយៈៗ នោះ មាន ២ យ៉ាងគឺៈ សាសនព្រហ្មចរិយៈ បានដល់សីល សមាធិ

បញ្ញា ១, មគ្គព្រហ្មចរិយៈ បានដល់មគ្គ-ផល ១ ។ ព្រហ្មចរិយៈដែលប្រែថាប្រសើរ ព្រោះមិនធ្វើអសទ្ធម្មជាដើម តួយ៉ាងដូចពុទ្ធបរិស័ទអ្នករក្សាឧបោសថសីលទាំង ៣ កាលណាមួយគឺៈ

១-បកតិឧបោសថ ឧបោសថប្រក្រតី ក្នុង ១ ខែមានកាលរក្សា ៨ ថ្ងៃ គឺថ្ងៃ ៥ កើត ៨ កើត ១៤ កើត ១៥ កើត និងថ្ងៃ ៥ រោច ៨ រោច ១៤ រោច ១៥ រោច រួមជា ៨ ថ្ងៃ (ខាងរនោចបើខែ ខ្វះថ្ងៃ ១៤ រោចថយមកនៅត្រឹមថ្ងៃ ១៣ វិញ ថ្ងៃ ១៥ រោចថយ មកនៅត្រឹមថ្ងៃ ១៤ វិញ ) ។

២-បដិជាគរឧបោសថ ឧបោសថរលឹកតបតាមអមថ្ងៃអង្គនៃបកតិនោះ ក្នុង ១ ខែ មានកាល ១១ ថ្ងៃ គឺថ្ងៃ ៤ កើត ៧ កើត ១៣ កើត និងថ្ងៃ ៤ រោច ៧ រោច ១៣ រោច ទាំង ៦ ថ្ងៃនេះនៅខាងដើមបកតិ ហៅថាថ្ងៃទទួលរក្សាសិក្ខាបទ ៨ អស់ ១ ថ្ងៃ ១ យប់ ដូចបកតិដែរ ប៉ុន្តែ មិនមានកិច្ចសមាទានទេ, ថ្ងៃ ៦ កើត ៩ កើត និងថ្ងៃ ១ រោច ៦ រោច ៩ រោច ទាំង ៥ នេះទៅខាងចុងថ្ងៃបកតិ ហៅថាជូនដំណើរ ត្រូវរក្សាសិក្ខាបទគ្រប់ទាំង ៨ ថែម ១ ថ្ងៃ ១ យប់ទៀត ។

៣-ចាដិហារិយបក្ខឧបោសថ លោកកំណត់យកខែក្នុងរដូវភ្លៀង ៥ ខែជាកាល គឺរាប់ពីថ្ងៃ ១ រោចខែអាសាធទៅទល់នឹង ១៥ កើតខែកត្តិក បើរាប់ជាថ្ងៃបាន១១៨ថ្ងៃប៉ុណ្ណោះ ។

ឯបាដិហារិយបក្ខឧបោសថនេះ មិនមានកិច្ចសមាទានឡើយ ។ ក្នុងវណ្ណនានៃរាជសូត្រប្រាប់ថា ចាដិហារិយបក្ខោ ជាម អន្តោវស្សេ តេមាសំ និពទ្ធុបោសថោ ឧបោសថដែលបុគ្គលរក្សាជាប់មិនដាច់អស់ ៣ ខែក្នុងវស្សា ឈ្មោះថាបាដិហារិយ-បក្ខឧបោសថ, បើបុគ្គលមានសទ្ធារក្សាអស់កាល ៥ ខែក៏ប្រពៃពេក បើមិនអាចរក្សាទេ នឹងរក្សាតែ ១ ខែ គឺរាប់ពីថ្ងៃ ១ រោចខែអស្សុជទៅទល់នឹងថ្ងៃពេញបុណ្ណមីខែកត្តិកក៏បាន ឬនឹងរក្សាតែកន្លះខែរាប់ពីថ្ងៃ ១ រោចខែអស្សុជទៅទល់នឹងថ្ងៃ ១៤ រោចខែអស្សុជប៉ុណ្ណោះក៏បាន ឈ្មោះថាបាដិហារិយបក្ខឧបោសថដូចគ្នា តាមស្ម័គ្រចិត្តអ្នកមានសទ្ធាចង់រក្សា មិនឃើញមានច្បាប់បង្គាប់ថាត្រូវរក្សាសិក្ខាបទទាំង ៨ គ្រប់ថ្ងៃទាំងអស់ទេ, ឯច្បាប់ហាមឃាត់ក៏គ្មានដែរ បើតាមន័យខាងលើនេះ គ្រាន់តែរក្សាបដិ-ជាគរៈឧបោសថជាប់រាល់ថ្ងៃគ្រប់ ៣ ខែ ក៏ឡើងទៅជាបាដិ-

ហារិយបក្ខឧបោសថហើយ ។ រួមសីលក្នុងឧបោសថទាំងអស់នេះឱ្យឈ្មោះថាសាសនព្រហ្មចរិយៈ ។ ឯមគ្គព្រហ្មចរិយៈនោះបានដល់មគ្គ ៤ ផល ៤ ដែលរំលត់ភ្លើងទុក្ខ គឺជាតិ ជរា ព្យាធិ មរណៈ និងភ្លើងកិលេសគឺរាគៈ ទោសៈ មោហៈបាន ឯផលនៃព្រហ្មចិរយៈទាំង ២ នេះ គួយ៉ាងដូចនិទានកូនឈ្នួលអនាថ-បិណ្ឌិកសេដ្ឋីម្នាក់ បុរសនោះបានរក្សាតែអឌ្ឍុបោសថប៉ុណ្ណោះលុះស្លាប់បានទៅកើតជាអារុក្ខទេវតា នៅនឹងដើមជ្រៃមួយដើមប្របផ្លូវ ។ ថ្ងៃមួយមានពួកឥសីមកពីព្រៃហិមពាន្តចូលមកជ្រកម្លប់ជ្រៃនោះ ហើយសូមទឹកដោយពាក្យថាៈ ជ្រៃនេះទំនងជាមានទេវតាអាស្រ័យនៅ បើមានមែន សូមឱ្យបណ្ដាលទរទឹកហូរចេញមក ចែកយើងទាំងឡាយបរិភោគផង ទេវតានោះឮហើយក៏អធិដ្ឋានជ្រៃឱ្យមានទរទឹកហូរចេញមកតាមមែក ប្រគេនពួកឥសីដោយឫទ្ធានុភាពខ្លួន បានពីផលនៃឧបោសថ ទរទឹកក៏ហូរចេញតាមមែកជ្រៃជាប្រាកដ ។ កាលបើពួកឥសីប្រាថ្នាអាហារទេវតានោះក៏បណ្ដាលឱ្យកើតអាហារ, កាលបើពួកឥសីទាំង-ឡាយនោះ ប្រាថ្នាសំពត់ស្លៀកដណ្ដប់ ទេវតាក៏បណ្ដាលឱ្យកើតសំពត់ស្លៀក-ដណ្ដប់ ប្រគេនដល់ពួកឥសីបានតាមប្រាថ្នា,

លុះពួកឥសីទាំងឡាយនោះ ចង់ឃើញរូបទេវតាៗ ក៏បណ្តាលឱ្យឃើញរូបដ៏ល្អបាន, ពួកឥសីសួរចង់ដឹងផលបុញ្ញកម្មដូចម្តេចដែលខ្លួនបានធ្វើមកពីជាតិមុន? ទេវតានោះ ក៏មានលញ្ឆមានភាព ប្រាប់ដល់ពួកឥសីថា: បុញ្ញកម្មនៃខ្ញុំនេះបន្តិចបន្តួចណាស់ គឺពីជាតិមុន កាលនៅជាមនុស្សកម្មករអនាថបិណ្ឌិកសេដ្ឋី ខ្ញុំគ្រាន់តែបានរក្សាសីលឧបោសថកន្លះថ្ងៃ ក្នុងសំណាក់សេដ្ឋី ហើយស្លាប់មកកើតជាទេវតានេះ ។

ព្រោះហេតុនោះ ពុទ្ធបរិស័ទទាំងឡាយ គួរពិចារណាឱ្យឃើញផលអស្ចារ្យនៃឧបោសថ អាចផ្ទេរជាតិមនុស្សទៅកើតជាទេវតាបាន, គួរណាស់ហើយតែយើងរាល់គ្នាខំឆ្លៀតយកឱកាសល្អ ដែលខ្លួនកើតមកបានជួបប្រទះនឹងព្រះពុទ្ធសាសនា ទុកថាខ្លួនមានភ័ព្វសំណាង ព្រោះសេចក្តីស្លាប់សម្រាប់រូប នៅប្រែចាំការគ្រប់ដង្ហើមចេញ-ចូល រាល់ថ្ងៃនិងយប់គ្រប់វេលា គួរលោករាល់គ្នាទោះជាអ្នកធ្វើស្រែចម្ការក្តី អ្នកធ្វើរបរជំនួញក្តី អ្នកធ្វើការឈ្នួលក្តី អ្នកធ្វើការបម្រើរាជការផែនដីក្តី រៃលេលករកឧបាយធ្វើកុលស គឺសីលជាយាន ទានជាស្បៀង ទុកបង្ការផ្លូវទៅមុខឱ្យហើយ ទោះបីតិចច្រើនកុំឱ្យខកខានខូចវេលា ធ្វើទាន សីល

ភាវនា ដើម្បីនឹងបានជាឧបនិស្ស័យទៅកាន់ព្រះនិព្វាន ជាស្ថានបរមសុខក្សេមក្សាន្ត ដូចបានអធិប្បាយមកនេះឯង ។

---

# មង្គលទី ៣៣

អរិយសច្ចាន ទស្សនំ កិរិយាឃើញនូវអរិយសច្ចទាំងឡាយ ជាមង្គលដ៏ឧត្តម ។

អធិប្បាយថាៈ អរិយសច្ចមាន ៤ ប្រការគឺៈ ទុក្ខសច្ច ១, សមុទយសច្ច ១, និរោធសច្ច ១, មគ្គសច្ច ១ (ត្រូវជា៤ប្រការ)។

ឯទុក្ខសច្ចនោះ ជាផលបានដល់ជាតិទុក្ខ ជរាទុក្ខ ព្យាធិទុក្ខ មរណទុក្ខជាដើម ចាត់ជានិពន្ធទុក្ខ ឬចាត់ជាភ្លើងទុក្ខ, ពួកទុក្ខនេះមាន ១២ ប្រការ បើថាឱ្យខ្លីចុះមានតែ ១ គឺសង្ខិត្តេនបញ្ចុបាទានក្ខន្ធាបិទុក្ខា ជាកំពូលទុក្ខធំ ដែលប្រជុំចុះនូវទុក្ខទាំង-ពួង លោកសំដៅយកឧបាទានក្ខន្ធទាំង ៥ នេះគឺៈ រូបូបាទានក្ខន្ធ ១, វេទនូបាទានក្ខន្ធ ១, សញ្ញូបាទានក្ខន្ធ ១, សង្ខារូបាទានក្ខន្ធ

១, វិញ្ញាណូបាទានក្ខន្ធ ១ (រួមជា ៥) ទុក្ខទាំង ៥ កងនេះ ជាកំពូលនៃទុក្ខទាំងពួង ឬជាមេទុក្ខធំជាងទុក្ខទាំងអស់ ។

ឯសមុទយសច្ចនេះ ជាហេតុបានដល់តណ្ហាទាំង ៣ គឺៈ កាមតណ្ហា ១, ភវតណ្ហា ១, វិភវតណ្ហា ១ (រួមជា ៣) ។ ឯកាមតណ្ហានោះ គឺសេចក្ដីប្រាថ្នាក្នុងកាមភព ១១ ជាន់ ដែលប្រើកាមគុណ ៥ គឺៈ រូប ១, សម្លេង ១, ក្លិន ១, រស ១, សម្ផស្ស ១ (រួមជា ៥) ។ ភវតណ្ហា គឺសេចក្ដីប្រាថ្នាក្នុងរូបភព ១៦ ជាន់ គឺព្រហ្មដែលមានរូប ។ វិភវតណ្ហា គឺសេចក្ដីប្រាថ្នានៅក្នុងអរូបភព ៤ ជាន់ គឺព្រហ្មដែលមិនមានរូប ។ តណ្ហានេះ ចាត់ជាខាងក្នុងមាន ៦ គឺៈ ភ្នែក ១, ត្រចៀក ១, ច្រមុះ ១, អណ្ដាត ១, កាយ ១, ចិត្ត ១ ។ ខាងក្រៅមាន ៦ គឺៈ រូប ១, សម្លេង ១, ក្លិន ១, រស ១, សម្ផស្ស ១, ធម៌ ១ (រួមជា ១២ ) ។ លោកយកតណ្ហាទាំងក្នុងទាំងក្រៅ ១២ នេះគុណនឹងកាល ៣ គឺៈ អតីតកាលមានតណ្ហា ១២, បច្ចុប្បន្នកាលមានតណ្ហា ១២, អនាគតកាលមានតណ្ហា ១២ បូករួមចូលគ្នាជា ៣៦, ចាត់ជាកាមតណ្ហា ៣៦ ភវតណ្ហា ៣៦ វិភវតណ្ហា ៣៦ (បូករួមចូលគ្នាត្រូវជា ១០៨) ហៅថាតណ្ហា ១០៨ ។ តណ្ហានេះជាហេតុ គឺដើមញុំាងទុក្ខជា

ផល គឺផ្លែឱ្យកើតឡើង ប្រៀបដូចជាផ្លែឈើទាំងពួងតោងជាប់ទៅពីមែកពីដើម, កាលបើបុគ្គលកាប់គាស់ដើមព្រមទាំងឫសអស់ហើយ ផ្លែឈើនោះក៏គ្មានដែរ, ឯផលគឺទុក្ខទាំងពួង ក៏តោងជាប់ទៅពីសមុទយៈដូច្នោះដែរ, កាលបើសមុទយៈ គឺតណ្ហាទាំង ១០៨ អស់ហើយ ទុក្ខក៏រលត់ ។

ឯនិរោធសច្ច គឺសេចក្ដីរលត់ ឬទីដែលរលត់ទុក្ខគឺនិព្វាន ឬទីដែលនាំចេញនូវតណ្ហាទាំង ១០៨ ឱ្យអស់ដោយសច្ឆិកាតព្វកិច្ចធម៌ គឺអរហត្តផលវិមុត្តិ កាត់ឫសតណ្ហាឱ្យផុតចាកចិត្តចេញបាន ។

ឯមគ្គសច្ច បានដល់មគ្គដែលប្រកបដោយអង្គ ៨ ប្រការគឺ:

១-សម្មាទិដ្ឋិ បញ្ញាឃើញត្រូវ ៤ យ៉ាង គឺឃើញផលនៃទុក្ខទាំង ១២ កង ១, ឃើញហេតុដែលនាំឱ្យទុក្ខកើតឡើង ១, ឃើញផលគឺនិព្វានជាទីរលត់ទុក្ខ ១, ឃើញហេតុគឺ សីល សមាធិ បញ្ញា ជាសេចក្ដីប្រតិបត្តិដែលធ្វើឱ្យទុក្ខរលត់ ១ (រួមជា ៤ ប្រការ) ។

២-សម្មាសង្កប្បៈ សេចក្តីត្រិះរិះត្រូវល្អប្រពៃមាន ៣ យ៉ាង គឺៈ រិះគិតនឹងចេញចាកកាម ១, សេចក្តីរិះគិតនឹងមិនព្យាបាទដល់សត្វដទៃ ១, រិះគិតនឹងមិនបៀតបៀនដល់សត្វដទៃ ១ (រួមជា ៣) ។

៣-សម្មាវាចា ពោលពាក្យត្រូវមាន ៤ យ៉ាងគឺៈ មិននិយាយកុហក ១, មិននិយាយស៊កសៀតញុះញង់អ្នកដទៃ ១, មិននិយាយពាក្យអាក្រក់ជូជាតិ ១, មិននិយាយរោយរាយឥតប្រយោជន៍ ១ (រួមជា ៤) ។

៤-សម្មាកម្មន្តៈ ធ្វើការងារត្រូវប្រពៃមាន ៣ យ៉ាងគឺៈ មិនសម្លាប់សត្វ ១, មិនលួចទ្រព្យអ្នកដទៃ ១, មិនលួចប្រពន្ធកូនគេ ១ (រួមជា ៣) ។

៥-សម្មាអាជីវៈ ចិញ្ចឹមជីវិតត្រូវមាន ៥ យ៉ាងគឺៈ មិនលក់មនុស្ស ១, មិនលក់សត្វមានជីវិត ១, មិនលក់គ្រឿងសស្ត្រាវុធ ១, មិនលក់ទឹកស្រវឹងឬគ្រឿងស្រវឹង ១, មិនលក់ថ្នាំពិសសំរាប់បំពុលគេឱ្យស្លាប់ ១ (រួមជា ៥) ។

៦-សម្មាវាយាមៈ ព្យាយាមត្រូវល្អប្រពៃមាន ៤ យ៉ាងគឺៈ រវាំងបាបថ្មីដែលមិនទាន់កើតមិនឱ្យកើតឡើងបាន ១, បាបចាស់ដែលមានហើយ ព្យាយាមលះបង់បាបនោះចេញ ១, កុសលដែលមិនទាន់កើត ព្យាយាមធ្វើឱ្យរីតតែចំរើនឡើង ១ (រួមជា ៤) ។

៧-សម្មាសតិ រលឹកត្រូវមាន ៤ យ៉ាងគឺៈ រលឹកដល់កាយខាងក្នុងនិងកាយខាងក្រៅ ១, រលឹកដល់វេទនាខាងក្នុង និងវេទនាខាងក្រៅ១, រលឹកចិត្តខាងក្នុងនិងចិត្តខាងក្រៅ ១, រលឹកដល់ធម៌ខាងក្នុងនិងធម៌ខាងក្រៅ ១ (រួមជា ៤) ។

៨-សម្មាសមាធិ ចិត្តខ្ជាប់ខ្ជួនហ្នឹងនៅក្នុងអារម្មណ៍នៃកម្មដ្ឋាន បើជាបឋមជ្ឈានប្រកបដោយអង្គ ៥ គឺៈវិតក្កៈកៀងចិត្តលើកផ្គងឡើងកាន់កម្មដ្ឋាន១, វិចារៈ ពិចារណាអង្គកម្មដ្ឋាន ១, បីតិ សេចក្ដីត្រេកអរឆ្អែតកាយឆ្អែតចិត្ត ១, សុខៈ សេចក្ដីសុខស្រួលកាយស្រួលចិត្ត ១, ឯកគ្គតា ភាពចិត្តតាំងនៅហ្នឹងខ្ជាប់ខ្ជួនក្នុងអារម្មណ៍ជាសមាធិ ១ (រួមជា ៥) ។

ឯមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរជាដំណើរទៅកាន់ទីគឺព្រះនិព្វាន តាមលំអានផ្លូវ សីល សមាធិ បញ្ញានេះ មាននៅក្នុងផ្ទៃអរិយសច្ច ៤ អាចធ្វើខ្លួនឱ្យអ្នកប្រតិបត្តិតាមឱ្យត្រាស់ដឹងបាន ដូចមានដំណាលពីរឿងយសកុលបុត្រ នៅក្នុងនគរពារាណសី មិនមានសេចក្ដីត្រេកអរក្នុងកាមគុណ ហើយរត់ចេញពីផ្ទះទាំងយប់ ទៅកាន់សំណាក់ព្រះសាស្ដា ក្នុងព្រៃឥសិបតនមិគទាយវ័ន គ្រានោះព្រះសាស្ដាព្រះអង្គទេសនាប្រោសយសកុលបុត្ត ឱ្យកើតបញ្ញាពិចារណាអរិយសច្ចធម៌ ៤ ក៏បានសម្រេចសោតាបត្តិ-ផល លុះព្រឹកឡើងសេដ្ឋីជាបិតាទៅតាមរកបុត្រក្នុងទីនោះ បានជួបនឹងព្រះអង្គៗ ក៏សម្ដែងធម៌ទេសនា ញ៉ាំងសេដ្ឋីជាបិតាយស-កុលបុត្រនោះឱ្យដល់នូវត្រៃសរណគមន៍ឈ្មោះតេវាចិកសរណ-គមន៍ ជាបឋមមុនគេបំផុតក្នុងព្រះពុទ្ធសាសនា, លុះចប់ធម៌-ទេសនាហើយ ព្រះអង្គស្រាយឫទ្ធិចេញទៅកាលណា សេដ្ឋីជាបិតា ក៏ឃើញយសកុលបុត្រជាកូន អង្គុយនៅជិតក្បែរខ្លួន, ហើយយសកុលបុត្រនោះ បានសូមបព្វជ្ជាជាឯហិឧបសម្បទាក្នុងព្រះពុទ្ធសាសនា ដោយលោកបានពិចារណាអរិយសច្ច ៤

ប្រការ តមកក៏បានសម្រេចព្រះអរហត្តផលជាខិប្បាភិញ្ញា ជាព្រះអរហន្តយ៉ាងប្រសើរក្នុងព្រះពុទ្ធសាសនា ។

លោកអ្នកចម្រើនធម៌អរិយសច្ចនោះ រមែងនឹងបានសម្រេចមគ្គផលព្រះនិព្វាន ដូចរឿងដែលបានអធិប្បាយមកយ៉ាងនេះឯង ។

---

# មង្គលទី ៣៤

និព្វានសច្ឆិកិរិយា ច កិរិយាធ្វើនូវព្រះនិព្វានឱ្យជាក់ច្បាស់បានដោយបញ្ញាជាមង្គលដ៏ឧត្តម ។

អធិប្បាយថា: បុគ្គលដែលនឹងធ្វើព្រះនិព្វានឱ្យជាក់ច្បាស់បានដោយបញ្ញានោះ ត្រូវធ្វើដំណើរចិត្តប្រតិបត្តិឱ្យត្រង់តាមផ្លូវអរិយមគ្គទាំង ៨ ប្រការគឺ សីល សមាធិ បញ្ញា ទើបនឹងធ្វើព្រះនិព្វានឱ្យជាក់ច្បាស់បាន; ឯបញ្ញាក្នុងទីនេះ លោកសំដៅយកបញ្ញាដែលកើតអំពីវិបស្សនា ១០ យ៉ាងគឺ:

១-សមជញ្ញាណ បញ្ញាពិចារណាឃើញសង្ខារថាជាអនិច្ចំ មិនទៀង, ទុក្ខំ ប្រកបដោយទុក្ខ, អនត្តា មិនមែនជារបស់ខ្លួន ដូច្នេះជាដើម ទូទៅគ្រប់សង្ខារទាំងអស់ ។

២-ឧទយព្វយញ្ញាណ បញ្ញាពិចារណាឃើញទីកើតទីរលត់នៃសង្ខារ គឺឃើញថា ខន្ធទាំង ៥ នេះក្នុងខន្ធមួយៗ កើតឡើងដោយធម៌ ៥ រលត់ទៅវិញដោយរលត់ធម៌ ៥ ជាមុន រូបកើតដោយធម៌ ៥ នេះមកប្រជុំព្រមគ្នាគឺៈ អវិជ្ជា ១, តណ្ហា ១, កម្ម១, អាហារ ១, ឧបាទាន ១, ទើបរូបកើតឡើងបាន កាលរូបក្ខន្ធនឹងរលត់ទៅលុះតែរលត់ធម៌ ៥ នេះជាមុន ។ ឯរូបក្ខន្ធទាំង ៤ កើតឬរលត់ដោយធម៌ ៥ៗ ដូចគ្នាគឺៈ អវិជ្ជា ១, តណ្ហា ១, កម្ម ១, សម្ផស្ស ១, ឧបាទាន ១ ។ បើយកខន្ធ ៥ មកគុណនិងញាណ ១០ ឃើញទៅជាញាណ ៥០ គឺញាណដែលឃើញទីកើតនៃខន្ធមាន ២៥, ញាណដែលឃើញទីរលត់នៃខន្ធមាន ២៥ (រួមជា ៥០)បញ្ចក្ខន្ធនិងធម៌ ៥ សម្រាប់បង្កើតខន្ធនេះ ប្រៀបដូចជាភ្លើងនិងអុស គឺអុសមាននៅដរាបណា ភ្លើងក៏មាននៅដរាបនោះ លុះអុសអស់រលីងហើយ ភ្លើងគ្មានវត្ថុអ្វីជាទីអាស្រ័យឆេះនៅក៏រលត់ទៅតាមអុសអស់នោះផងដែរ, ដូចធម៌ ៥ ដែលជាមេ

បង្កើតខន្ធៗ ជាមេបង្កើតទុក្ខៗ ជាមេបង្កើតទោសនានាជាអនេកប្រការ គឺជាតួភ្លើងទុក្ខភ្លើងកិលេស ឆេះជាប់ក្នុងសន្តានចិត្តនៃសត្វទាំងយប់-ថ្ងៃឥតមានស្រាកស្រាន្តឡើយ ។

៣-ភង្គញ្ញាណ បញ្ញាពិចារណាឃើញទីបែកធ្លាយនៃសង្ខារ ដូចជាដុំនៃពពុះទឹកដែកប៉ោងឡើងហើយបែកទៅវិញ ។

៤-ភយតុបដ្ឋានញ្ញាណ បញ្ញាពិចារណាឃើញទោសក្នុងសង្ខារថា មានភ័យច្រើនគួរខ្លាចបីដូចជារងើកភ្លើងដែលក្តៅ ។

៥-អាទីនវញ្ញាណ បញ្ញាពិចារណាឃើញទោសក្នុងសង្ខារថាមានរោគច្រើនបៀតបៀនជានិច្ច ដូចជាដំបូកជាទីនៅនៃសត្វកណ្តៀរ ។

៦-និព្វិទាញាណ បញ្ញាពិចារណាឃើញទោសក្នុងសង្ខារហើយកើតសេចក្តីជិនឆ្អន់ធុញទ្រាន់នឿយណាយ ដូចជាស្វាមីនិងភរិយាឃើញទោសគ្នា ហើយប្រាថ្នានិងលែងលះគ្នាឱ្យដាច់ ។

៧-មុញ្ចិតុកម្យតាញាណ បញ្ញាពិចារណារកឧបាយដែលនឹងចេញឱ្យរួចចាកសង្ខារ ដូចជាសត្វទទាត្បុលទ្រុងចង់ចេញឱ្យ

រួចពីទ្រុង ឬដូចត្រីរុលត្បុលសំណាញ់ចង់ចេញឱ្យរួចពីក្នុងសំណាញ់ ។

៨-សង្ខារុបេក្ខាញាណ បញ្ញាពិចារណាឃើញគុណនិងទោសក្នុងសង្ខារ ហើយធ្វើចិត្តតាំងនៅជាកណ្តាលមិនស្រឡាញ់មិនស្អប់សង្ខារ ដូចជាស្វាមីនិងភរិយាដែលលះលែងគ្នាដាច់ស្រឡះហើយ ។

៩-អនុលោមិកញ្ញាណ បញ្ញាពិចារណាឃើញអរិយសច្ចទាំង ៤ ព្រមទាំងសង្ខារ ជាអនុលោមបដិលោមទៅមកៗ ក្នុងញាណ ៨ ខាងដើម ដើម្បីរំលត់អវិជ្ជា-តណ្ហា-កម្មជាដើម ប្រៀបដូចជាសត្វប្រចៀវសួរទៅមកៗ ដើម្បីរកផ្លែស្រគំក្នុងមែកទាំង ៥ ។

១០-គោត្រភូញាណ បញ្ញាពិចារណាលើកចិត្តឡើងកាន់អរិយមគ្គ តាមឧបនិស្ស័យវាសនាបារមី របស់ខ្លួនពីបុព្វជាតិកសាងសន្សំមក ផ្សំគ្នានឹងហេតុ-ផលនៃការសេពគប់មិត្រក្នុងបច្ចុប្បន្នជាតិនេះផង ដូចរឿងព្រះបាទអជាតសត្រូវរលត់មគ្គ-ផលព្រោះត្រូវសេពគប់នឹងទេវទត្តជាមិត្រខុស នេះជាទោសហេតុផលក្នុងបច្ចុប្បន្ន ។

វិបស្សនាបញ្ញា ឬវិបស្សនាញាណ ទាំង ៩ ឬទាំង ១០ ប្រការនេះ ជាធម៌សម្រាប់ធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន ។ ព្រះនិព្វាននោះមាន ២ យ៉ាងគឺៈ *សឧបាទិសេសនិព្វាន* រំលត់ធម្មធាតុដែលជាលោកិយ គឺសោមនស្សទោមនស្សតួកិលេសឱ្យស្លាប់អស់ ហើយចិត្តជាឆឡង្គុបេក្ខា ធម្មដ្ឋិតិញាណ បញ្ញាតាំងនៅខ្ជាប់ខ្ជួនក្នុងធម៌ មិនបានញាប់ញ័រគឺជាតួព្រះអរហត្តផល១។ *អនុបាទិសេសនិព្វាន* រំលត់ភ្លើងទុក្ខភ្លើងកិលេសមានជាតិ-ជរាព្យាធិ-មរណៈ និងរាគៈ ទោសៈ មោហៈ ជាដើមឱ្យអស់ទៅបាន ១ ។

ម្យ៉ាងទៀតព្រះនិព្វាននោះ ព្រះបរមសាស្តាទ្រង់ទេសនាថាៈ *អត្ថិ ភិក្ខវេ តទាយតនំ* ម្នាលភិក្ខុទាំងឡាយ អាយតនៈមាននៅ ឈ្មោះថាសង្ខតធាតុ មិនមានបច្ច័យប្រជុំតាក់តែងនូវធាតុអាយតនៈនិងនាមរូបក្នុងទីណា គឺនឹងថាជាដីជាទឹកជាភ្លើងជាខ្យល់ជាវិញ្ញាណ អណ្តែតទៅក្នុងអាកាស គឺទីវាលទទេៗ នោះក៏ទេដែរ ព្រះនិព្វានគ្រាន់តែជាទីរំលត់ទុក្ខនិងរំលត់ហេតុឱ្យកើតទុក្ខគឺតណ្ហាទាំង ១០៨ និងកិលេសទាំង ១៥០០ ឱ្យអស់រលីងទៅតែប៉ុណ្ណោះ ទើបបានឈ្មោះថាព្រះនិព្វាន ដូចបានអធិប្បាយ

សង្ខេបមកយ៉ាងនេះឯង ។ សូមបណ្ឌិតជាតជាអ្នកមានប្រាជ្ញាពិចារណាឱ្យយល់វែងឆ្ងាយតទៅ ៕

---

# មង្គលទី ៣៨

ផុដ្ឋស្ស លោកធម្មេហិ ចិត្តំ យស្ស ន កម្បតិ ចិត្តរបស់បុគ្គលឯណា មិនញាប់ញ័រដោយលោកធម៌ទាំងឡាយពាល់ត្រូវ ហើយជាមង្គលដ៏ឧត្តម ។

អធិប្បាយថាៈ លោកធម៌មាន ៨ ប្រការគឺៈ មានលាភ ១, ឥតលាភ ១, មានយស ១, ឥតយស ១, និន្ទា ១, សរសើរ ១, សុខ ១, ទុក្ខ ១ (រួមជា ៨ ប្រការ) លោកធម៌ទាំង ៨ នេះ បានជាហៅថាលោកធម៌ ព្រោះជាសភាពធ្វើចិត្តរបស់សត្វលោកដែលមានសន្តានជាបុថុជ្ជននៅឡើយ ឱ្យញាប់ញ័រជានិច្ច ។ វៀរលែងតែអង្គព្រះអរហត្ត ដែលលោកកាត់កិលេសអស់ចាកសន្តាន សម្លាប់ធម្មធាតុទាំង ៧ ប្រការបាន ព្រះទ័យលោកគ្មានសោមនស្សទោមនស្ស ជាឆឡង្គុបេក្ខា គឺតាំងនៅជាកណ្តាល

ធម្មដ្ឋិតិញាណ លោកមានបញ្ញាខ្ជាប់ខ្ជួនពិចារណាក្នុងសង្ខតធម៌ និងអសង្ខតធម៌ បានជាលោកមិនញាប់ញ័រដោយលោកធម៌ទាំង ៨ នេះឡើយ ។

ឯបុគ្គលដែលមានសន្តានចិត្តជាបុថុជ្ជន បើអាស្រ័យដោយបញ្ញាពិចារណាលោកធម៌ទាំង ៨ នេះថា មានលាភ មានយស មានសរសើរ មានសុខ និងសូន្យលាភ បង់យស បាននិន្ទា មានទុក្ខ ទាំងអម្បាលនេះជារបស់មិនទៀង ជាទុក្ខ មិនមែនជារបស់ខ្លួន រមែងប្រែប្រួលទៅតាមសភាពលោកជាធម្មតា កាលបើបានពិចារណាដូច្នេះរឿយៗ ហើយ សេចក្តីត្រេកអរ ឬតូចចិត្តសោយសោក ខ្សឹកខ្សួលជាដើម ក៏ស្ដើងស្ដួចចាកកាយសន្តានបានដោយសារបញ្ញា ពិចារណានូវសង្ខាររឿយៗ នោះនឹងកំចាត់បង់ឧបាទានបានខ្លះៗ មិនខាន ។

ឯបុគ្គលដែលមានសន្តានចិត្តជាបុថុជ្ជននៅឡើយ បើមានលាភ យស សរសើរ សុខហើយ រមែងត្រេកអរ ចិត្តក៏កាន់យកដោយមោហុបាទាន ។ បើគ្មានលាភ គ្មានយស បាននិន្ទា បានទុក្ខវិញ រមែងទោមនស្សតូចចិត្ត កើតសេចក្តីសៅសោកជាធម្មតា ព្រោះអវិជ្ជាគឺមោហៈគ្របសង្កត់ មិនឱ្យដឹងប្រមាណក្នុង

សង្ខារ ដូចមានរឿងដំណាលពីនាងមាគន្ទិយ ដែលបានជាអគ្គ-មហេសីព្រះបាទឧទេន បានលាភ-យសជាដើម ត្រេកអរភ្លេចខ្លួនឡើងមានៈ កើតប្រទូស្តនឹងនាងសាមាវតី ក៏ត្រូវឡប់ទៅជាវិនាសខ្លួនវិញ ឬដូចរឿងសត្វចចកស្គមដើរតាមព្រានព្រៃគិតថាក្រែងបានសាច់ដែលសេសសល់ លុះដល់ព្រាននោះឃើញដំរីមិនឃើញពស់ ក៏ឈរជិតសត្វពស់បាញ់ដំរីព្រៃ នៅវេលាស្នាដំរថ្លស់កែទៅត្រូវដំរីស្លាប់ ពស់នោះវាភ័យភ្ញាក់ចឹកជើងព្រានៗក៏ដួលវាត់ ស្នាទៅត្រូវចំក្បាលពស់ៗ ក៏ស្លាប់ផងដែរ ។

ឯឆ្កែចចកនោះ ក៏ស្រែកថាមហាលាភោ អញមានលាភធំណាស់ពេលនេះ ព្រោះដំរីក៏ស្លាប់មនុស្សក៏ស្លាប់ពស់ក៏ស្លាប់បានជាអាហារអញទាំងអស់ ប៉ុន្តែអាត្មាត្រូវសំចៃទុកស៊ីថ្ងៃក្រោយតៗ ទៅ ពេលនេះត្រូវអញស៊ីស្បែកបន្ទោះស្នាជាមុន បើមិនឆ្អែតសឹមស៊ីសាច់ពស់ទៀត ចចកនោះលុះគិតដូច្នោះហើយក៏អង្កៀមបន្ទោះស្នាៗ នៅវេលាដាច់បន្ទោះក៏វាត់មកត្រូវចំក្បាលចចកៗ ក៏ស្លាប់ក្នុងពេលនោះផងដែរ ។

ឯអ្នកដែលល្មោភលាភ-យស-សរសើរ-សុខ ជាដើមនេះ រមែងតែងបានជួបប្រទះនឹងគ្រោះថ្នាក់ធំៗ ដល់ខ្លួនដូចសត្វចចក ដែលបានអធិប្បាយមកយ៉ាងនេះឯង ៕

---

# មង្គលទី ៣៦

**អសោកំ** សេចក្តីមិនសោយសោក ដោយហេតុដែលកើតឡើងផ្សេងៗ ជាមង្គលដ៏ឧត្តម ។

អធិប្បាយថា: សេចក្តីសោយសោកនិងភ័យទាំងឡាយដែលកើតឡើងបាននោះ មកអំពីពួកសត្វមានតណ្ហាជាហេតុ ពុទ្ធដីកាសំដែងប្រាប់ហេតុនៃសេចក្តីសោក និងភ័យជាដើមថា: តណ្ហា ជាយតេ សោកោ តណ្ហា ជាយតេ ភយំ តណ្ហាវិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ សេចក្តីសោកកើតមកពីតណ្ហា ភ័យក៏កើតមកពីតណ្ហា បើបុគ្គលមានចិត្តផុតស្រឡះអំពីតណ្ហាហើយ សេចក្តីសោកនិងភ័យមិនមានមកអំពីទីណាទៀតឡើយ ។ ឯកិច្ចនឹងរំលត់សេចក្តីសោកនិងភ័យជាដើមនេះ ត្រូវ

រំលត់ដោយកម្មដ្ឋាន ២ ប្រការគឺៈ សមថកម្មដ្ឋាន និងវិបស្សនា-កម្មដ្ឋាន ទើបរលត់បាន, ឯសមថកម្មដ្ឋាននោះគឺៈ អនុស្សតិ ១០, អសុភ ១០, កសិណ ១០, អរូបជ្ឈាន ៤ ព្រហ្មវិហារ ៤, ធាតុវវត្ថាន ១, អាហារប្បដិកូលសញ្ញា ១ (រួមជា ៤០) ។

## អនុស្សតិ ១០ គឺៈ

**១-ពុទ្ធានុស្សតិ** រឭកដល់ពុទ្ធគុណមានអរហំជាដើម ។

**២-ធម្មានុស្សតិ** រឭកដល់ធម្មគុណមាន ស្វាក្ខាតោជាដើម

**៣-សង្ឃានុស្សតិ** រឭកដល់សង្ឃគុណមានសុបដិបន្នោជាដើម ។

**៤-សីលានុស្សតិ** រឭកដល់សីលគុណមានអដ្ឋង្គិកសីលជាដើម ។

**៥-ចាគានុស្សតិ** រឭកដល់គុណទានដែលខ្លួនបានបរិច្ចាគហើយ ។

**៦-ទេវតានុស្សតិ** រឭកដល់គុណធម៌របស់ទេវតាមានសទ្ធាជាដើម ។

**៧-ឧបសមានុស្សតិ** រឭកដល់គុណព្រះនិព្វាន មានវដ្តបរិច្ឆេទ ជាដើម ។

**៨-មរណានុស្សតិ** រឭកដល់សេចក្តីស្លាប់ថា ‹‹អញនឹងស្លាប់››ជាដើម ។

**៩-អានាបានស្សតិ** រឭកដល់ខ្យល់ដកដង្ហើមចេញ-ចូលគ្រប់ដង្ហើម ។

**១០-កាយគតាសតិ** រឭកទូទៅក្នុងកាយឱ្យឃើញថាមិនស្អាតជារបស់គួរខ្ពើម ។

## អសុភ ១០ គឺ:

**១-ឧទ្ធុមាតកំ** អសុភដែលហើមប៉ោងឡើង

**២-វិនីលកំ** អសុភហើមឡើងពណ៌ខៀវ

**៣-វិបុព្វកំ** អសុភដែលមានទឹកខ្ទុះហូរចេញ

**៤-វិច្ឆិទ្ទកំ** អសុភដែលគេកាត់ដាច់ពាក់កណ្តាលខ្លួន

**៥-វិក្ខាយិត្តកំ** អសុភដែលសត្វខាំជញ្ជែងស៊ី

**៦-វិក្ខិត្តកំ** អសុភដែលមានឆ្អឹងរាត់រាយក្នុងទីផ្សេងៗ

**៧-ហតវិក្ខិត្តកំ** អសុភដែលគេកាប់ចិញ្រ្ចាំដាច់ជាកំណាត់តូច-ធំ

**៨-លោហិតកំ** អសុភដែលប្រឡាក់ដោយឈាម

**៩-បុឡុវកំ** អសុភដែលមានដង្កូវវារចេញរវើក

**១០-អដ្ឋិកំ** អសុភដែលនៅសល់តែរាងឆ្អឹងទទេ

## កសិណ ១០ គឺ:

**១-បឋវីកសិណំ** សម្លឹងមើលដីយកជាអារម្មណ៍

**២-អាបោកសិណំ** សម្លឹងមើលទឹកយកជាអារម្មណ៍

**៣-តេជោកសិណំ** សម្លឹងមើលភ្លើងយកជាអារម្មណ៍

**៤-វាយោកសិណំ** សំឡឹងមើលខ្យល់យកជាអារម្មណ៍

**៥-នីលកសិណំ** សំឡឹងមើលពណ៌ខៀវយកជាអារម្មណ៍

**៦-បីតកសិណំ** សម្លឹងមើលពណ៌លឿងយកជាអារម្មណ៍

**៧-លោហិតកសិណំ** សម្លឹងមើលពណ៌ក្រហមយកជាអារម្មណ៍

**៨-ឱទាតកសិណំ** សម្លឹងមើលពណ៌សយកជាអារម្មណ៍

**៩-អាលោកកសិណំ** សម្លឹងមើលអាកាសយកជាអារម្មណ៍

**១០-អាកាសកសិណំ** សំឡឹងមើលអាកាសយកជាអារម្មណ៍

## អរូបជ្ឈាន ៤

**១-អាកាសានញ្ចាយតនៈ** សម្លឹងមើលអាកាសគឺទីវាល ដែលជាចន្លោះទទេយកជាអារម្មណ៍ ហើយបរិកម្មថា: (អនន្តោ អាកាសោ) ។

**២-វិញ្ញាណញ្ចាយតនៈ** ស្រាវយកអរូបវិញ្ញាណទី ១ ដែលល្អិតមកធ្វើជាអារម្មណ៍របស់ចិត្ត ហើយបរិកម្មថា: (បរិត្តកំ វិញ្ញាណំ) ។

**៣-អកិញ្ចញ្ញាយតនៈ** កំណត់យកអរូបវិញ្ញាណទី ១ ដែលផ្សាយទៅដោយមិនមានកង្វល់តិចតួចជាអារម្មណ៍ ហើយបរិកម្មថា: (នត្ថិ កិញ្ចិ វត្ថុ) ។

**៤-នេវសញ្ញានាសញ្ញាយតនៈ** កំណត់យកសេចក្តីល្អិតរបស់អរូបចិត្តទី ៣ ដែលមានស្មើរតែមិនមាន មកជាអារម្មណ៍។

## ព្រហ្មវិហារ ៤ គឺៈ

**១-មេត្តាចេតោ** ផ្សាយមេត្តាចិត្តដល់សត្វទាំងពួង

**២-ករុណាចេតោ** ផ្សាយករុណាចិត្តដល់សត្វទាំងពួង

**៣-មុទុតាចេតោ** ផ្សាយមុទិតាចិត្តដល់សត្វទាំងពួង

**៤-ឧបេក្ខាចេតោ** ផ្សាយឧបេក្ខាចិត្តដល់សត្វទាំងពួង

## ធាតុវវត្ថាន ១ គឺៈ

**១-ធាតុវវត្ថានៈ** ពិចារណាធាតុ ៤ គឺ ដី-ទឹក-ភ្លើង-ខ្យល់ ខាងក្នុងខ្លួនថាៈ ធាតុក្នុងអាស្រ័យ និង ធាតុក្រៅទើបរស់នៅបាន ។

## អាហារប្បដិក្កូលសញ្ញា ១ គឺៈ

**១-អាហារប្បដិក្កូលសញ្ញា** ពិចារណាអាហារទាំងពួង ឱ្យឃើញថាជារបស់បដិកូលគួរខ្ពើមរអើម រួមត្រូវជា ៤០ ហៅថា **សមថកម្មដ្ឋាន ៤០** ។

សមថកម្មដ្ឋាននេះ សម្រាប់ឃោគាវចរកុលបុត្រអ្នកមានសទ្ធា មិនថាគ្រហស្ថមិនថាបព្វជិតសិក្សាបានដូចគ្នា បើអ្នកមានសទ្ធាព្រមទាំងព្យាយាមខំចំរើនកម្មដ្ឋាននេះណាមួយ គង់នឹង

បានទទួលកម្រៃផលពីការចម្រើននោះខ្លះៗ មិនខាន, ដូចមានរឿងដំណាល ពីព្រះសមណគោតមបរមគ្រូជាម្ចាស់សាសនានៃយើង កាលព្រះអង្គនៅជាព្រះពោធិសត្វនៅឡើយ ទ្រង់កើតក្នុងត្រកូលព្រាហ្មណ៍មួយ ក្នុងគ្រួសារនេះមានគ្នា ៦ នាក់គឺៈ ព្រះអង្គ ១, ភរិយា ១, កូនប្រុស ១, កូនស្រី ១, កូនប្រសាស្រី ១, ខ្ញុំស្រី ១ ត្រូវជា ៦ នាក់ ។ ឯព្រះពោធិសត្វទ្រង់តែងឱ្យឱវាទដល់ជន ៥ នាក់ ដែលនៅក្នុងសំណាក់ព្រះអង្គនោះរឿយៗ ថា អ្នកទាំងឡាយត្រូវខំចម្រើនមរណានុស្សតិកម្មដ្ឋាន អ្នកនឹងបានដឹងច្បាស់នូវសង្ខារនេះថាៈ ‹‹សត្វទាំងឡាយដែលកើតមកហើយ រមែងត្រូវស្លាប់ទៅវិញជាធម្មតា›› មិនរើសមុខសត្វពួកណាមួយឡើយ ឱ្យតែពួកសត្វដែលមានជាតិកើតមកហើយរមែងធ្វើដំណើរទៅជួបនឹងសេចក្តីស្លាប់វិញ ដូចគ្នាទាំងអស់ ។ ដោយហេតុនេះ ចូរអ្នកទាំងឡាយកុំប្រមាទមើលងាយសេចក្តីស្លាប់ថានៅឆ្ងាយ មិនទាន់ចូលដល់យើងទាំងឡាយឡើយ សេចក្តីស្លាប់នេះ នៅប្រចាំជីវិតយើងរាល់គ្នាគ្រប់វារៈខ្យល់ដកដង្ហើមចេញ-ចូល ជាធម្មតាចាំផ្លាស់វេនគ្នានឹងសេចក្តីកើតប្រៀបបីដូចជាថ្ងៃរះត្រូវផ្លាស់វេននឹងយប់ គឺថ្ងៃលិចបាត់ទៅវិញ

ដូច្នោះដែរ, ហេតុនេះ គួរណាស់ហើយតែយើងត្រូវនឹកដល់សេចក្ដីស្លាប់ឱ្យគ្រប់វារៈដង្ហើមចេញ-ចូល កុំត្រេកត្រអាលក្នុងកាមភ្លេចខ្លួនឡើយ ។ តេ បញ្ច ជនា ជនទាំងឡាយ ៥ នាក់នោះ ក៏ស្ថិតនៅក្នុងឱវាទរបស់ព្រះបរមពោធិសត្វគ្រប់ប្រការនាំគ្នាចម្រើនមរណានុស្សតិកម្មដ្ឋានគ្រប់ទិវារាត្រីកាល មិនមានសេចក្ដីប្រមាទឡើយ ។ ឯកាទិវសំ សម័យថ្ងៃមួយ ព្រះពោធិ-សត្វ ២ នាក់នឹងកូនប្រសានាំគ្នាទឹមនង្គ័លទៅភ្ជួរពីព្រឹកព្រហាមឯមាណពជាកូន បានកាន់កាំបិតព្រាម្នីម្នាដើរទៅបោចស្មៅនៅភ្លឺស្រែយកមកគរដុត ផ្សែងក៏បក់ត្រឡប់ចូលទៅក្នុងស៊ុំទ្រុំស្មៅ ឯស៊ុំទ្រុំនោះ មានពស់វែកមួយវារពេននៅក្នុងទីនោះ លុះត្រូវផ្សែងវាក៏លូនចេញមកឃើញមាណពកំពុងតែដុតភ្លើងវាខឹងឃោរឃៅមហិមា ក៏វាលោតទៅចឹកមាណព ត្រូវដួលដេកស្លាប់ក្នុងទីនោះទៅ ដោយកម្លាំងឃោរឃៅនិងពិសដ៏ក្លាហាន ។ ឯព្រះបរម-ពោធិសត្វ កាលបើបានឃើញកូនដួលដេកស្លាប់ដូច្នោះហើយលោកក៏ម្នីម្នារត់ទៅលើកសពកូនឡើង នាំយកទៅផ្ដេកនៅក្រោមម្លប់ឈើធំមួយនៅនាភ្លឺស្រែ ហើយលោកមិនបានយំ

សោកអ្វីនឹងកូនដែលស្លាប់នោះឡើយ, ដោយលោកពិចារណាថា កូនអញដែលស្លាប់នេះ លះបង់នូវរាងកាយចោល បីដូចជាសត្វពស់ដែលសកលះបង់សំណកហើយចេញចោលទៅ ធម្មតាពស់ដែលសក មិនស្រឡាញ់មិនជាប់ចិត្តនឹងសំណកវាយ៉ាងណា ឯកូនអញដែលវាស្លាប់ទៅនេះក៏ដូច្នោះដែរ បើអញយំសោកស្តាយមិនមានប្រយោជន៍អ្វីដល់អញ ឬដល់កូនដែលស្លាប់ទៅនោះ បន្តិចបន្តួចសោះឡើយ ។ លុះពោធិសត្វគិតដូច្នោះហើយ ក៏ត្រឡប់ទៅភ្ជួរស្រែតទៅទៀត គ្រានោះ មានបុរសម្នាក់ដើរមកជិតលោកៗ ក៏ស្រែកផ្តាំថា នែ អ្នក បើអ្នកទៅដល់ស្រុកហើយ អាណិតចូលទៅប្រាប់អ្នកផ្ទះខ្ញុំឱ្យមកទាំងអស់គ្នា ហើយឱ្យយកបាយតែមួយចំណែកមកហើយ កុំយកពីរចំណែកដូចសព្វដងឡើយ, ឯបុរសនោះក៏ទទួលយកអាសាហើយទៅប្រាប់ភរិយានិងធីតាពោធិសត្វតាមបណ្តាំ ជនទាំង ៤ នាក់ទៀតនោះ លុះឮហើយក៏នាំគ្នាទៅទាំងអស់គ្នា យកអាហារតែមួយចំណែកទៅ លុះទៅដល់ឃើញមាណពស្លាប់នៅក្រោមម្លប់ឈើដូច្នោះហើយ ក៏នាំគ្នាពិចារណាសេចក្តីស្លាប់ផ្សេងៗ គ្នា, ឯនាងព្រាហ្មណីជាមាតា នាងពិចារណាថា កូនអញកាលគេមក

កើតក្នុងផ្ទៃអញនេះ អញក៏មិនបានហៅគេមក កាលគេវិលត្រឡប់ទៅមិនមកវិញយ៉ាងនេះ គេក៏មិនបានលាអញៗ ក៏មិនអនុញ្ញាតឱ្យគេទៅឡើយ, កាលគេមកកាន់ផ្ទៃអញយ៉ាងណា គេទៅវិញក៏យ៉ាងនោះដែរ ចូរទៅតាមអធ្យាស្រ័យចុះ បើអញយំសោកស្តាយគេ ក៏ឥតមានផលប្រយោជន៍អ្វីឡើយ មាតាពិចារ-ណាដូច្នោះហើយ ក៏មិនបានយំសោយសោក ។ ឯប្អូនក្រមុំពិចារណាថា បងអញដែលស្លាប់នេះ បើអញយំសោកទៅក៏ឥតប្រយោជន៍ទេ ព្រោះគេមិនបានឮអញយំសោកស្តាយគេឡើយ, ប្អូនក្រមុំពិចារណាដូច្នោះហើយ ក៏មិនបានយំសោយសោក ។ ឯនាងព្រាហ្មណីជាភរិយាមាណពនោះពិចារណាថា បើអញយំសោកស្រណោះស្វាមីដែលស្លាប់នេះ នឹងទៅជាមនុស្សឆោតហួសពេក បីដូចជាកូនក្មេងតូច ក្រឡេកឃើញដួងព្រះចន្ទរះភ្លឺលើមេឃក៏ស្រែកយំទា បើទុកជាក្មេងនោះយំទាយ៉ាងណា ក៏គ្មានអ្នកណានឹងចាប់យកដួងព្រះចន្ទ ពីលើមេឃមកឱ្យក្មេងនោះកាន់លេងបានឡើយ ភរិយាពិចារណាដូច្នោះហើយ ក៏មិនបានយំសោក ។ ឯខ្ញុំស្រីពិចារណាថា កូនម្ចាស់អញដែលស្លាប់នេះ បីដូចជាឆ្នាំងបែកជា ៧ ភាគ អ្នកណានឹងអាចផ្សារឆ្នាំងដី

ដែលបែកខ្ទេចនោះជាប់ឡើងវិញបាន បើអញយំសោកទៅម្ចាស់អញនេះក៏មិនរស់ឡើងវិញឡើយ, ខ្ញុំស្រីនោះលុះពិចារណាឃើញដូច្នោះហើយ ក៏មិនបានយំសោក ។ ជនទាំង ៥ នាក់នោះ ពិចារណាឃើញសេចក្ដីស្លាប់ព្រមគ្នាដូច្នេះហើយ ក៏គ្មាននរណាម្នាក់យំសោយសោកឡើយ សូម្បីតែស្រក់ទឹកភ្នែកមួយដំណក់ក៏គ្មានសោះ ។

តស្សាវសេជ ដោយអំណាចមរណានុស្សតិនោះ ក៏បណ្ដាលឱ្យក្ដៅដល់បណ្ឌុកម្ពលសេនាសនៈ នៃសម្ដេចអម្រិន្ទ្រាធិរាជៗ ក៏បើកសហស្សន័យនេត្រទតមើលមកឃើញច្បាស់នូវហេតុការណ៍សព្វគ្រប់ហើយ ទើបចុះចាកទេវស្ថាននិម្មិតខ្លួនជាព្រាហ្មណ៍ចាស់ ហើយដើរចូលទៅកាន់ទីនោះសួរថា នែ អ្នកទាំងឡាយ កូនអ្នកពស់ចឹកស្លាប់ដូច្នេះហើយ តើហេតុដូចម្ដេចក៏បានជាមិនមានអ្នកណាម្នាក់ ទួញយំសោកស្ដាយកូននោះឡើយ ព្រះពោធិសត្វឆ្លើយតបថា ម្នាលព្រាហ្មណ៍អើយ អ្នកណាដែលទួញយំសោកស្ដាយអាឡោះអាល័យ មនុស្សស្លាប់នេះ អ្នកនោះជាមនុស្សអន្ធពាល មានសន្ដានចិត្តខ្លៅ នៅឆោតល្ងិតល្ងង់

ដោយអវិជ្ជាគ្របសង្កត់ មនុស្សនោះ មិនដឹងគុណនៃព្រះធម៌ ដែលនាំចេញនូវសេចក្ដីសោកវិយោគព្រាត់ប្រាសចាកសត្វនិង សង្ខារ ដែលជាទីស្រឡាញ់ពេញចិត្តឡើយ ។ តំ សុត្វា ព្រះ ឥន្ទ្រាធិរាជទ្រង់ព្រះសណ្ដាប់ពាក្យនោះហើយ ក៏មានព្រះទ័យ សោមនស្សឱ្យពរសព្ទសាធុការ ដល់ជនទាំង ៥ នាក់ រួចក៏ហោះ ឡើងកាន់អាកាស បណ្ដាលឱ្យភ្លៀងកែវ ៧ ប្រការ ធ្លាក់ចុះមក ពេញផ្ទះឥតសល់ល្វែងណាមួយឡើយ ឯអ្នកដែលបានចម្រើន មរណានុស្សតិកម្មដ្ឋាន រមែងមិនសោយសោក តែងបាន ប្រយោជន៍ច្រើនប្រការ ដូចន័យដែលអធិប្បាយមកយ៉ាងនេះ ឯង ។

---

# មង្គលទី ៣៧

វិរជំ ចិត្តដែលប្រាសចាកធុលី គឺកិលេសក្នុងសន្ដាន ជាមង្គលដ៏ឧត្តម ។

អធិប្បាយថាៈ រាគៈទោសៈ មោហៈ ទាំង ៣ នេះ លោក

ចាត់ជាមេកិលេសធំៗ ប្រៀបដូចភ្នំ អនុសយកិលេស ជាកិលេសល្អិតដែលដិតជាប់ក្នុងខន្ធសន្ដានមាន ៧ យ៉ាងទៀតគឺៈ

**១-កាមរាគានុស័យ** សេចក្ដីតម្រេកត្រេកត្រអាលក្នុងកាមគុណ ៥ គឺៈ រូប ១, សម្លេង ១, ក្លិន១, រស១, សម្ផស្ស១ ។

**២-ភវរាគានុស័យ** សេចក្ដីតម្រេកត្រេកអរក្នុងភព ដែលជាទីកើត ៣ កន្លែងគឺៈ កាមភព ១, រូបភព១, អរូបភព ១ ។

**៣-បដិឃានុស័យ** បានដល់ទោសៈដែលមានបដិឃៈ គឺៈ សេចក្ដីថ្នាំងថ្នាក់ចិត្តជាប់ជានិច្ច ប្រទូស្តក្នុងសត្វគឺរូបដែលមានជីវិត និងប្រទូស្តក្នុងសង្ខារគឺរូបដែលឥតជីវិត ឥតគិតពិចារណារកគុណទោសឡើយ ។

**៤-មានានុស័យ** សេចក្ដីប្រកាន់ខ្លួនប្រាណថាយើងថាគេថាអញ ថាឯង មានប្រកាន់ជាតិត្រកូល ថាខត្តិយៈ, ព្រាហ្មណៈ, វេស្សៈ, សូទ្រៈ ជាដើម ។

**៥-ទិដ្ឋានុស័យ** សេចក្ដីយល់ខុសឃើញថាសត្វទៀង បើសត្វណាធ្លាប់កើតជាសត្វអ្វី ក៏នៅជាសត្វនោះដដែល ឬយល់ឃើញថាសូន្យៗ បាត់ៗ ទៅនៅវេលាស្លាប់ មិនឃើញមានកើតទៀត ឬមកប្រាប់ឱ្យដឹងផងឡើយ ។

**៦-វិចិកិច្ឆានុស័យ** សេចក្ដីសង្ស័យក្នុងធម៌ទាំងពួង មានសង្ស័យក្នុងសុចរិតទុច្ចរិតថាឱ្យទុក្ខដល់សត្វជាដើម ។

**៧-អវិជ្ជានុស័យ** បានដល់មោហៈសេចក្ដីវង្វេងឬភាន់ច្រឡំមិនដឹងក្នុងសង្ខារដែលជាអតីតៈអនាគតនិងបច្ចុប្បន្នជាដើម ។

## វិចិកិច្ឆានោះមាន ៨ យ៉ាងគឺ:

**បុព្វន្តេ អញ្ញាណំ** មិនដឹងក្នុងខន្ធធាតុអាយតនៈខាងដើម គឺមិនដឹងថាជាតិមុនខ្លួនកើតជាអ្វី ជាមនុស្ស ឬជាសត្វក៏មិនដឹង ១ ។

**បរន្តេ អញ្ញាណំ** មិនដឹងក្នុងខន្ធធាតុអាយតនៈខាងចុង គឺមិនដឹងថាខ្លួនស្លាប់ពីនេះនឹងទៅកើតជាអ្វី ជាមនុស្ស ឬជាសត្វក៏មិនដឹង ១ ។

**អបរាបរន្តេ អញ្ញាណំ** មិនដឹងក្នុងខន្ធធាតុអាយតនៈ ទាំងអតីតៈ អនាគត បច្ចុប្បន្ន គឺមិនដឹងទាំងជាតិមុខជាតិក្រោយ និងជាតិនេះ ១ ។

**ទុក្ខេ អញ្ញាណំ** មិនដឹងច្បាស់នូវទុក្ខទាំង ១២ កង មានជាតិទុក្ខជាដើម ១ ។

**ទុក្ខសមុទយេ អញ្ញាណំ** មិនដឹងច្បាស់នូវហេតុដែលនាំឱ្យកើតទុក្ខគឺតណ្ហាទាំង ៣ មានកាមតណ្ហាជាដើម ១ ។

**ទុក្ខនិរោធគាមិនីបដិបទា អញ្ញាណំ** មិនដឹងច្បាស់នូវបដិបទា គឺសីល សមាធិ បញ្ញា ជាផ្លូវប្រតិបត្តិឱ្យរលត់ទុក្ខ ១ ។

**បដិច្ចសមុប្បាទេ អញ្ញាណំ** មិនដឹងច្បាស់នូវហេតុនៃធម៌ជាបច្ច័យឱ្យកើតឡើងតៗ គ្នា មាន ១២ គឺអវិជ្ជាជាបច្ច័យឱ្យកើតសង្ខារៗ ជាបច្ច័យឱ្យកើតវិញ្ញាណៗ ជាបច្ច័យឱ្យកើតនាមរូបៗ ជាបច្ច័យឱ្យកើតអាយតនៈៗ ជាបច្ច័យឱ្យកើតផស្សៈៗ ជាបច្ច័យឱ្យកើតវេទនាៗ ជាបច្ច័យឱ្យកើតតណ្ហាៗ ជាបច្ច័យឱ្យកើតឧបាទានៗ ជាបច្ច័យឱ្យកើតភពៗ ជាបច្ច័យឱ្យកើតជាតិៗ ជាបច្ច័យឱយកើតជរា មរណៈ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្ស ជាដើមរៀងៗ ទៅ ។

**បដិសន្ធិអនិដ្ឋសច្ចស្ស** ពួកសត្វដែលមានអវិជ្ជាបិទបាំងនៅឡើយនោះមិនអាចឃើញ ឬដឹងច្បាស់នូវបដិសន្ធិឱ្យពិតប្រាកដបាន ដូចមានរឿងដំណាលពីបេសការធីតា កាលព្រះសម្មាសម្ពុទ្ធគង់នៅកណ្តាលទីប្រជុំពុទ្ធបរិស័ទ ក្នុងដែនអាឡវី ឃើញនាងបេសការធីតានោះដើរមក ព្រះអង្គត្រាស់ហៅថា នែ នាង

នេះទៅណា? នាងនោះឆ្លើយថា ខ្ញុំព្រះអង្គមិនដឹងជាទៅណាទេ, ព្រះអង្គសួរទៀតថាៈ ចុះនាងមកពីណា? នាងនោះឆ្លើយថា ខ្ញុំព្រះអង្គមិនដឹងជាមកពីណាទេ ។ ឯពួកពុទ្ធបរិស័ទដែលនៅអង្គុយគាល់ព្រះអង្គត្រៀបត្រាក្នុងទីនោះ ក៏កើតសេចក្តីងឿងឆ្ងល់ដល់ធីតានោះថា ហេតុដូចម្តេចក៏បានជានាងនេះ និយាយពាក្យដូច្នេះមកកាន់ព្រះអង្គ, ទើបព្រះអង្គសួរថា ម្នាលបេសការ-ធីតា ដែលនាងឆ្លើយថាមិនដឹងជាទៅណា តើនាងមិនដឹងនូវអ្វី? នាងនោះឆ្លើយតបថា ខ្ញុំព្រះអង្គមិនដឹងនូវដំណើរវិញ្ញាណក្ខន្ធដែលទៅកាន់យកបដិសន្ធិក្នុងភពថ្មីទៀត គឺខ្ញុំព្រះអង្គមិនដឹងជាខ្លួនស្លាប់ពីនេះទៅៗ កើតជាសត្វ ឬជាមនុស្សទៀតឡើយ ចុះនាងថាមិនដឹងជាខ្លួននាងមកពីណា? នាងឆ្លើយថា នោះក៏ខ្ញុំព្រះអង្គ មិនដឹងថាខ្លួនមកពីណាមកកើតក្នុងទីនេះបានឡើយ គឺខ្ញុំព្រះអង្គមិនអាចដឹងបានថា ខ្លួនមកពីមនុស្ស ឬទេពតាមកកើតក្នុងទីនេះ ទើបក្រាបទូលព្រះអង្គតាមការពិត ព្រះអង្គក៏ប្រទានសព្ទសាធុការពរដល់នាងនោះ ហើយទ្រង់សំដែងអំពីធម៌ ដែលមិនដឹងដល់គ្នានឹងគ្នា មានអវិជ្ជានិងសង្ខារជាដើម លុះចប់ធម៌-

ទេសនាហើយពុទ្ធបរិស័ទក្នុងទីប្រជុំនោះ មាននាងជាដើម ក៏បានសម្រេចសោតាបត្តិផល ។

ឯរឿងដែលនាំមកសម្ដែងពន្យល់អំពីអវិជ្ជា ៨ ប្រការនេះ ក៏ល្មមស្ដាប់បានហើយដោយន័យដែលវិសជ្ជនាមកដូចនេះឯង ។

---

# មង្គលទី ៣៨

ខេមំ អ្នកដែលមានសេចក្ដីក្សេមចាកយោគៈ ជាគ្រឿងប្រកបចងរឹតរួតក្នុងសន្ដាន ជាមង្គលដ៏ឧត្តម ។

អធិប្បាយថា: យោគៈមាន ៤ ប្រការគឺ:

**កាមយោគៈ** សេចក្ដីតម្រេកត្រេកត្រអាលក្នុងកាមគុណ ៥ គឺ: រូប, សម្លេង, ក្លិន, រស, សម្ផស្ស ដែលជាគ្រឿងប្រកបសត្វ ឬចងចិត្តសត្វ ១ ។

**ភវយោគៈ** ភពគឺកន្លែងកើតទាំង ៣ កន្លែង គឺកាមភព, រូបភព, អរូបភព ទាំង៣នេះជាគ្រឿងប្រកបចងចិត្តសត្វទុក១ ។

**ទិដ្ឋិយោគៈ** ទិដ្ឋិគឺសេចក្តីយល់ខុស គឺឃើញថាសត្វទៀង លោកទៀង ឬយល់ថាសត្វស្លាប់ទៅសូន្យ លោកសូន្យជាដើម ជាគ្រឿងប្រកបចិត្តសត្វទុក ១ ។

**អវិជ្ជាយោគៈ** ការមិនដឹងដល់ដើមកំណើតនៃសង្ខារ ជាគ្រឿងប្រកបចិត្តសត្វទុក ១ (រួមជា ៤ ប្រការ) ។

ធម៌ជាគ្រឿងរំលត់យោគៈ ៤ ប្រការនេះឱ្យអស់ទៅត្រូវធ្វើ សីល សមាធិ បញ្ញា ឱ្យកើតចាស់ក្លាឡើងក្នុងសន្តាន ទើបនឹងសម្លាប់យោគៈទាំង ៤ នេះបាន ចិត្តក៏ជ្រះថ្លាបរិសុទ្ធស្អាតផូរផង់ក្នុងសន្តាន ដោយមានធម៌ជាគ្រឿងធ្វើឱ្យកើតសេចក្តីសុខក្សេម-ក្សាន្ត និរាសប្រាសចាកសេចក្តីទុក្ខភ័យអន្តរាយទាំងឡាយគ្រប់ប្រការ សូម្បីមនុស្សណានឹងគិតប្រទូស្តធ្វើការអាក្រក់ដល់ខ្លួនក៏មិនបានឡើយ, ដូចមានរឿងដំណាលពីមហាកាឡត្ថេរថា: លោកជាអ្នកមានសទ្ធា រត់ចោលភរិយាទាំង ៨ នាក់ ទៅបួសក្នុងសំណាក់ព្រះពុទ្ធសាសនា ហើយមានព្យាយាមខំចម្រើនសមថវិបស្សនា មិនយូរប៉ុន្មាន ក៏បានសម្រេចព្រះអរហត្តផល, ឯភរិយាចិត្តចង់ឱ្យលោកសឹកមកវិញ ទើបប្រើមនុស្សឱ្យទៅនិមន្តលោកដែលជាស្វាមីនោះ មកឆាន់ក្នុងផ្ទះខ្លួន លោកក៏

ទទួលនិមន្តមក លុះលោកឆាន់រួចហើយ ភរិយាទាំង ៨ នាក់ ក៏បបួលគ្នាចោមរោមលោកជុំវិញ ប្រាថ្នានឹងចាប់ផ្សឹក ព្រះថេរៈ ឃើញអាការៈមិនស្រួលដូច្នោះហើយ លោកក៏ចូលឈាន ហោះ ឡើងកាន់អាកាសទៅកាន់អារាមវិញ រួចចាកសេចក្ដីអន្តរាយ ដោយហេតុលោកបានកំចាត់បង់ឃោគៈទាំងឡាយ ឱ្យអស់ ពីសន្ដាន ដូចបានវិសជ្ជនាមកនេះឯង ៕

(ចប់មង្គល ៣៨ ប្រការ)

**ឯតាទិសានិ កត្វាន** បុគ្គលដែលបានប្រព្រឹត្តធ្វើនូវមង្គលទាំងឡាយនេះ ឱ្យពេញបរិបូណ៌ក្នុងសន្តាន ហើយជាអ្នកមិនចាលចាញ់ក្នុងទីទាំងពួង តែងដល់នូវសិរីសួស្តីក្នុងទីទាំងពួងមង្គលទាំង ៣៨ ប្រការ មានកិរិយាមិនសេពគប់នូវបុគ្គលពាលជាដើមនោះ ជារបស់ទេវតានិងមនុស្សទាំងអម្បាលណោះសុទ្ធតែជាមង្គលដ៏ឧត្តមទាំងអស់ ។

អធិប្បាយសេចក្តីសរុបថា: មង្គលទាំង ៣៨ ប្រការនេះ បើបុគ្គលណាបានធ្វើឱ្យគ្រប់គ្រាន់ហើយ បុគ្គលនោះនឹងបានសំរេចមគ្គផល ព្រះនិព្វានជាស្ថានក្សេមផុតចាកទុក្ខទាំងពួង បើមិនទាន់បានដល់និព្វានទេ នៅវិលវល់ក្នុងវដ្តសង្សារក៏គង់មិនធ្លាក់ទៅសោយទុក្ខវេទនាក្នុងអបាយភូមិឡើយ ដោយអំណាចកម្មជាកុសលនោះជួយឧបត្ថម្ភ កម្មនេះប្រែថាធ្វើ គោលដើមមាន ២ យ៉ាងគឺ: កុសលកម្ម ១ អកុសលកម្ម ១ កម្មទាំងពីរនេះចែកចេញទៅជាកម្ម ១១ ឬ១២ យ៉ាងគឺ:

**១-ទិដ្ឋធម្មវេទនីយកម្ម** កម្មជាបុណ្យក្តី ជាបាបក្តីឱ្យផលក្នុងបច្ចុប្បន្នជាតិនេះ ។

**២-ឧបបជ្ជវេទនីយកម្ម** កម្មជាបុណ្យ ឬបាបឱ្យផលទៅក្នុងជាតិមុខ ។

**៣-អបរាបរវេទនីយកម្ម** កម្មជាបុណ្យ ឬបាបឱ្យផលក្នុងជាតិទី ២ ឡើងទៅ ។

**៤-គរុកម្ម** កម្មធ្ងន់ បើបុណ្យបានដល់ឈាន ៤, សមាបត្តិ ៨, បើបាបបានដល់អនន្តរិយកម្ម ៥ គឺៈ សម្លាប់មាតា, បិតា, ព្រះអរហន្ត, ធ្វើលោហិតុប្បាទ, សង្ឃភេទ ។

**៥-អាចិណ្ណកម្ម** បុណ្យឬបាប ដែលខ្លួនធ្វើហើយនឹកញយៗ

**៦-អាសន្នកម្ម** បុណ្យឬបាប ដែលខ្លួនធ្វើជិតពេលមរណៈ ទោះបីទន់ខ្សោយបន្តិចបន្តួចក៏ដោយ អាចឱ្យផលមុនបាន ដូចគោចាស់នៅជិតមាត់ក្រោល ។

**៧-កដត្តាវាបនកម្ម** បុណ្យឬបាបស្រាលមានកម្លាំងតិច បើបុណ្យឬបាបដទៃមិនឱ្យផលទេ ក៏អាចឱ្យផលក្នុងចន្លោះគេដូចមនុស្សឆ្កួតបាញ់សរ ។

**៨-ជនកកម្ម** បុណ្យឬបាបដែលនាំបដិសន្ធិវិញ្ញាណឱ្យកើតក្នុងភព ។

**៩-ឧបត្ថម្ភកកម្ម** បុណ្យឬបាបដែលជួយជ្រោមជ្រែងកម្មចាស់ឱយមានកម្លាំង ។

**១០-ឧបបីឡកកម្ម** បុណ្យឬបាបដែលចូលមកបៀតបៀនកម្មចាស់ឱ្យមានកម្លាំងខ្សោយ ហើយឱ្យផលដោយខ្លួនឯង បើបាបប្រៀបដូចឆ្កែដេញសត្វ បើបុណ្យប្រៀបដូចពលៀងកូនក្មេងដេញទាន់ត្រង់ទីណា ក៏ចាប់ត្រកងបីពទ្បើងក្នុងទីនោះ ។

**១១-ឧបឃាតកកម្ម** បុណ្យឬបាបដែលក្លាហានអាចសម្លាប់បុណ្យឬបាបដែលមានកម្លាំងអន់ទន់ខ្សោយបាន ដូចអ្នកដែលស្លាប់ដោយលេបថ្នាំពិសជាដើម ។ បើរាប់កម្មមាន ១២ នេះ ត្រូវថែមលហុកម្ម ១ ទៀតបន្ទាប់គរុកម្មទី ៤ នោះ ។

អធិប្បាយសង្គ្រោះកម្ម ១១ ក្នុងខាងចុងមង្គល ៣៨ ប្រការ ចប់ដោយសង្ខេបប៉ុណ្ណោះឯង ៕

ចប់អធិប្បាយមង្គល ៣៨ ប្រការ

---

វាយជាអក្សរកំព្យូទ័រសម្រាប់ប្រើជាមួយនឹងឧបករណ៍ទំនើបឈ្មោះ (Ipad)

ដោយភិក្ខុបញ្ញាបទីបោ **ប៉ាត សុផល**

ផ្ទៀងផ្ទាត់អក្ខរាវិរុទ្ធដោយភិក្ខុសុវណ្ណត្ថេរ **ហ៊ុយ ហុច**

ចាប់ផ្ដើមវាយនៅថ្ងៃទី ២៧ ចប់នៅថ្ងៃទី ៣០ ខែឧសភា ឆ្នាំ២០១១

**វត្តរតនរង្សី រីវៀរ**

75 Thornton Street
Revre, MA 02151
Tel: (781) 286-1942